ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 36

# ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្ម

## Impairment of Assets

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនកម្មផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

៣៥៙៧៧

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**"។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី "គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ" នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ **ស្តង់ដារគណនេយ្យកម្ពុជា** ដែលរួមមាន "***ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា***" និង "***ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម***" ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឌី តាយី**

## គោលបំណង

១ គោលបំណងនៃស្តង់ដានេះគឺកំណត់ពីនីតិវិធី ដែលអង្គភាពមួយអនុវត្ត ដើម្បីធានាថាការកំណត់តម្លៃទ្រព្យសកម្មរបស់ខ្លួន មិនលើសពីតម្លៃអាចទទួលបានមកវិញ។ ទ្រព្យសកម្មមួយត្រូវបានកំណត់តម្លៃលើសពីតម្លៃអាចទទួលបានមកវិញប្រសិនបើតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្មនោះលើសពីតម្លៃទទួលបានមកវិញតាមរយៈការប្រើប្រាស់ ឬការលក់ទ្រព្យសកម្មនោះ។ ក្នុងករណីនេះ ទ្រព្យសកម្ម ត្រូវបានគេចាត់ទុកថាជាការធ្លាក់ចុះតម្លៃ ហើយស្តង់ដាតម្រូវឱ្យអង្គភាពទទួលស្គាល់ថា ជាការខាតពីការធ្លាក់ចុះតម្លៃ។ ស្តង់ដាក៏បានបញ្ជាក់ នៅពេលដែលអង្គភាពមួយគួរប្រែត្រឡប់ការខាតពីការធ្លាក់ចុះតម្លៃ និងការលាតត្រដាងព័ត៌មានផងដែរ។

## វិសាលភាព

២ ស្តង់ដានេះ ត្រូវបានអនុវត្ត ចំពោះគណនេយ្យ សម្រាប់ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្មទាំងអស់ លើកលែងតែៈ

(ក) សន្និធិ (សូមមើល ស.គ.អ.ក២ សន្និធិ)

(ខ) ទ្រព្យសកម្មកើតចេញពីកិច្ចសន្យាសាងសង់ (សូមមើល ស.គ.អ.ក ១១កិច្ចសន្យាសាង់សង់)

(គ) ទ្រព្យសកម្មពន្ធពន្យារ (សូមមើល ស.គ.អ.ក១២ ពន្ធលើប្រាក់ចំណូល)

(ឃ) ទ្រព្យសកម្មកើតចេញពីអត្ថប្រយោជន៍និយោជិក (សូមមើល ស.គ.អ.ក ១៩អត្ថប្រយោជន៍និយោជិក)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ

(ច) ទ្រព្យវិនិយោគដែលវាស់វែងតាមតម្លៃសមស្រប(សូមមើលស.គ.អ.ក ៤០ ទ្រព្យវិនិយោគ)

(ឆ) ទ្រព្យសកម្មជីវសាស្ត្រពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ដែលវាស់វែងតាមតម្លៃសមស្របដកថ្លៃដើមដើម្បីលក់ (សូមមើល ស.គ.អ.ក ៤១ កសិកម្ម)

(ជ) ចំណាយលើការទិញពន្យារនិងទ្រព្យសកម្មអរូបីយកើតចេញ ពីសិទ្ធិកិច្ចសន្យារបស់អ្នកធានារ៉ាប់រង ក្រោមកិច្ចសន្យាធានារ៉ាប់រងនៅក្នុងវិសាលភាព ស.រ.ហ.អ.ក ៤ កិច្ចសន្យាធានារ៉ាប់រង និង

(ញ) ទ្រព្យសកម្មរយៈពេលវែង (ឬការលក់ជាក្រុម) ដែលបានចាត់ថ្នាក់ទុកសម្រាប់លក់ស្របតាម ស.រ.ហ.អ.ក ៥ ទ្រព្យសកម្មរយៈពេលវែងទុកសម្រាប់លក់ និងប្រតិបត្តិការមិនបន្ត។

៣ ស្តង់ដានេះមិនអនុវត្តចំពោះសន្និធិ ទ្រព្យសកម្មកើតចេញពីកិច្ចសន្យាសាងសង់ទ្រព្យសកម្មពន្ធពន្យារ ទ្រព្យសកម្មកើតចេញពីអត្ថប្រយោជន៍និយោជិក

ឬទ្រព្យសកម្ម ដែលបានចាត់ថ្នាក់ទុកសម្រាប់លក់ (ឬការលក់ជាក្រុមដែលត្រូវបានចាត់ថ្នាក់ទុកសម្រាប់លក់) ព្រោះស.រ.ហ.អ.ក ដែលមានស្រាប់អាចអនុវត្តចំពោះទ្រព្យសកម្មទាំងនេះ ដោយបានកំណត់នូវលក្ខខណ្ឌតម្រូវសម្រាប់ទទួលស្គាល់ និងវាស់វែងនូវទ្រព្យសកម្មទាំងនេះ។

៤ ស្តង់ដានេះអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានចាត់ថ្នាក់ជាៈ

(ក) បុត្រសម្ព័ន្ធ ដូចមានកំណត់ក្នុង ស.គ.អ.ក ២៧ របាយការណ៍ហិរញ្ញវត្ថុរួមគ្នា និងដាច់ដោយឡែក

(ខ) ញាតិសម្ព័ន្ធ ដូចមានកំណត់ក្នុងស.គ.អ.ក ២៨ ការវិនិយោគក្នុងញាតិសម្ព័ន្ធ និង

(គ) ក្រុមហ៊ុនរួមទុនដូចមានកំណត់ក្នុង ស.គ.អ.ក៣១ ផលប្រយោជន៍ក្នុងក្រុមហ៊ុនរួមទុន។

សម្រាប់ការធ្លាក់ចុះ នៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត អនុវត្តតាម ស.គ.អ.ក៣៩។

៥ ស្តង់ដានេះមិនអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ទ្រព្យវិនិយោគដែលវាស់វែងតាមតម្លៃសមស្របស្របតាម ស.គ.អ.ក ៤០ ឬទ្រព្យសកម្មជីវសាស្ត្រពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ដែលវាស់វែងតាមតម្លៃសមស្របដកថ្លៃដើមដើម្បីលក់ស្របតាម ស.គ.អ.ក ៤១។ ប៉ុន្តែ ស្តង់ដានេះអនុវត្តចំពោះទ្រព្យសកម្មដែលអនុវត្តការវាយតម្លៃឡើងវិញ (ឧទាហរណ៍ តម្លៃសមស្រប) ស្របតាម ស.រ.ហ.អ.ក ដូចគំរូនៃការវាយតម្លៃឡើងវិញក្នុងស.គ.អ.ក ១៦ ទ្រព្យ រោងចក្រ និងឧបករណ៍។ ការកំណត់

ពីទ្រព្យសកម្ម ដែលត្រូវវាយតម្លៃឡើងវិញ ដែលអាចត្រូវធ្លាក់ចុះនៃតម្លៃ អាស្រ័យទៅលើមូលដ្ឋានប្រើប្រាស់ក្នុងការកំណត់តម្លៃសមស្រប÷

(ក) ប្រសិនបើតម្លៃសមស្របរបស់ទ្រព្យសកម្មគឺជាតម្លៃទីផ្សារ ភាពខុសគ្នារវាងតម្លៃសមស្របរបស់ទ្រព្យសកម្ម និងតម្លៃសមស្របដកថ្លៃដើមដើម្បីលក់ គឺជាចំណាយបន្ថែម ដោយផ្ទាល់ដើម្បីលក់ទ្រព្យសកម្មនោះ÷

(១) ប្រសិនបើចំណាយលក់មិនធំដុំ តម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្ម បានវាយតម្លៃឡើងវិញប្រហាក់ប្រហែលនឹង ឬច្រើនជាងតម្លៃដែលបានវាយតម្លៃឡើងវិញ (ឧទាហរណ៍ តម្លៃសមស្រប)។ ក្នុងករណីនេះ បន្ទាប់ពីការអនុវត្តលក្ខខណ្ឌតម្រូវនៃការវាយតម្លៃឡើងតម្លៃទ្រព្យសកម្ម ដែលបានវាយតម្លៃឡើងវិញ មិនត្រូវបានធ្លាក់ចុះតម្លៃហើយតម្លៃអាចទទួលបានមកវិញក៍មិនចាំបាច់ធ្វើការប៉ាន់ស្មាន។

(២) ប្រសិនបើចំណាយលក់ធំដុំ តម្លៃសមស្របដកថ្លៃដើម ដើម្បីលក់នៃទ្រព្យសកម្មបានវាយតម្លៃឡើងវិញ គឺតិចជាងតម្លៃសមស្រប។ ដូចនេះ ទ្រព្យសកម្មបានវាយតម្លៃឡើងវិញនឹងត្រូវធ្លាក់ចុះតម្លៃប្រសិនបើតម្លៃកំពុងប្រើប្រាស់តិចជាងតម្លៃដែលបានវាយតម្លៃឡើងវិញ (ឧទាហរណ៍ តម្លៃសមស្រប)។ ក្នុងករណីនេះ បន្ទាប់ពីការអនុវត្តលក្ខខណ្ឌតម្រូវនៃការវាយតម្លៃឡើង អង្គភាពមួយអនុវត្តស្តង់ដានេះ ដើម្បីកំណត់ពីទ្រព្យសកម្មដែលអាចធ្លាក់ចុះតម្លៃ។

(ខ) ប្រសិនបើតម្លៃសមស្របរបស់ទ្រព្យសកម្ម ត្រូវបានកំណត់ផ្អែកលើមូលដ្ឋានមិនមែនតាមតម្លៃទីផ្សារតម្លៃ ដែលបានវាយតម្លៃឡើងវិញ (ឧទាហរណ៍ តម្លៃសមស្រប) អាចច្រើនជាង ឬតិចជាងតម្លៃអាចទទួលបានមកវិញ។ ដូចនេះ បន្ទាប់ពីការអនុវត្តលក្ខខណ្ឌតម្រូវនៃការវាយតម្លៃឡើងអង្គភាពមួយ អនុវត្តស្តង់ដានេះ ដើម្បីកំណត់ពីទ្រព្យសកម្ម ដែលអាចធ្លាក់ចុះតម្លៃ។

## និយមន័យ

៦ ពាក្យបច្ចេកទេសខាងក្រោម ត្រូវបានប្រើប្រាស់ក្នុងស្តង់ដានេះ ជាមួយអត្ថន័យជាក់លាក់:

ទីផ្សារសកម្ម គឺជាទីផ្សារដែលអាចគោរពបាននូវលក្ខខណ្ឌដូចខាងក្រោម÷

(ក) ធាតុបានដាក់លក់ក្នុងទីផ្សារដែលមានលក្ខណៈដូចគ្នា

(ខ) ការស្ម័គ្រចិត្តរបស់អ្នកទិញ និងអ្នកលក់អាចធ្វើទៅបានគ្រប់ពេល និង

(គ) ថ្លៃអាចរកបានជាសាធារណៈ។

តម្លៃក្នុងបញ្ជី គឺជាតម្លៃដែលទ្រព្យសកម្មត្រូវបានទទួលស្គាល់បន្ទាប់ពីដកចេញនូវរំលស់បូកបន្ត និងការខាតពីការធ្លាក់ចុះតម្លៃបូកបន្ត។

អង្គភាពរកសាច់ប្រាក់ គឺជាក្រុមទ្រព្យសកម្មអាចកំណត់បានតូចបំផុតដែលបង្កើតលំហូរសាច់ប្រាក់ចូលដែលមានឯករាជ្យភាពច្រើននៃលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មផ្សេងទៀត។

ទ្រព្យសកម្មសារជីវកម្មគឺជាទ្រព្យសកម្មទាំងឡាយណាដែលមិនមែនមូលនិធិពាណិជ្ជកម្មដែលបញ្ចូលទៅសាច់ប្រាក់អនាគតទាំងអង្គភាពរកសាច់ប្រាក់ដែលស្ថិតក្រោមការត្រួតពិនិត្យនិងអង្គភាពរកសាច់ប្រាក់ផ្សេងទៀត។

ចំណាយលើការលក់ គឺជាចំណាយបន្ថែមដែលចូលរួមដោយផ្ទាល់លើការលក់ទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់ ដោយមិនរាប់បញ្ចូលចំណាយហិរញ្ញវត្ថុ និងចំណាយពន្ធលើប្រាក់ចំណូល។

តម្លៃដែលអាចរំលស់បានគឺជាការចំណាយលើទ្រព្យសកម្មមួយ ឬតម្លៃជំនួសផ្សេងទៀតសម្រាប់ចំណាយក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដកតម្លៃកាកសំណល់។

ការរំលស់ គឺជាការបែងចែកជាប្រព័ន្ធនៃតម្លៃដែលអាចរំលស់បាននៃទ្រព្យសកម្មមួយលើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនោះ។[a]

តម្លៃសមស្របដកថ្លៃដើមដើម្បីលក់ គឺជាតម្លៃ ដែលទទួលបានពីការលក់ទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់នៅក្នុងប្រតិបត្តិការបណ្តោយដៃរវាងភាគីដែលមានការយល់ដឹង ដកថ្លៃលក់។

ការខាតពីការធ្លាក់ចុះតម្លៃ គឺជាតម្លៃដែលតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់លើសពីតម្លៃអាចទទួលបានមកវិញ។

តម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់ខ្ពស់ជាងតម្លៃសមស្របដកថ្លៃដើម ដើម្បីលក់និងតម្លៃកំពុងប្រើប្រាស់។

---

[a] ក្នុងករណីដែលទ្រព្យសកម្មអរូបីយ ពាក្យ (រំលស់) ជាទូទៅត្រូវបាន ប្រើប្រាស់ជំនួស (រំលស់) ។ ពាក្យទាំងពីរគឺមានន័យដូចគ្នា ។

អាយុកាលប្រើប្រាស់ គឺៈ

(ក) រយៈពេលដែលទ្រព្យសកម្មមួយរំពឹងប្រើប្រាស់ដោយអង្គភាព ឬ

(ខ) ចំនួននៃផលិតកម្ម ឬឯកតាប្រហាក់ប្រហែលគ្នា រំពឹងទទួលបាន ពីទ្រព្យសកម្មដោយអង្គភាពមួយ។

តម្លៃកំពុងប្រើប្រាស់គឺជាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគតរំពឹងទទួលបានពីទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់។

## ការកំណត់ពីទ្រព្យសកម្មមួយដែលអាចធ្លាក់ចុះតម្លៃ

៧ កថាខណ្ឌទី ៨-១៧ បញ្ជាក់ពេលដែលតម្លៃអាចទទួលបានមកវិញ ត្រូវបានកំណត់។ លក្ខខណ្ឌទាំងនេះប្រើប្រាស់ពាក្យ (ទ្រព្យសកម្ម) ប៉ុន្តែអនុវត្តដូចគ្នាទៅនឹងទ្រព្យសកម្មនីមួយៗ ឬអង្គភាពរកសាច់ប្រាក់។ ស្តង់ដានេះត្រូវបានរៀបចំរចនាសម្ព័ន្ធ ដូចខាងក្រោម÷

(ក) កថាខណ្ឌទី ១៨-៥៧ កំណត់ពីលក្ខខណ្ឌសម្រាប់វាស់វែងតម្លៃអាចទទួលបានមកវិញ។ លក្ខខណ្ឌទាំងនេះ ក៏ប្រើប្រាស់ពាក្យ (ទ្រព្យសកម្ម)ដែរ ប៉ុន្តែអនុវត្តដូចគ្នានឹងទ្រព្យសកម្មនីមួយៗ និងអង្គភាពរកសាច់ប្រាក់។

(ខ) កថាខណ្ឌទី ៥៨-១០៨ កំណត់ពីលក្ខខណ្ឌសម្រាប់ទទួលស្គាល់ និងវាស់វែងការខាតពីការធ្លាក់ចុះតម្លៃ។ ការទទួលស្គាល់ និងការវាស់វែងនៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មនីមួយៗ មិនមែនមូលនិធិពាណិជ្ជកម្មដែលត្រូវអនុវត្តតាមកថាខណ្ឌទី ៥៨-៦៤។ កថាខណ្ឌទី ៦៥-១០៨ អនុវត្តចំពោះការទទួលស្គាល់ និងការវាស់វែ

ងនៃការខាតពីការធ្លាក់ចុះតម្លៃ សម្រាប់អង្គភាពរកសាច់ប្រាក់ និង មូលនិធិពាណិជ្ជកម្ម។

(គ) កថាខណ្ឌទី ១០៩-១១៦ កំណត់ពីលក្ខខណ្ឌសម្រាប់ការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃ ក្នុងគ្រាមុនសម្រាប់ទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់។ ម្តងទៀត លក្ខខណ្ឌទាំងនេះ ប្រើប្រាស់ពាក្យ (ទ្រព្យសកម្មមួយ) ប៉ុន្តែអនុវត្តដូចគ្នានឹងទ្រព្យសកម្មនីមួយៗ ឬអង្គភាពរកសាច់ប្រាក់។ លក្ខខណ្ឌបន្ថែមសម្រាប់ទ្រព្យសកម្មនីមួយៗ ត្រូវបានកំណត់ក្នុងកថាខណ្ឌទី ១១៧-១២១ សម្រាប់អង្គភាពរកសាច់ប្រាក់ក្នុងកថាខណ្ឌទី ១២២ និង ១២៣ និងសម្រាប់មូលនិធិពាណិជ្ជកម្មក្នុងកថាខណ្ឌទី ១២៤ និង ១២៥។

(ឃ) កថាខណ្ឌទី ១២៦-១៣៣ បញ្ជាក់ពីព័ត៌មាន ដែលត្រូវលាតត្រដាងព័ត៌មានពីការខាតពីការធ្លាក់ចុះតម្លៃ និងការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្ម និងអង្គភាពរកសាច់ប្រាក់។ កថាខណ្ឌ ១៣៤-១៣៧ បញ្ជាក់ពីការលាតត្រដាងព័ត៌មានបន្ថែមសម្រាប់អង្គភាពរកសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មឬទ្រព្យសកម្មអរូបីយ ជាមួយនឹងអាយុកាលប្រើប្រាស់មិនកំណត់ត្រូវបានបែងចែកសម្រាប់គោលបំណងធ្វើតេស្តការធ្លាក់ចុះនៃតម្លៃ។

៨ ទ្រព្យសកម្មមួយត្រូវបានចាត់ទុកថាធ្លាក់ចុះតម្លៃនៅពេលតម្លៃក្នុងបញ្ជី លើសពីតម្លៃអាចទទួលបានមកវិញ។ កថាខណ្ឌទី ១២-១៤ សញ្ញាបង្ហាញពីការខាតពីការធ្លាក់ចុះតម្លៃដែលអាចកើតឡើង។ ប្រសិនបើមានសញ្ញាបង្ហាញអង្គភាពមួយតម្រូវឱ្យបង្កើតការប៉ាន់ស្មានតម្លៃអាចទទួលបានមកវិញជាផ្លូវ

ការ។ លើកលែងតែមានសញ្ញាក្នុងកថាខណ្ឌ ទី ១០ ស្តង់ដានេះមិនតម្រូវឱ្យអង្គភាពបង្កើតការប៉ាន់ស្មានតម្លៃអាចទទួលបានមកវិញជាផ្លូវការប្រសិនបើគ្មានការសញ្ញាបង្ហាញនៃការខាតពីការធ្លាក់ចុះតម្លៃ។

៩ **អង្គភាពមួយត្រូវវាយតម្លៃនៅចុងគ្រារាយការណ៍នីមួយៗ ពីសញ្ញាបង្ហាញថាទ្រព្យសកម្មណាមួយ អាចធ្លាក់ចុះតម្លៃ។ ប្រសិនបើមានសញ្ញាបង្ហាញ អង្គភាពត្រូវប៉ាន់ស្មានតម្លៃអាចទទួលបានមកវិញ។**

១០ **មិនពាក់ព័ន្ធនឹងសញ្ញានៃការធ្លាក់ចុះនៃតម្លៃ អង្គភាពក៏ត្រូវៈ**

(ក) **ធ្វើតេស្តទ្រព្យសកម្មអរូបីយមួយដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬទ្រព្យសកម្មអរូបីយមួយ ដែលមិនមានប្រើសម្រាប់ការធ្លាក់ចុះតម្លៃប្រចាំឆ្នាំដោយប្រៀបធៀបតម្លៃក្នុងបញ្ជីជាមួយតម្លៃអាចទទួលបានមកវិញ។ ការធ្វើតេស្តការធ្លាក់ចុះតម្លៃអាចអនុវត្តបានគ្រប់ពេលក្នុងកំឡុងគ្រាប្រចាំឆ្នាំ។ ភាពខុសគ្នាទ្រព្យសកម្មអរូបីយ អាចត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះនៃតម្លៃនៅពេលខុសគ្នា។ ប៉ុន្តែទ្រព្យសកម្មអរូបីយមួយត្រូវបានទទួលស្គាល់ដំបូងកំឡុងគ្រាបច្ចុប្បន្នប្រចាំឆ្នាំ ដែលទ្រព្យសកម្មអរូបីយត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃមុនពេលចុងគ្រាបច្ចុប្បន្នប្រចាំឆ្នាំ។**

(ខ) **ធ្វើតេស្តមូលនិធិពាណិជ្ជកម្មតម្រូវក្នុងការរួមបញ្ចូលអាជីវកម្ម សម្រាប់ការធ្លាក់ចុះនៃតម្លៃប្រចាំឆ្នាំស្របទៅតាមកថាខណ្ឌ ៨០-៩៩។**

១១ លទ្ធភាពនៃទ្រព្យសកម្មអរូបីយ ក្នុងការទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតគ្រប់គ្រាន់ដើម្បីទទួលបានតម្លៃអាចទទួលបានមកវិញគឺជាកម្មវត្ថុទៅនឹងភាពមិនប្រាកដប្រជាខ្ពស់មុនពេលទ្រព្យសកម្មអាចប្រើប្រាស់ជាងអា

ចប្រើប្រាស់។ ដូចនេះ ស្តង់ដានេះតម្រូវឱ្យអង្គភាពមួយធ្វើតេស្តសម្រាប់ការធ្លាក់ចុះនៃតម្លៃយ៉ាងហោចណាស់ប្រចាំឆ្នាំ តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មអរូបីយ មួយដែលមិនអាចប្រើប្រាស់បាន។

**១២ ក្នុងការវាយតម្លៃពីសញ្ញាបង្ហាញថាទ្រព្យសកម្មមួយអាចត្រូវបានធ្លាក់ចុះនៃតម្លៃអង្គភាពមួយត្រូវពិចារណាជាអប្បបរមានូវសញ្ញា ដូចខាងក្រោម÷**

ប្រភពព័ត៌មានខាងក្រៅ÷

(ក) ក្នុងកំឡុងគ្រា តម្លៃទីផ្សាររបស់ទ្រព្យសកម្មមួយធ្លាក់ចុះខ្លាំងជាងការរំពឹងទុកដែលជាលទ្ធផលនៃការកន្លងហួសពេលវេលា ឬការប្រើប្រាស់ធម្មតា។

(ខ) ការផ្លាស់ប្តូរដ៏សំខាន់ៗជាមួយនឹងផលប៉ះពាល់អាក្រក់មកលើអង្គភាពក្នុងកំឡុងគ្រា ឬនឹងកើតឡើងនាពេលអនាគតដ៏ខ្លី ក្នុងបរិស្ថានបច្ចេកវិទ្យា ទីផ្សារ សេដ្ឋកិច្ច ឬច្បាប់ ដែលអង្គភាពធ្វើអាជីវកម្ម ឬក្នុងទីផ្សារដែលទ្រព្យសកម្មមានគោលបំណងពិសេស។

(គ) អត្រាការប្រាក់ទីផ្សារ ឬអត្រាទីផ្សារនៃចំណូលលើការវិនិយោគផ្សេងទៀត បានកើនឡើងក្នុងកំឡុងគ្រា ហើយការកើនឡើងទាំងនោះទំនងប៉ះពាល់លើអត្រាអប្បហារដែលប្រើក្នុងការគណនាតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្ម ហើយធ្លាក់ចុះជាសារវន្តនូវតម្លៃអាចទទួលបានមកវិញរបស់ទ្រព្យសកម្ម។

(ឃ) តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពលើសពីមូលធននីយកម្ម។

ប្រភពព័ត៌មានខាងក្នុង÷

(ង) មានភស្តុតាងពីភាពហួសសម័យ ឬការខូចខាតរូបរាងនៃទ្រព្យសកម្មមួយ។

(ច) ការផ្លាស់ប្តូរដ៏សំខាន់ៗជាមួយនឹងផលប៉ះពាល់អាក្រក់មកលើអង្គភាពក្នុងកំឡុងគ្រា ឬត្រូវបានរំពឹងថាកើតឡើងនាពេលអនាគតដ៏ខ្លី ក្នុងបរិស្ថានបច្ចេកវិទ្យា ទីផ្សារ សេដ្ឋកិច្ច ឬច្បាប់ ដែលអង្គភាពធ្វើអាជីវកម្ម ក្នុងទំហំ ឬឥរិយាបទ ដែលទ្រព្យសកម្មមួយត្រូវបានប្រើ ឬត្រូវបានរំពឹងនឹងប្រើ។ ការផ្លាស់ប្តូរនេះរួមបញ្ចូលទ្រព្យសកម្ម ដែលបានទំនេរ ផែនការមិនបន្ត ឬរះរើប្រតិបត្តិការដែលទ្រព្យសកម្មស្ថិតនៅ ផែនការលក់ចោលទ្រព្យសកម្មមួយមុនពេលថ្ងៃដែលបានរំពឹងទុកពីមុន និងការវាយតម្លៃឡើងវិញនូវអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មមួយទៅជាមានអាយុកាលប្រើប្រាស់មានកាលកំណត់ជាជាងមិនមានកាលកំណត់។[៦]

---

[៦] នៅពេលទ្រព្យសកម្មមួយអាចអនុវត្តទៅតាមលក្ខខណ្ឌដែលត្រូវបានចាត់ថ្នាក់ទុកសម្រាប់លក់ (ឬស្ថិតក្នុងក្រុមទុកសម្រាប់លក់ដែលត្រូវបានចាត់ថ្នាក់ទុកសម្រាប់លក់) មិនរាប់បញ្ចូលក្នុងវិសាលភាពនៃស្តង់ដារនេះទេ ហើយរាប់បញ្ចូលស្របតាមស្តង់ដារ ស.រ.ហ.គ.ក ៥ ទ្រព្យសកម្មរយៈពេលវែងទុកសម្រាប់លក់ និងប្រតិបត្តិការមិនបន្ត។

(ជ) មានភស្តុតាងពីការរាយការណ៍ខាងក្នុងដែលបញ្ជាក់ថាដំណើរការសេដ្ឋកិច្ចនៃទ្រព្យសកម្មមានភាពអាក្រក់ ឬនឹងអាក្រក់ជាងការរំពឹងទុក។

ភាគលាភពីបុត្រសម្ព័ន្ធ អង្គភាពត្រួតពិនិត្យរួមគ្នា ឬញាតិសម្ព័ន្ធ

(ឈ) សម្រាប់ការវិនិយោគក្នុងបុត្រសម្ព័ន្ធអង្គភាពត្រួតពិនិត្យរួមគ្នា ឬញាតិសម្ព័ន្ធ វិនិយោគិនទទួលស្គាល់ភាគលាភបានមកពីការវិនិយោគ និងមានភស្តុតាងដែល÷

(១) តម្លៃក្នុងបញ្ជីនៃការវិនិយោគក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកលើសពីតម្លៃក្នុងបញ្ជីក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមនៃទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនដែលត្រូវបានវិនិយោគដោយរាប់បញ្ចូលនូវមូលនិធិពាណិជ្ជកម្ម ឬ

(២) ភាគលាភលើសពីចំណូលលម្អិតសរុបនៃបុត្រសម្ព័ន្ធ អង្គភាពត្រួតពិនិត្យរួមគ្នា ឬញាតិសម្ព័ន្ធក្នុងគ្រាដែលភាគលាភត្រូវបានប្រកាស។

១៣ ការរាយក្នុងកថាខណ្ឌទី ១២ មិនទាន់គ្រប់គ្រាន់។ អង្គភាពមួយអាចកំណត់សញ្ញាដែលទ្រព្យសកម្មមួយអាចនឹងត្រូវបានធ្លាក់ចុះតម្លៃហើយតម្រូវឱ្យអង្គភាពកំណត់តម្លៃអាចទទួលបានមកវិញរបស់ទ្រព្យសកម្ម ឬក្នុងករណីមូលនិធិពាណិជ្ជកម្ម អាចអនុវត្តការធ្វើតេស្តការធ្លាក់ចុះតម្លៃស្របតាមកថាខណ្ឌទី ៨០-៩៩។

១៤ ភស្តុតាងពីការរាយការណ៍ខាងក្នុងដែលបង្ហាញថាទ្រព្យសកម្មមួយអាចត្រូវថយចុះតម្លៃដែលរួមបញ្ចូលនូវ÷

(ក) លំហូរសាច់ប្រាក់សម្រាប់ការទិញទ្រព្យសកម្ម ឬសាច់ប្រាក់ដែលត្រូវការសម្រាប់ប្រតិបត្តិការ ឬរក្សាទ្រព្យសកម្មនេះដែលខ្ពស់ខ្លាំងគម្រោងផែនការដំបូង

(ខ) លំហូរសាច់ប្រាក់សុទ្ធជាក់ស្តែង ឬចំណេញពីប្រតិបត្តិការ ឬការខាតពីទ្រព្យសកម្មដែលអាក្រក់ខ្លាំងជាងគម្រោងផែនការ

(គ) ការធ្លាក់ចុះខ្លាំងក្នុងគម្រោងផែនការលំហូរសាច់ប្រាក់សុទ្ធ ឬចំណេញពីប្រតិបត្តិការ ឬការឡើងខ្លាំងក្នុងគម្រោងផែនការខាតបង់ បណ្តាលមកពីទ្រព្យសកម្ម ឬ

(ឃ) ការខាតពីប្រតិបត្តិការ ឬលំហូរសាច់ប្រាក់ចេញសុទ្ធ សម្រាប់ទ្រព្យសកម្ម នៅគ្រាបច្ចុប្បន្នតម្លៃសរុបជាមួយតម្លៃគម្រោងផែនការសម្រាប់អនាគត។

១៥ ដូចបានបង្ហាញក្នុងកថាខណ្ឌទី ១០ ស្តង់ដានេះតម្រូវឱ្យទ្រព្យសកម្មអរូបីយមួយដែលមានអាយុកាលប្រើប្រាស់មិនមានកាលកំណត់ ឬមិនទាន់រួចរាល់សម្រាប់ប្រើប្រាស់ និងមូលនិធិពាណិជ្ជកម្ម ត្រូវបានធ្វើតេស្តការធ្លាក់ចុះនៃតម្លៃយ៉ាងហោចណាស់ប្រចាំឆ្នាំ។ មួយផ្នែកផ្សេងពីការអនុវត្តលក្ខខណ្ឌតម្រូវក្នុងកថាខណ្ឌទី ១០ ទស្សនៈសារវន្តអនុវត្តក្នុងការកំណត់ពីតម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មមួយ ត្រូវធ្វើបានប៉ាន់ស្មាន។ ជាឧទាហរណ៍ ប្រសិនបើ ការគណនាមុនបង្ហាញថាតម្លៃអាចទទួលបានមកវិញរបស់ទ្រព្យសកម្មមួយខ្ពស់ជាងខ្លាំងតម្លៃក្នុងបញ្ជី អង្គភាពមិនចាំបាច់ប៉ាន់ស្មានជាថ្មីនូវ

តម្លៃអាចទទួលបានមកវិញ ប្រសិនមិនមានព្រឹត្តិការណ៍កើតឡើងដែលដក ចេញនូវភាពខុសគ្នា។ ប្រហាក់ប្រហែលគ្នានេះដែរ ការវិភាគមុនអាចបង្ហាញ ថាតម្លៃអាចទទួលបានមកវិញរបស់ទ្រព្យសកម្មមួយ មិនរំលោចនឹងសញ្ញា មួយ ឬច្រើន ដូចមានរាយក្នុងកថាខណ្ឌទី ១២។

១៦ ដូចបង្ហាញនៃកថាខណ្ឌទី ១៥ ប្រសិនអត្រាការប្រាក់ទីផ្សារ ឬអត្រាទីផ្សារ នៃចំណូលលើការវិនិយោគផ្សេងទៀត បានកើនឡើងក្នុងកំឡុងគ្រាអង្គភាព មួយមិនតម្រូវឱ្យធ្វើការប៉ាន់ស្មានជាផ្លូវការ នៃតម្លៃអាចទទួលបានមកវិញ របស់ទ្រព្យសកម្ម ក្នុងករណីដូចខាងក្រោម÷

(ក) ប្រសិនបើអត្រាអប្បហារប្រើក្នុងការគណនាតម្លៃកំពុងប្រើប្រាស់របស់ ទ្រព្យសកម្ម ទំនងប៉ះពាល់ដោយសារការកើនឡើងនៃអត្រាទីផ្សារ។ ជាឧទាហរណ៍ ការកើនឡើងអត្រាការប្រាក់រយៈពេលខ្លីអាចមិនប៉ះ ពាល់ជាសារវន្តលើអត្រាអប្បហារ ប្រើសម្រាប់ទ្រព្យសកម្មដែលនៅ សល់អាយុកាលប្រើប្រាស់វែង។

(ខ) ប្រសិនអត្រាអប្បហារ ប្រើក្នុងការគណនាក្នុងការគណនាតម្លៃកំពុង ប្រើប្រាស់របស់ទ្រព្យសកម្ម ទំនងជាប៉ះពាល់ដោយការកើនឡើងនៃ អត្រាទីផ្សារ ប៉ុន្តែការវិភាគការរំលោចមុននៃតម្លៃអាចទទួលបានមក វិញបង្ហាញថា÷

(១) ទំនងមិនមានការថយចុះជាសារវន្ត ក្នុងតម្លៃអាចទទួលបាន មកវិញ ព្រោះថាលំហូរសាច់ប្រាក់អនាគតអាចនឹងកើនឡើង (ឧទាហរណ៍ ក្នុងករណីខ្លះ អង្គភាពមួយអាចបង្ហាញកែតម្រូវ ចំណូលដើម្បីទូទាត់ សម្រាប់ការកើនឡើងអត្រាទីផ្សារ) ឬ

(២) ការថយចុះតម្លៃអាចទទួលបានមកវិញ ទំនងមិនមានការខាត ពីការធ្លាក់ចុះតម្លៃជាសារវន្ត។

១៧ ប្រសិនបើ មានសញ្ញាបង្ហាញថាទ្រព្យសកម្មមួយ ត្រូវបានធ្លាក់ចុះតម្លៃ នេះអាចបញ្ជាក់ថាអាយុកាលប្រើប្រាស់នៅសល់ វិធីសាស្ត្ររំលស់ ឬតម្លៃសំណល់សម្រាប់ទ្រព្យសកម្មត្រូវធ្វើការត្រួពិនិត្យ និងកែតម្រូវ ស្របតាមស្តង់ដាដែលពាក់ព័ន្ធចំពោះទ្រព្យសកម្ម ទោះបីជាគ្មានការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មក៏ដោយ។

## ការវាស់វែងតម្លៃអាចទទួលបានមកវិញ

១៨ ស្តង់ដានេះកំណត់តម្លៃអាចទទួលបានមកវិញខ្ពស់ជាង តម្លៃសមស្របដកថ្លៃដើម្បីលក់ និងតម្លៃកំពុង ប្រើប្រាស់របស់ទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់។ កថាខណ្ឌទី ១៩-៥៧ កំណត់លក្ខខណ្ឌសម្រាប់វាស់វែងតម្លៃអាចទទួលបានមកវិញ។ លក្ខខណ្ឌទាំងនេះប្រើប្រាស់ពាក្យ (ទ្រព្យសកម្ម) ប៉ុន្តែអនុវត្តដូចគ្នាទៅនឹងទ្រព្យសកម្មនីមួយៗ ឬអង្គភាពរកសាច់ប្រាក់។

១៩ គ្រប់ពេលមិនចាំបាច់ត្រូវកំណត់ទាំងតម្លៃសមស្របដកថ្លៃដើម្បីលក់ និងតម្លៃកំពុងប្រើប្រាស់ទេ។ ប្រសិនបើ តម្លៃទាំងពីរលើសពីតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្ម ទ្រព្យសកម្មមិនត្រូវបានធ្លាក់ចុះតម្លៃ ហើយក៏មិនចាំបាច់ធ្វើការប៉ាន់ស្មានតម្លៃផ្សេងទៀតទេ។

២០ អាចធ្វើការត្រូវកំណត់ពីតម្លៃសមស្របដកថ្លៃដើម្បីលក់បើទោះបីទ្រព្យសកម្មមួយមិនត្រូវដាក់លក់ក្នុងទីផ្សារសកម្ម។ ប៉ុន្តែ ពេលខ្លះមិនអាចកំណត់តម្លៃសមស្របដកថ្លៃដើម្បីលក់ ព្រោះថាគ្មានមូលដ្ឋានប៉ាន់ស្មានតម្លៃ ដែលអាច

ជឿជាក់បានពីការលក់ទ្រព្យសកម្ម ក្នុងប្រតិបត្តិការបណ្តោយដៃរវាងបុគ្គលដែលមានចំណេះដឹង។ ក្នុងករណីនេះ អង្គភាពអាចប្រើប្រាស់តម្លៃកំពុងជាតម្លៃអាចទទួលបានមកវិញ។

២១ បើគ្មានមូលហេតុជឿជាក់ថា តម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្មជាសារវន្តលើសពីតម្លៃសមស្របដកថ្លៃដើម្បីលក់ តម្លៃសមស្របដកថ្លៃដើម្បីលក់របស់ទ្រព្យសកម្មអាចត្រូវបានប្រើជាតម្លៃអាចទទួលបានមកវិញ។នេះជាករណីញឹកញាប់សម្រាប់ទ្រព្យសកម្មមួយដែលទុកសម្រាប់លក់។ នេះព្រោះថាតម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្មមួយទុកសម្រាប់លក់នឹងមានពីចំណូលពីការលក់ទ្រព្យសកម្មសុទ្ធ ដែលលំហូរសាច់ប្រាក់បានមកពីការបន្តការប្រើប្រាស់ទ្រព្យសកម្មរហូតដល់ពេលលក់អាចនឹងមិនធំដុំ។

២២ តម្លៃអាចទទួលបានមកវិញត្រូវបានកំណត់សម្រាប់ទ្រព្យសកម្មនីមួយៗ លើកលែងតែទ្រព្យសកម្មមិនអាចទទួលបានលំហូរសាច់ប្រាក់ចូលដែលពឹងផ្អែកខ្លាំងលើទ្រព្យសកម្មផ្សេងទៀត ឬក្រុមនៃទ្រព្យសកម្ម។ ក្នុងករណីនេះតម្លៃអាចទទួលបានមកវិញត្រូវបានកំណត់សម្រាប់អង្គភាពរកសាច់ប្រាក់ដែលទ្រព្យសកម្មនោះស្ថិតនៅ (សូមមើលកថាខណ្ឌទី ៦៥-១០៣) លើកលែងតែ÷

(ក) តម្លៃសមស្របរបស់ទ្រព្យសកម្មដកថ្លៃដើម្បីលក់ខ្ពស់ជាង តម្លៃក្នុងបញ្ជី ឬ

(ខ) តម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្មអាចត្រូវបានប៉ាន់ស្មាន ប្រហាក់ប្រហែលទៅនឹងតម្លៃសមស្របដកថ្លៃដើម្បីលក់ ហើយតម្លៃសមស្របដកថ្លៃ ដើម្បីលក់ត្រូវបានកំណត់។

២៣ ក្នុងករណីខ្លះ ការប៉ាន់ស្មានជាមធ្យម និងការគណនាខ្លីអាចផ្តល់ហេតុផលសមស្របនៃការគណនាបង្ហាញលម្អិតក្នុងស្តង់ដានេះសម្រាប់កំណត់តម្លៃសមស្របដកថ្លៃដើម្បីលក់ ឬតម្លៃកំពុងប្រើប្រាស់។

## ការវាស់វែងតម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មអរូបីយមួយជាមួយនឹងអាយុកាលប្រើប្រាស់មិនកំណត់

២៤ កថាខណ្ឌទី ១០ តម្រូវឱ្យទ្រព្យសកម្មអរូបីយមួយជាមួយនឹងអាយុកាលប្រើប្រាស់មិនកំណត់ត្រូវបាន ធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃប្រចាំឆ្នាំ ដោយធ្វើការប្រៀបធៀបរវាងតម្លៃ ក្នុងបញ្ជីជាមួយនឹងតម្លៃអាចទទួលបានមកវិញ ដោយមិនពាក់ព័ន្ធទៅនឹងសញ្ញាណាមួយដែលថាអាចត្រូវបានធ្លាក់ចុះតម្លៃ។ ប៉ុន្តែ ការគណនាលម្អិតថ្មីៗ នៃតម្លៃអាចទទួលបានមកវិញរបស់ទ្រព្យសកម្មក្នុងគ្រាមុន អាចត្រូវបានប្រើធ្វើតេស្តការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មក្នុងគ្រាបច្ចុប្បន្ន ដោយគោរពបាននូវលក្ខណៈវិនិច្ឆ័យដូចខាងក្រោម÷

(ក) ប្រសិនបើ ទ្រព្យសកម្មអរូបីយមិនអាចទទួលបានលំហូរសាច់ប្រាក់ចូលពីប្រតិបត្តិការបន្តដែលមានឯករាជ្យភាពច្រើនពីទ្រព្យសកម្មដទៃទៀត ឬក្រុមនៃទ្រព្យសកម្ម ដូចនេះ ការសាកល្បងសម្រាប់ការធ្លាក់ចុះនៃតម្លៃគឺជាផ្នែកមួយនៃអង្គភាពរកសាច់ប្រាក់ដែលទ្រព្យសកម្មនោះស្ថិតនៅទ្រព្យសកម្ម និងបំណុលនឹងបង្កើតឡើងរហូតដល់មិនមានការផ្លាស់ប្តូរសំខាន់ៗតាំងការគណនាតម្លៃអាចទទួលបានមកវិញថ្មីបំផុត។

(ខ) ការគណនាតម្លៃអាចទទួលបានមកវិញថ្មីបំផុតជាលទ្ធផល គឺជាតម្លៃមួយដែលលើសពីតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្មដោយមានគំលាតខ្ពស់ហើយ

(គ) ផ្អែកលើមូលដ្ឋានវិភាគ នៃប្រតិបត្តិការ ដែលបានកើតឡើង និងស្ថានភាព ដែលបានផ្លាស់ប្តូរចាប់តាំង ពីការការគណនាតម្លៃអាចទទួលបានមកវិញថ្មីបំផុត ទំនងការកំណត់តម្លៃអាចទទួលបានមកវិញបច្ចុប្បន្នអាចទាបជាងឆ្ងាយពីតម្លៃក្នុងបញ្ជី។

## តម្លៃសមស្របដកថ្លៃដើម្បីលក់

២៥ ភស្តុតាងដ៏ល្អបំផុតនៃតម្លៃសមស្របដកថ្លៃដើម្បីលក់របស់ទ្រព្យសកម្ម គឺជាថ្លៃក្នុងកិច្ចសន្យាលក់ ក្នុងប្រតិបត្តិការបណ្តោយដៃ កែតម្រូវចំណាយបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងលក់ទ្រព្យសកម្ម។

២៦ ប្រសិនបើមិនមានក្នុងកិច្ចសន្យាលក់ ប៉ុន្តែមានទ្រព្យសកម្មមួយ ត្រូវបានលក់ក្នុងទីផ្សារសកម្ម តម្លៃសមស្រប ដកថ្លៃដើម្បីលក់ គឺជាតម្លៃទីផ្សារដកចំណាយលក់។ តម្លៃទីផ្សារដ៏សមស្របជាទូទៅគឺជាថ្លៃទិញបច្ចុប្បន្ន។ នៅពេលថ្លៃទិញបច្ចុប្បន្នមិនអាចរកបាន ថ្លៃប្រតិបត្តិការថ្មីបំផុតអាចផ្តល់ជាមូលដ្ឋានក្នុងការប៉ាន់ស្មានតម្លៃសមស្របដកថ្លៃដើម្បីលក់ ដែលបង្ហាញថាមិនមានការប្រែប្រួលស្ថានភាពសេដ្ឋកិច្ចរវាងថ្ងៃប្រតិបត្តិការនិងថ្ងៃដែលធ្វើការប៉ាន់ស្មាន។

២៧ ប្រសិនបើមិនមានកិច្ចសន្យាលក់ ឬទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មមួយតម្លៃសមស្របដកថ្លៃដើម្បីលក់

គឺផ្អែកលើព័ត៌មានដ៏ល្អដែលឆ្លុះបញ្ចាំងពីតម្លៃដែលអង្គភាពមួយអាចទទួលបាន នៅចុងគ្រារាយការណ៍ ពីប្រតិបត្តិការបណ្តោយដៃរវាងភាគីដែលមានចំណេះដឹង បន្ទាប់ពីដកចំណាយលក់។ ក្នុងការកំណត់តម្លៃនេះ អង្គភាពមួយពិចារណាលលទ្ធផលនៃប្រតិបត្តិការថ្មីៗសម្រាប់ទ្រព្យសកម្មប្រហាក់ប្រហែលគ្នាក្នុងវិស័យដូចគ្នា។ តម្លៃសមស្របដកថ្លៃដើម្បីលក់ មិនឆ្លុះបញ្ចាំងពីការលក់បង្ខំ លើកលែងតែអ្នកគ្រប់គ្រងតម្រូវឱ្យលក់ភ្លាម។

២៨ ចំណាយនៃការលក់ ដែលមិនមែនជាអ្វី ដែលបានទទួលស្គាល់ជាបំណុលត្រូវបានដកចេញពីការកំណត់តម្លៃសមស្របដកថ្លៃដើម្បីលក់។ ឧទាហរណ៍ចំណាយ ដែលជាការចំណាយផ្នែកច្បាប់ ប្រថាប់ត្រានិងប្រតិបត្តិការពន្ធប្រហាក់ប្រហែល ចំណាយរំកិលទ្រព្យសកម្ម និងចំណាយបន្ថែម ក្នុងការទទួលបានទ្រព្យសកម្ម ក្នុងលក្ខខណ្ឌសម្រាប់ការលក់។ ប៉ុន្តែ បញ្ញប់អត្ថប្រយោជន៍ (ដូចមានកំណត់ក្នុង ស.គ.អ.ក ១៩) និងចំណាយពាក់ព័ន្ធជាមួយការកាត់បន្ថយ ឬរះរើរអាជីវកម្មបណ្តាលមកពីការលក់ទ្រព្យសកម្មមួយ មិនចាត់ទុកថាជាចំណាយបន្ថែមសម្រាប់ការលក់ទ្រព្យសកម្មឡើយ។

២៩ ពេលខ្លះ ការលក់ទ្រព្យសកម្មអាចតម្រូវឱ្យអ្នកទិញចាត់ទុកជាបំណុល ហើយមានតែតម្លៃសមស្រប សម្រាប់ទ្រព្យសកម្មដកថ្លៃដើម្បីលក់តែមួយដែលមានសម្រាប់ទាំងទ្រព្យសកម្ម និងបំណុល។ កថាខណ្ឌទី ៧៨ ពន្យល់ពីររបៀបដោះស្រាយករណីទាំងនេះ។

## តម្លៃកំពុងប្រើប្រាស់

៣០ ធាតុខាងក្រោម ត្រូវបានប្រើសម្រាប់គណនាតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្មមួយ÷

(ក) ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតដែលអង្គភាពមួយរំពឹងថានឹងទទួលបានពីទ្រព្យសកម្ម

(ខ) ការរំពឹងទុកពីការប្រែប្រួលជាទឹកប្រាក់ ឬពេលវេលានៃលំហូរសាច់ប្រាក់អនាគត

(គ) តម្លៃពេលវេលានៃប្រាក់ បានបង្ហាញដោយអត្រាការប្រាក់ទីផ្សារបច្ចុប្បន្នគ្មានហានិភ័យ

(ឃ) ថ្លៃដែលកើតឡើងពីភាពមិនប្រាកដប្រជានៃទ្រព្យសកម្ម និង

(ង) កត្តាផ្សេងៗ ដូចជាភាពមិនអាចប្តូរជាសាច់ប្រាក់ ដែលអ្នកចូលរួមក្នុងទីផ្សារអាចឆ្លុះបញ្ចាំងពីថ្លៃនៃលំហូរសាច់ប្រាក់អនាគត ដែលអង្គភាពរំពឹងទទួលបានពីទ្រព្យសកម្ម។

៣១ ការប៉ាន់ស្មានតម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្មមួយ រួមមានដំណាក់កាលដូចខាងក្រោម÷

(ក) ការប៉ាន់ស្មានពីលំហូរសាច់ប្រាក់ចូលអនាគត និងលំហូរសាច់ប្រាប់ចេញអនាគត ដែលត្រូវទទួលបានពីប្រតិបត្តិការបន្តនៃការប្រើប្រាស់ទ្រព្យសកម្ម និងពីការលក់ចុងក្រោយ និង

(ខ) ការប្រើអត្រាអប្បហារសមស្របទៅលើលំហូរសាច់ប្រាក់អនាគត។

៣២ ធាតុបានកំណត់ក្នុងកថាខណ្ឌទី ៣០ (ក) និង (ឃ) និង (ង) អាចត្រូវបានឆ្លុះបញ្ចាំងទាំងការកែតម្រូវទៅលើលំហូរសាច់ប្រាក់អនាគត ឬការកែតម្រូវលើអត្រាអប្បហារ។ ទោះបីអង្គភាពមួយអនុវត្តវិធីណាក៏ដោយ ដើម្បីឆ្លុះបញ្ចាំងការរំពឹងទុកពីការប្រែប្រួលជាទឹកប្រាក់ ឬពេលវេលានៃលំហូរសាច់ប្រាក់អនាគត ជាលទ្ធផលត្រូវបានឆ្លុះបញ្ចាំងតម្លៃបច្ចុប្បន្នរំពឹងទុកនៃលំហូរសាច់ប្រាក់អនាគត ឧទាហរណ៍ ទិងន់មធ្យមដែលភ្ជូវនីយភាពនៃលទ្ធភាពដែលអាចកើតមានទាំងអស់។ ឧបសម្ព័ន្ធ ក ផ្តល់ការណែនាំបន្ថែមលើការប្រើប្រាស់បច្ចេកទេសតម្លៃបច្ចុប្បន្ន ក្នុងការវាស់វែងតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្មមួយ។

**មូលដ្ឋានសម្រាប់ប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត**

៣៣ **ការវាស់វែងតម្លៃកំពុងប្រើប្រាស់ អង្គភាពមួយត្រូវ÷**

(ក) ផ្អែកលើការព្យាករណ៍លំហូរសាច់ប្រាក់ដោយប្រើការសន្មតសមស្របនិងអាចទទួលយកបាន ដែលជាការប៉ាន់ស្មានដ៏ល្អរបស់អ្នកគ្រប់គ្រងលើគ្រប់លក្ខខណ្ឌសេដ្ឋកិច្ចដែលនឹងកើតមានលើអាយុកាលប្រើប្រាស់នៅសល់នៃទ្រព្យសកម្ម។ ទិងន់ខ្ពស់ជាងត្រូវយោងទៅលើភស្តុតាងខាងក្រៅ។

(ខ) ផ្អែកលើការព្យាករណ៍លំហូរសាច់ប្រាក់ដែលបានមកគម្រោងផែនការហិរញ្ញវត្ថុ/ការព្យាករណ៍ហិរញ្ញវត្ថុ បានអនុម័តដោយអ្នកគ្រប់គ្រង ប៉ុន្តែមិនត្រូវបញ្ចូលការប៉ាន់ស្មានលំហូរសាច់ប្រាក់ចូល អនាគត ឬលំហូរសាច់ប្រាក់ចេញអនាគតរំពឹងកើតឡើងពីការរុះរើអនាគត

ឬពីការធ្វើឱ្យប្រសើរ ឬបង្កើនស្នាដៃរបស់ទ្រព្យសកម្ម។ ការព្យាករណ៍លើថវិកា/ការព្យាករណ៍ត្រូវគ្របដណ្តប់ យ៉ាងច្រើនបំផុតគឺប្រាំឆ្នាំ លើកលែងតែមានការកែសម្រួលគ្រាច្រើនជាងនេះ។

(គ) ការប៉ាន់ស្មានលំហូរសាច់ប្រាក់ព្យាករណ៍ក្រោយគ្រាគ្របដណ្តប់ ដោយគម្រោងថវិកា/ព្យាករណ៍ថ្មីៗបំផុត ដោយសរុបការព្យាករណ៍ ផ្អែកលើគម្រោងថវិកា /ការព្យាករណ៍ដោយប្រើប្រាស់អត្រាកំណើនថេរ ឬអត្រាកំណើនថយចុះសម្រាប់ឆ្នាំបន្ទាប់ លើកតែមានការកែសម្រួលអត្រាកំណើន។ អត្រាកំណើននេះមិនត្រូវលើសអត្រាកំណើនមធ្យមរយៈពេលវែងសម្រាប់ផលិតផលវិស័យ ឬប្រទេសមួយ ឬប្រទេសច្រើនដែលអង្គភាពធ្វើប្រតិបត្តិការ ឬសម្រាប់ទីផ្សារដែលទ្រព្យសកម្មត្រូវបានប្រើប្រាស់ លើកលែងតែអត្រាខ្ពស់មានការកែតម្រូវ។

៣៤ អ្នកគ្រប់គ្រងវាយតម្លៃការសន្មតសមស្របដែលត្រូវបានប្រើជាមូលដ្ឋាន ក្នុងការព្យាករណ៍លំហូរសាច់ប្រាក់បច្ចុប្បន្ន ដោយការពិនិត្យពីភាពខុសគ្នារវាងការព្យាករណ៍លំហូរសាច់ប្រាក់អតីតកាល និងលំហូរសាច់ប្រាក់ជាក់ស្តែង។ អ្នកគ្រប់គ្រងត្រូវប្រាដកថាការសន្មតដែលត្រូវបានប្រើជាមូលដ្ឋាន ក្នុងការព្យាករណ៍លំហូរសាច់បច្ចុប្បន្នមាននិរន្តភាពជាមួយ លទ្ធផលអតីតកាលជាក់ស្តែង ផ្តល់ផលប៉ះពាល់ព្រឹត្តិការណ៍បន្ទាប់ ឬស្ថានភាពដែលមិនបានកើតឡើងនៅពេលលំហូរសាច់ប្រាក់ជាក់ស្តែងត្រូវបានទទួល។

៣៥ លម្អិតជាក់ស្តែង និងអាចជឿជាក់បាននៃគម្រោងថវិកា/ការព្យាករណ៍លំហូរសាច់ប្រាក់អនាគតសម្រាប់គ្រាវែងជាងប្រាំឆ្នាំ ជាទូទៅមិនអាចរកបាននោះទេ។ សម្រាប់ហេតុផលនេះ ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់អនាគតរបស់

អ្នកគ្រប់គ្រង គឺផ្អែកលើគម្រោងថវិកា/ការព្យាករណ៍ថ្មីបំផុត សម្រាប់រយៈពេលអតិបរមាប្រាំឆ្នាំថ្មីបំផុត។ អ្នកគ្រប់គ្រងអាចប្រើប្រាស់លំហូរសាច់ប្រាក់ព្យាករណ៍ផ្អែកលើគម្រោងថវិកា/ការព្យាករណ៍ ច្រើនជាងរយៈពេលប្រាំឆ្នាំ ប្រសិនបើមានភាពជឿជាក់ថាការព្យាករណ៍ គឺអាចជឿជាក់បាន ហើយបង្ហាញសមត្ថភាព ដោយផ្អែកលើបទពិសោធន៍អតីតកាល ទៅលើលំហូរសាច់ប្រាក់ព្យាករណ៍ត្រឹមត្រូវលើរយៈពេលវែង។

៣៦ លំហូរសាច់ប្រាក់ព្យាករណ៍ រហូតដល់បញ្ចប់អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានប៉ាន់ស្មានសរុប លំហូរសាច់ប្រាក់ព្យាករណ៍ផ្អែកគម្រោងថវិកា/ការព្យាករណ៍ដោយប្រើអត្រាកំណើនសម្រាប់ឆ្នាំបន្ទាប់។ អត្រានេះថេរ ឬថយចុះ លើកលែងតែការកើនឡើងនៃអត្រាស៊ីគ្នាទៅនឹងគោលបំណងព័ត៌មាន ពីទំលាប់នោរលើផលិតផល ឬខួបជីវិតនៃវិស័យ។ សមស្របប្រសិនបើអត្រាកំណើនស្មើសូន្យ ឬអវិជ្ជមាន។

៣៧ នៅពេលលក្ខខណ្ឌល្អ គូរប្រគួតប្រជែងទំនងចូលក្នុងទីផ្សារ ហើយកំហិតកំណើន។ ដូចនេះ អង្គភាពនឹងប្រឈមផលវិបាកក្នុងការទទួលបានអត្រាកំណើនលើសពីអត្រាកំណើនប្រវត្តិសាស្ត្រជាមធ្យមរយៈពេលវែង (ឧទាហរណ៍ ១២ ឆ្នាំ) សម្រាប់ផលិតផលវិស័យ ឬប្រទេសមួយ ឬប្រទេសច្រើនដែលអង្គភាពធ្វើប្រតិបត្តិការ ឬសម្រាប់ទីផ្សារដែលទ្រព្យសកម្មប្រើប្រាស់។

៣៨ ក្នុងការប្រើប្រាស់ព័ត៌មានបានពីការគម្រោងថវិកា/ការព្យាករណ៍ អង្គភាពមួយពិចារណាពីព័ត៌មានឆ្លុះបញ្ចាំងការសន្មតសមស្រប និងអាចទទួលយកបាននិងបង្ហាញពីការប៉ាន់ស្មានល្អបំផុតរបស់អ្នកគ្រប់គ្រង គ្រប់លក្ខខណ្ឌ

សេដ្ឋកិច្ច ដែលនឹងកើតមានលើអាយុកាលប្រើប្រាស់ នៅសល់របស់ទ្រព្យសកម្ម។

**សមាសធាតុនៃការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត**

៣៩ ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតត្រូវបញ្ចូល÷

(ក) ការព្យាករណ៍លំហូរសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ទ្រព្យសកម្ម

(ខ) ការព្យាករណ៍លំហូរសាច់ប្រាក់ចេញ ដែលចាំបាច់កើតឡើង ដើម្បីទទួលបានលំហូរសាច់ប្រាក់ចូលពីការបន្តការប្រើប្រាស់ទ្រព្យសកម្ម (រាប់បញ្ចូលលំហូរសាច់ប្រាក់ចេញដើម្បីរៀបចំទ្រព្យសកម្ម សម្រាប់ប្រើប្រាស់)និងអាចត្រូវបានបែងចែកដោយផ្ទាល់ ឬអាចត្រូវបានបែងចែកលើមូលដ្ឋានសមស្រប និងនិរន្ត ភាពទៅលើទ្រព្យសកម្ម និង

(គ) លំហូរសាច់ប្រាក់សុទ្ធ ប្រសិនបើ ត្រូវបានទទួលបាន (ឬចំណាយ) សម្រាប់ការលក់នៃទ្រព្យសកម្មនៅចុងគ្រាអាយុកាលប្រើប្រាស់។

៤០ ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត និងអត្រាអប្បហារឆ្លុះបញ្ចាំងពីនិរន្តភាពការសន្មតពីថ្លៃកើនឡើង ដែលចូលរួមទៅហានិភ័យទូទៅ។ ដូចនេះ ប្រសិនបើអត្រាអប្បហាររួមបញ្ចូលការប៉ះពាល់ នៃការកើនឡើងថ្លៃចូលរួមទៅហានិភ័យទូទៅ លំហូរសាច់ប្រាក់អនាគត ត្រូវបានប៉ាន់ស្មានក្នុងថ្លៃធម្មតា។ ប្រសិនបើអត្រាអប្បហារមិនរួមបញ្ចូលការប៉ះពាល់នៃការកើនឡើងថ្លៃចូលរួមទៅហានិភ័យទូទៅលំហូរសាច់ប្រាក់អនាគត ត្រូវបានប៉ាន់ស្មានក្នុងថ្លៃពិត (ប៉ុន្តែរួមបញ្ចូល ថ្លៃកើនឡើង ឬថយចុះ អនាគតជាក់លាក់)។

៤១ ការព្យាករណ៍នៃលំហូរសាច់ប្រាក់ចេញរួមបញ្ចូលអ្វីដែលពាក់ព័ន្ធសេវាកម្មប្រចាំថ្ងៃនៃទ្រព្យសកម្ម ក៏ដូចជា ចំណាយបន្ទាប់បន្សំអនាគត ដែលអាចត្រូវបានចូលរួមដោយផ្ទាល់ ឬត្រូវបានបែងចែកលើមូលដ្ឋានសមស្រប និងនិរន្តភាពទៅលើការប្រើប្រាស់ទ្រព្យសកម្ម។

៤២ នៅពេលតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មមិនទាន់បញ្ចូលលំហូរសាច់ប្រាក់ចេញដែលត្រូវបានកើតឡើងមុនពេលរួចរាល់សម្រាប់ប្រើប្រាស់ ឬលក់ការប៉ាន់ស្មានលំហូរសាច់ប្រាក់ចេញអនាគត រាប់បញ្ចូលការប៉ាន់ស្មាន នៃលំហូរសាច់ប្រាក់ចេញអនាគតដែលរំពឹងថាត្រូវកើតឡើងមុនពេលទ្រព្យសកម្មរួចរាល់សម្រាប់ប្រើប្រាស់ ឬលក់។ ជាឧទាហរណ៍ នេះជាករណីសម្រាប់អគារស្ថិតនៅក្រោមការសាងសង់ ឬសម្រាប់អភិវឌ្ឍន៍គម្រោងដែលមិនទាន់បញ្ចប់នៅឡើយ។

៤៣ ដើម្បីជៀសវាងការរាប់ស្ទួន ការព្យាករណ៍លំហូរសាច់ប្រាក់អនាគត មិនបញ្ចូល÷

(ក) លំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មដែលទទួលបានលំហូរសាច់ប្រាក់ចូលដែលផ្អែកស្មើរតែទាំងស្រុង នៃលំហូរសាច់ប្រាក់ចូលបានមកពីទ្រព្យសកម្មក្រោមការពិនិត្យ (ឧទាហរណ៍ទ្រព្យសកម្មហិរញ្ញវត្ថុដូចជាការគណនីត្រូវទទួល) និង

(ខ) លំហូរសាច់ប្រាក់ចេញ ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចដែលត្រូវទទួលស្គាល់ជាបំណុល (ឧទាហរណ៍ គណនីដែលត្រូវបង់ សោធននិវត្តន៍ ឬសំវិធានធន)។

៤៤. **លំហូរសាច់ប្រាក់អនាគតត្រូវបានប៉ាន់ស្មានសម្រាប់ទ្រព្យសកម្មនៅក្នុងលក្ខខណ្ឌបច្ចុប្បន្ន។ ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់មិនត្រូវរាប់បញ្ចូលការប៉ាន់ស្មានលំហូរសាច់ប្រាក់ចូលអនាគត ឬលំហូរសាច់ប្រាក់ចេញអនាគតដែលរំពឹងថាកើតចេញពី÷**

(ក) **ការរុះរើនាពេលអនាគតដែលអង្គភាពមួយមិនទាន់មានការតាំងចិត្ត ឬ**

(ខ) **ការធ្វើឱ្យប្រសើរ ឬបង្កើនស្នាដៃរបស់ទ្រព្យសកម្ម។**

៤៥ ព្រោះលំហូរសាច់ប្រាក់អនាគត ត្រូវបានប៉ាន់ស្មានសម្រាប់ទ្រព្យសកម្មនៅក្នុងស្ថានភាពបច្ចុប្បន្ន តម្លៃកំពុងប្រើប្រាស់មិនឆ្លុះបញ្ចាំងពី÷

(ក) លំហូរសាច់ប្រាក់ចេញអនាគត ឬពាក់ព័ន្ធនឹងការសន្សំការចំណាយ (ឧទាហរណ៍ការកាត់បន្ថយចំណាយបុគ្គលិក) ឬអត្ថប្រយោជន៍ដែលត្រូវបានរំពឹងថាកើតឡើងពីការរុះរើពេលអនាគត ដែលអង្គភាពមួយមិនទាន់មានការតាំងចិត្ត ឬ

(ខ) លំហូរសាច់ប្រាក់ចេញអនាគត ដែលនឹងប្រសើរ ឬបង្កើនស្នាដៃរបស់ទ្រព្យសកម្ម ឬពាក់ព័ន្ធនឹងលំហូរសាច់ប្រាក់ចូល ដែលត្រូវបានរំពឹងថា កើតឡើងពីលំហូរចេញនោះ។

៤៦ ការុះរើគឺជាកម្មវិធីដែលត្រូវបានរៀបចំផែនការ និងត្រួតពិនិត្យ ដោយអ្នកគ្រប់គ្រង និងការផ្លាស់ប្តូរជាសារវន្ត ទាំងក្នុងវិសាលភាពការធ្វើអាជីវកម្មដោយអង្គភាពមួយឬក្នុងឥរិយាបទមួយដែលអង្គភាពមួយអនុវត្ត។ស.គ.អ.ក ៣៧ សំវិធានធន បំណុលជាយថាហេតុ និងទ្រព្យសកម្មជាយថាហេតុផ្តល់ការណែនាំការចាត់ថ្នាក់នៅពេលអង្គភាពមួយតាំងចិត្តក្នុងការរុះរើ។

៤៧ នៅពេលអង្គភាពមួយតាំងចិត្តក្នុងការរុះរើ ទ្រព្យសកម្មខ្លះអាចរងការត្រូវប៉ះពាល់ ដោយសារការរុះរើនេះ។ នៅពេលដែលអង្គភាពតាំងចិត្តក្នុងការរុះរើ÷

(ក) ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់ចូលអនាគត និងលំហូរសាច់ប្រាក់ចេញអនាគត សម្រាប់គោលបំណងក្នុងការកំណត់តម្លៃកំពុងប្រើប្រាស់ ឆ្លុះបញ្ចាំងការសន្សំសំចៃចំណាយ និងអត្ថប្រយោជន៍ផ្សេងៗ ដែលកើតមានឡើងពីការរុះរើ (ផ្អែកលើគម្រោងថវិកា/ការព្យាករណ៍ថ្មីៗបំផុត បានអនុម័តដោយអ្នកគ្រប់គ្រង) និង

(ខ) ការប៉ាន់ស្មានលំហូរសាច់ប្រាក់ចេញសម្រាប់ការរុះរើ ត្រូវបានបញ្ចូលក្នុងសំវិធានធនរុះរើស្របតាម ស.គ.អ.ក ៣៧។

ការបង្ហាញក្នុងឧទាហរណ៍៥បង្ហាញអំពីការប៉ះពាល់ការរុះរើនាពេលអនាគតលើការគណនាតម្លៃកំពុងប្រើប្រាស់។

៤៨ រហូតដល់អង្គភាពមួយកើតឡើងលំហូរសាច់ប្រាក់ចេញដែលធ្វើឱ្យប្រសើរឬបង្កើនស្នាដៃរបស់ទ្រព្យសកម្ម ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតមិនបញ្ចូលការប៉ាន់ស្មានលំហូរសាច់ប្រាក់ចូលអនាគត ដែលត្រូវបានរំពឹងថាកើតឡើងពីការកើនឡើងនូវអត្ថប្រយោជន៍សេដ្ឋកិច្ចពាក់ព័ន្ធនឹងលំហូរសាច់ប្រាក់ចេញ (មើលក្នុងឧទាហរណ៍បង្ហាញ ៦)។

៤៩ ការប៉ាន់ស្មានលំហូរសាច់អនាគតរួមទាំងលំហូរសាច់ប្រាក់ចេញអនាគតចាំបាច់រក្សាកម្រិតអត្ថប្រយោជន៍សេដ្ឋកិច្ចរំពឹងថាកើតឡើងពីទ្រព្យសកម្ម នៅក្នុងស្ថានភាពបច្ចុប្បន្ន ។ នៅពេលអង្គភាពរកសាច់ប្រាក់មានទ្រព្យសកម្មដែលមានអាយុកាលប្រើប្រាស់ខុសគ្នា ដែលទ្រព្យសកម្មទាំងអស់ចាំបាច់

ក្នុងការគាំទ្រការបន្តប្រតិបត្តិការទៅមុខរបស់អង្គភាព ការជំនួសនៃទ្រព្យសកម្មជាមួយនឹងអាយុកាលប្រើប្រាស់ខ្លីត្រូវបាន គិតថាជាផ្នែកក្នុងសេវាកម្មប្រចាំថ្ងៃរបស់អង្គភាព នៅពេលប៉ាន់ស្មានលំហូរសាច់អនាគត ជាមួយអង្គភាព។ ប្រហាក់ប្រហែលគ្នានេះដែរ នៅពេលទ្រព្យសកម្មមួយមានសមាសធាតុជាមួយការប៉ាន់ស្មានអាយុកាលប្រើប្រាស់ខុសគ្នា ការជំនួសនៃសមាសធាតុ ជាមួយអាយុកាលប្រើប្រាស់ខ្លីត្រូវបានគិតថាជាផ្នែកមួយនៃសេវាកម្មប្រចាំថ្ងៃ នៃទ្រព្យសកម្មនៅពេលប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតដែលទទួល បានពីទ្រព្យសកម្មនោះ។

៥០ **ការប៉ាន់ស្មានលំហូរសាច់ប្រាក់មិនបញ្ចូល÷**

(ក) **លំហូរសាច់ប្រាក់ចូល ឬលំហូរសាច់ប្រាក់ចេញបានមកសកម្មភាពហិរញ្ញវត្ថុ ឬ**

(ខ) **ពន្ធលើប្រាក់ចំណូលត្រូវទទួល ឬ ចំណាយ។**

៥១ ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត ឆ្លុះបញ្ចាំងការសន្មត ដែលមាននិរន្តភាពជាមួយការកំណត់អត្រាអប្បហារ។ ម្យ៉ាងទៀត ការប៉ះពាល់ការសន្មតនឹងត្រូវបានរាប់ពីរដង ឬមិនរាប់។ ព្រោះថាតម្លៃពេលវេលានៃលុយត្រូវបានគិតដោយអប្បហារការប៉ាន់ស្មាន លំហូរសាច់ប្រាក់អនាគតលំហូរសាច់ប្រាក់មិនបញ្ចូលលំហូរសាច់ប្រាក់ចូល ឬលំហូរសាច់ប្រាក់ចេញពីសកម្មភាពហិរញ្ញវត្ថុ។ ប្រហាក់ប្រហែលគ្នានេះដែរ ព្រោះអត្រាអប្បហារគឺត្រូវបានកំណត់លើមូលដ្ឋានមុនពេលបង់ពន្ធ លំហូរសាច់ប្រាក់អនាគតក៏ត្រូវបានប៉ាន់ស្មានលើមូលដ្ឋានមុនពេលបង់ពន្ធដែរ។

៥២ **ការប៉ាន់ស្មានលំហូរសាច់ប្រាក់សុទ្ធដែលត្រូវទទួល (ឬចំណាយ) សម្រាប់ការលក់ទ្រព្យសកម្មមួយនៅចុងអាយុកាលប្រើប្រាស់ ត្រូវតែជាតម្លៃមួយដែលអង្គភាពមួយរំពឹងថានឹងទទួលបានពីការលក់ទ្រព្យសកម្មនៃទ្រព្យសកម្មនោះក្នុងប្រតិបត្តិការបណ្តោយដៃរវាងភាគីដែលមានចំណេះ បន្ទាប់ពីដកចេញនូវការប៉ាន់ស្មានចំណាយការលក់។**

៥៣ ការប៉ាន់ស្មានលំហូរសាច់ប្រាក់សុទ្ធដែលត្រូវទទួល (ឬចំណាយ) សម្រាប់ការលក់ទ្រព្យសកម្មមួយនៅចុងអាយុកាលប្រើប្រាស់ ត្រូវបានកំណត់ក្នុងមធ្យោបាយស្រដៀងគ្នាទៅនឹងតម្លៃសមស្របដកថ្លៃ ដើម្បីលក់របស់ទ្រព្យសកម្មនូវចំណាយដើម្បីលក់ លើកលែងតែមានការប៉ាន់ស្មានលំហូរសាច់ប្រាក់សុទ្ធ÷

(ក) អង្គភាពមួយប្រើថ្លៃកំណត់ណាមួយនៅថ្ងៃប៉ាន់ស្មាន សម្រាប់ទ្រព្យសកម្មប្រហាក់ប្រហែលគ្នា ដែលបានដល់ចុងអាយុកាលប្រើប្រាស់ និងបានប្រតិបត្តិការ ក្រោមលក្ខខណ្ឌប្រហាក់ប្រហែល ទៅនឹងលក្ខខណ្ឌទ្រព្យសកម្មដែលត្រូវបានប្រើប្រាស់។

(ខ) អង្គភាព កែតម្រូវថ្លៃដែលប៉ះពាល់ទាំងការកើនឡើងតម្លៃ អនាគតបណ្តាលមកពីតិផរណាទូទៅ និងថ្លៃអនាគតកើនឡើង ឬថយចុះជាក់លាក់។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតកើតឡើងពីការបន្តការប្រើប្រាស់ទ្រព្យសកម្ម និងអត្រាអប្បហារ មិនរាប់បញ្ចូល ការប៉ះពាល់អតិផរណាទូទៅ អង្គភាពក៏មិនត្រូវរាប់បញ្ចូលការប៉ះពាល់ពីការប៉ាន់ ស្មានលំហូរសាច់ប្រាក់សុទ្ធលើការលក់ដែរ។

## លំហូរសាច់ប្រាក់អនាគតរូបិយប័ណ្ណបរទេស

៥៤ លំហូរសាច់ប្រាក់អនាគតត្រូវបានប៉ាន់ស្មានក្នុងរូបិយប័ណ្ណដែលនឹងត្រូវទទួលបានបន្ទាប់មកអប្បហារ ដោយប្រើអត្រាអប្បហារសមស្របទៅនឹងរូបិយប័ណ្ណនោះ។ អង្គភាពមួយបកប្រែតម្លៃបច្ចុប្បន្នដោយប្រើអត្រាប្តូរប្រាក់បច្ចុប្បន្ន នៅថ្ងៃគណនាតម្លៃកំពុងប្រើប្រាស់។

## អត្រាអប្បហារ

៥៥ **អត្រាអប្បហារ (អត្រា) ត្រូវតែជាអត្រាមុនពេលគិតពន្ធ (អត្រា) ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ន នៃ÷**

(ក) តម្លៃពេលវេលានៃលុយ និង

(ខ) ហានិភ័យជាក់លាក់ទៅលើទ្រព្យសកម្មសម្រាប់ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតដែលមិនទាន់ត្រូវបានកែតម្រូវ។

៥៦ អត្រាដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃលុយ និងហានិភ័យជាក់លាក់ទៅលើទ្រព្យសកម្មដែលជាផលប្រាក់ចំណេញដែលវិនិយោគិនចង់បាន ប្រសិនបើពួកគេសម្រេចចិត្តវិនិយោគទទួលបានតម្លៃនៃលំហូរសាច់ប្រាក់ ពេលវេលា និងហានិភ័យប្រហាក់ប្រហែលទៅនឹងអង្គភាពរំពឹងថានឹងទទួលបានពីទ្រព្យសកម្ម។អត្រាប៉ាន់ស្មាននេះបានមកពីអត្រាបង្កប់ក្នុងប្រតិបត្តិការទីផ្សារបច្ចុប្បន្នសម្រាប់ទ្រព្យសកម្មស្រដៀងគ្នា ឬថ្លៃដើមមូលធនមធ្យមនៃក្រុមហ៊ុនចុះបញ្ជីដែលមានទ្រព្យសកម្មតែមួយ (ឬចង្កោមនៃទ្រព្យសកម្ម) ប្រហាក់ប្រហែលទៅនឹងសេវាកម្មសក្តានុពល និងហានិភ័យទៅលើទ្រព្យសកម្មដែលស្ថិតនៅក្រោមការត្រួតពិនិត្យ។ ប៉ុន្តែ អត្រាអប្បហារ

បានប្រើក្នុងការវាស់វែងតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្មមួយត្រូវឆ្លុះបញ្ចាំងហានិភ័យសម្រាប់ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគតបានកែតម្រូវ។ ម្យ៉ាងវិញទៀត ការប៉ះពាល់ការសន្មត់ខ្លះនឹងត្រូវរាប់ស្ទួន។

៥៧ នៅពេលអត្រាទ្រព្យសកម្មមួយមិនអាចរកបានដោយផ្ទាល់ពីទីផ្សារ អង្គភាពមួយប្រើការជំនួស ក្នុងការប៉ាន់ស្មានអត្រាអប្បហារ។ ឧបសម្ព័ន្ធ ក ផ្តល់គោលការណ៍ណែនាំបន្ថែមពីលើការប៉ាន់ស្មានអត្រាអប្បហារក្នុងស្ថានភាពនោះ។

## ការទទួលស្គាល់ និងការវាស់វែងការខាតពីការធ្លាក់ចុះតម្លៃ

៥៨ កថាខណ្ឌទី ៥៩-៦៤កំណត់ពីលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ និងការវាស់វែងការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មនីមួយៗមិនមែនមូលនិធិពាណិជ្ជកម្ម។ ការទទួលស្គាល់ និងការវាស់វែងការខាតពីការធ្លាក់ចុះតម្លៃសម្រាប់អង្គភាពរកសាច់ប្រាក់ និងមូលនិធិពាណិជ្ជកម្ម ត្រូវអនុវត្ត តាមកថាខណ្ឌទី ៦៥-១០៨។

**៥៩ ប្រសិនបើ ហើយមានតែ តម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មមួយតិចជាងតម្លៃក្នុងបញ្ជី តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មត្រូវបានកាត់បន្ថយទៅតម្លៃអាចទទួលបានមកវិញ។ ការកាត់បន្ថយនេះគឺជាការខាត ពីការធ្លាក់ចុះតម្លៃ។**

**៦០ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ភ្លាមៗក្នុងចំណេញ ឬខាតលើកលែងតែទ្រព្យសកម្មត្រូវបានវាយតម្លៃឡើងវិញ ស្របតាមស្តង់ដាមួយផ្សេងទៀត (ឧទាហរណ៍ ស្របតាមគំរូការវាយតម្លៃឡើងវិញក្នុង**

**ស.គ.អ.ក ១៦)។ ការខាតពីការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្មបានវាយតម្លៃឡើងវិញត្រូវបានចាត់ទុកថាជាការថយចុះនៃវាយតម្លៃឡើងវិញស្របតាមស្តង់ដាផ្សេងទៀត។**

៦១ ការខាតពីការធ្លាក់ចុះតម្លៃលើទ្រព្យសកម្ម ដែលមិនបានវាយតម្លៃឡើងវិញត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។ ប៉ុន្តែ ការខាតពីការធ្លាក់ចុះតម្លៃលើទ្រព្យសកម្មដែលបានវាយតម្លៃឡើងវិញ ត្រូវបានទទួលស្គាល់ក្នុងចំណេញ លម្អិតក្នុងន័យថាការខាតពីការធ្លាក់ចុះតម្លៃមិនលើសពីតម្លៃវាយតម្លៃឡើងវិញលើសសម្រាប់ទ្រព្យសកម្មដូចគ្នា។ ការខាតពី ការធ្លាក់ចុះតម្លៃលើទ្រព្យសកម្មដែលបានវាយតម្លៃឡើងវិញកាត់បន្ថយតម្លៃ វាយតម្លៃឡើងវិញលើសសម្រាប់ទ្រព្យសកម្មនោះ។

**៦២ នៅពេលតម្លៃប៉ាន់ស្មានសម្រាប់ការខាតពីការធ្លាក់ចុះតម្លៃលើសពីតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មដែលទ្រព្យសកម្មនោះពាក់ព័ន្ធអង្គភាពមួយត្រូវទទួលស្គាល់ជាបំណុលប្រសិនបើ ហើយមាន តម្រូវដោយ ស្តង់ដាមួយផ្សេងទៀត។**

**៦៣ បន្ទាប់ពីទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃការរំលស់សម្រាប់ទ្រព្យសកម្មត្រូវបានកែតម្រូវក្នុងគ្រាអនាគតដោយបែងចែកទៅតម្លៃក្នុងបញ្ជីកែតម្រូវរបស់ទ្រព្យសកម្ម លើកលែងតែតម្លៃនៅសល់ (ប្រសិនបើមាន) លើមូលដ្ឋានជាប្រព័ន្ធលើអាយុកាលដែលនៅសល់។**

៦៤ ប្រសិនបើ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងទ្រព្យសកម្មពន្ធពន្យា ឬបំណុលដែលត្រូវបានកំណត់ស្របតាមស្តង់ដា ស.គ.អ.ក ១២ ដោយធ្វើការប្រៀបធៀបរវាងតម្លៃក្នុងបញ្ជីកែ តម្រូវនៃទ្រព្យសកម្មជាមួយនឹងមូលដ្ឋាននៃការគិតពន្ធ (សូមមើលការបង្ហាញក្នុងឧទាហរណ៍ ៣)។

៦៥ កថាខណ្ឌទី ៦៦-១០៨ និងឧបសម្ព័ន្ធ គ កំណត់លក្ខខណ្ឌសម្រាប់កំណត់អង្គភាពរកសាច់ប្រាក់ ដែលទ្រព្យសកម្មនោះស្ថិតនៅ និងកំណត់តម្លៃក្នុងបញ្ជី និងការទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ អង្គភាពស្វែងរកសាច់ប្រាក់ និងមូលនិធិពាណិជ្ជកម្ម។

## ការកំណត់អង្គភាពរកសាច់ប្រាក់ដែលទ្រព្យសកម្មស្ថិតនៅ

**៦៦ ប្រសិនបើ មានសញ្ញាថាទ្រព្យសកម្មមួយអាចត្រូវបានធ្លាក់ចុះនៃតម្លៃ តម្លៃអាចទទួលបាន ត្រូវបានប៉ាន់ស្មានសម្រាប់ទ្រព្យសកម្មនីមួយៗ។ ប្រសិនមិនអាចប៉ាន់ស្មានបានតម្លៃអាចទទួលបាននៃទ្រព្យសកម្មនីមួយៗ អង្គភាពមួយត្រូវកំណត់តម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ដែលទ្រព្យសកម្មស្ថិតនៅ (អង្គភាពរកសាច់ប្រាក់របស់ទ្រព្យសកម្ម)។**

៦៧ តម្លៃអាចទទួលបានមកវិញ នៃទ្រព្យសកម្មនីមួយៗ មិនអាចកំណត់បាន ប្រសិនបើ÷

(ក) តម្លៃកំពុងប្រើប្រាស់របស់ ទ្រព្យសកម្ម មិនអាចត្រូវប៉ាន់ស្មានបានប្រហាក់ប្រហែលទៅនឹងតម្លៃសមស្របរបស់ទ្រព្យសកម្មដកថ្លៃដើម្បីលក់ (ឧទាហរណ៍ នៅពេលលំហូរសាច់ប្រាក់អនាគតបានមកពីការបន្តការប្រើប្រាស់ទ្រព្យសកម្មមិនអាចប៉ាន់ស្មានបានជាតម្លៃមិនធំដុំ) និង

(ខ) ទ្រព្យសកម្ម មិនអាចទទួលបានលំហូរសាច់ប្រាក់ចូល ដែលមានឯករាជ្យភាពច្រើនពីទ្រព្យសកម្មផ្សេងទៀត។

ក្នុងករណីនេះ តម្លៃកំពុងប្រើប្រាស់ និងតម្លៃអាចទទួលបានមកវិញ អាចត្រូវបានកំណត់សម្រាប់តែអង្គភាពរកសាច់ប្រាក់របស់ទ្រព្យសកម្មតែប៉ុណ្ណោះ។

| ឧទាហរណ៍ |
| --- |
| ក្រុមហ៊ុនរុករករ៉ែមានកម្មសិទ្ធិផ្លូវដែកឯកជន ដើម្បីគាំទ្រដល់សកម្មភាពរុករករ៉ែ។ ផ្លូវដែកឯកជន អាចត្រូវបានលក់បានតែតម្លៃកាកសំណល់ និងមិនអាចទទួលបានលំហូរសាច់ប្រាក់ចូល ដែលមានឯករាជ្យភាពច្រើននៃលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មផ្សេងទៀតនៃសកម្មភាពរុករករ៉ែ។<br>មិនអាចប៉ាន់ស្មានតម្លៃអាចទទួលបានមកវិញ នៃផ្លូវដែកឯកជនព្រោះថាតម្លៃកំពុងប្រើប្រាស់ មិនអាចត្រូវបានកំណត់ និងភនីយភាពខុសគ្នា ពីតម្លៃកាកសំណល់។ ដូចនេះ អង្គភាពប៉ាន់ស្មានតម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ដែលផ្លូវដែកឯកជនស្ថិតនៅ ជាឧទាហរណ៍ការរុករករ៉ែទាំងមូលនេះ។ |

៦៨ ដូចបានកំណត់ក្នុងកថាខណ្ឌ ទី ៦ អង្គភាពរកសាច់ប្រាក់របស់ទ្រព្យសកម្មមួយ គឺជាក្រុមនៃទ្រព្យសកម្មតូចបំផុត ដែលរួមបញ្ចូលទ្រព្យសកម្ម និងទទួលបានលំហូរសាច់ប្រាក់ចូល ដែលមានឯករាជ្យភាព ច្រើននៃលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្ម ឬក្រុមនៃទ្រព្យសកម្មផ្សេងទៀត។ ការកំណត់អង្គភាពរកសាច់ប្រាក់គឺពាក់ព័ន្ធនឹងការសន្មត។ ប្រសិនបើតម្លៃអាចទទួលបានមកវិញរបស់ទ្រព្យសកម្មនីមួយៗ មិនអាចត្រូវបានកំណត់បានអង្គភាពមួយកំណត់ទ្រព្យសកម្មសរុបតូចបំផុតនៃទ្រព្យសកម្ម ដែលមានឯករាជ្យភាពច្រើនលើលំហូរសាច់ប្រាក់ចូលទទួលបាន ។

| ឧទាហរណ៍ |
| --- |
| ក្រុមហ៊ុនឡានក្រុងផ្តល់សេវាកម្ម ដោយមានកិច្ចសន្យាជាមួយសាលាក្រុង ដែលតម្រូវឱ្យផ្តល់សេវាកម្មអប្បបរមានៅផ្លូវប្រាំខ្សែផ្សេងគ្នា។ ទ្រព្យសកម្មដែលចូលរួមក្នុងផ្លូវនីមួយៗ និងលំហូរសាច់ប្រាក់ពីផ្លូវនីមួយៗអាចកំណត់ដាច់ដោយឡែកពីគ្នា។ ផ្លូវមួយក្នុងចំណោមផ្លូវទាំងប្រាំ គឺខាតខ្លាំង។<br>ព្រោះថាអង្គភាពមិនមានជម្រើសក្នុងការកាត់ផ្លូវណាមួយ ការកំណត់លំហូរសាច់ប្រាក់ចូលទាបបំផុត ដែលមានឯករាជ្យភាពច្រើនពីទ្រព្យសកម្មឬក្រុមនៃទ្រព្យសកម្មដែលជាលំហូរសាច់ប្រាក់ចូលដែលទទួលបានពីផ្លូវទាំងប្រាំ។ អង្គភាពរកសាច់ប្រាក់សម្រាប់ផ្លូវនីមួយៗគឺសម្រាប់ក្រុមហ៊ុនរថយន្តទាំងមូល។ |

៦៩ លំហូរសាច់ប្រាក់ចូល គឺជាលំហូរចូលនៃសាច់ប្រាក់ចូល និងសាច់ប្រាក់សមមូលចូលទៅក្នុងអង្គភាពដែលទទួលបានពីភាគីខាងក្រៅ។ ក្នុងការកំណត់ពីលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មមួយ (ឬក្រុមនៃទ្រព្យសកម្ម) គឺដែលមានឯករាជ្យភាពច្រើននៃលំហូរសាច់ប្រាក់ចូលបានពីទ្រព្យសកម្ម (ឬក្រុមនៃទ្រព្យសកម្ម) អង្គភាពមួយពិចារណាពីកត្តាផ្សេងៗ ដែលរួមមានរបៀបដែលអ្នកគ្រប់គ្រងតាមដានប្រតិបត្តិការរបស់អង្គភាព (ដូចជាដោយខ្សែផលិតផល អាជីវកម្ម ទីតាំងនីមួយៗ ខណ្ឌ ឬទីតាំងក្នុងតំបន់) ឬរបៀបដែលអ្នកគ្រប់គ្រងធ្វើការសម្រេចចិត្តពីការបន្ត ឬលក់នៃទ្រព្យសកម្មរបស់អង្គភាព និងប្រតិបត្តិការ។ ការបង្ហាញក្នុងឧទាហរណ៍ទី១ ផ្តល់ជាឧទាហរណ៍ក្នុងការកំណត់អង្គភាពរកសាច់ប្រាក់។

៧០ ប្រសិនបើទីផ្សារសកម្មមានសម្រាប់ផលិតផលដែលបានផលិត ដោយទ្រព្យសកម្មមួយ ឬក្រុមនៃទ្រព្យសកម្ម ដែលទ្រព្យសកម្មឬក្រុមនៃទ្រព្យសកម្មនោះត្រូវបានកំណត់ជាអង្គភាពស្វែងរកសាច់ប្រាក់ បើទោះបីជាផលិតផលខ្លះឬទាំងអស់ ផលិតផលត្រូវបានប្រើផ្ទៃក្នុង។ ប្រសិនបើលំហូរសាច់ប្រាក់ចូលបានទទួលបានដោយទ្រព្យសកម្មមួយ ឬអង្គភាពរកសាច់ប្រាក់ ត្រូវបានប៉ះពាល់ដោយការផ្ទេរថ្លៃខាងក្នុង អង្គភាពមួយប្រើការប៉ាន់ស្មានថ្លៃអនាគតដ៏ល្អបំផុតរបស់អ្នកគ្រប់គ្រងដែលអាចទទួលបានពីការប៉ាន់ស្មានប្រតិបត្តិការបណ្តោយដៃ÷

(ក) លំហូរសាច់ប្រាក់ចូលអនាគត បានប្រើក្នុងការកំណត់តម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្ម ឬអង្គភាព រកសាច់ប្រាក់ និង

(ខ) លំហូរសាច់ប្រាក់ចេញអនាគតបានប្រើក្នុងការកំណត់តម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្មណាមួយ ឬអង្គភាពរកសាច់ប្រាក់ដែលអាចត្រូវបានប៉ះពាល់ដោយការផ្ទេរថ្លៃខាងក្នុង។

៧១ ប្រសិនបើផ្នែក ឬទាំងអស់នៃផលិតផលបានផលិតដោយទ្រព្យសកម្មមួយ ឬក្រុមនៃទ្រព្យសកម្មត្រូវបានប្រើដោយផ្នែកផ្សេងនៃអង្គភាព (ឧទាហរណ៍ ផលិតផលនៅក្នុងដំណាក់ពាក់កណ្តាលសម្រេច នៃដំណើរការផលិតកម្ម) ទ្រព្យសកម្មនេះ ឬក្រុមនៃទ្រព្យសកម្មក្នុងទម្រង់អង្គភាពរកសាច់ប្រាក់ដាច់ដោយឡែក ប្រសិនបើអង្គភាពអាចលក់ផលិតផលក្នុងទីផ្សារសកម្ម។ ព្រោះទ្រព្យសកម្ម ឬក្រុមនៃទ្រព្យសកម្ម អាចទទួលបានលំហូរសាច់ប្រាក់ចូលដែលមានឯករាជ្យភាពច្រើននៃលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្ម ឬក្រុមនៃទ្រព្យសកម្មផ្សេងទៀត។ ក្នុងការប្រើព័ត៌មានផ្អែកលើគម្រោងថវិកា/ព្យា-

ករណីដែលពាក់ព័ន្ធនឹងអង្គភាពរកសាច់ប្រាក់ ឬអង្គភាពមួយកែតម្រូវព័ត៌មាននេះ ប្រសិនបើការផ្ទេរថ្លៃផ្ទៃក្នុងមិនឆ្លុះបញ្ចាំងការប៉ាន់ស្មានថ្លៃអនាគតដ៏ល្អបំផុតរបស់អ្នកគ្រប់គ្រង ដែលអាចទទួលបាន តាមរយៈប្រតិបត្តិការបណ្ដោយដៃ។

៧២ **អង្គភាពរកសាច់ប្រាក់ត្រូវបានកំណត់មាននិរន្តភាពពីគ្រាមួយទៅគ្រាមួយសម្រាប់ទ្រព្យសកម្មដូចគ្នា ឬប្រភេទទ្រព្យសកម្ម លើកលែងតែការប្រែប្រួលមានការកែតម្រូវ។**

៧៣ ប្រសិនបើអង្គភាពមួយកំណត់ទ្រព្យសកម្មមួយស្ថិតនៅក្នុងអង្គភាពរក ប្រាក់សាច់ប្រាក់ខុសគ្នាពីគ្រាមុន ឬប្រភេទទ្រព្យសកម្មសរុបសម្រាប់អង្គភាពរកសាច់ប្រាក់របស់ទ្រព្យសកម្មបានផ្លាស់ប្ដូរ កថាខណ្ឌទី ១៣០ តម្រូវឱ្យលាតត្រដាងព័ត៌មានអំពីអង្គភាពរកសាច់ប្រាក់ ប្រសិន**ការខាតពីការធ្លាក់ចុះតម្លៃ**ត្រូវបានទទួលស្គាល់ ឬការប្រែត្រឡប់សម្រាប់អង្គភាពរកសាច់ប្រាក់។

## តម្លៃអាចទទួលបានមកវិញ និងតម្លៃក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់

៧៤ តម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ខ្ពស់ជាងតម្លៃសមស្របដកថ្លៃដើម្បីលក់របស់អង្គភាពរកសាច់ប្រាក់ដកចេញថ្លៃលក់ និងតម្លៃកំពុងប្រើប្រាស់។ សម្រាប់គោលបំណងក្នុងការកំណត់តម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ យោងទៅតាមកថាខណ្ឌទី ១៩-៥៧ ទៅ (ទ្រព្យសកម្ម) អានការយោងទៅ (អង្គភាពរកសាច់ប្រាក់)។

**៧៥ តម្លៃក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់ ត្រូវបានកំណត់លើមូលដ្ឋាននិរន្តភាព ជាមួយនឹងការកំណត់តម្លៃអាចទទួលបានមកវិញនៃអង្គភាពស្វែងរក សាច់ប្រាក់។**

៧៦ តម្លៃក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់÷

(ក) បញ្ចូលតម្លៃក្នុងបញ្ជីនៃតម្លៃទ្រព្យសកម្មដែលចូលរួមដោយផ្ទាល់ ឬ បែងចែកដោយផ្ទាល់ផ្អែកលើមូលដ្ឋានសមស្រប និងនិរន្តភាព ទៅ អង្គភាពរកសាច់ប្រាក់ ហើយនឹងត្រូវទទួលបានលំហូរសាច់ប្រាក់ចូល អនាគត បានប្រើក្នុងការកំណត់តម្លៃកំពុងប្រើប្រាស់របស់អង្គភាពរក សាច់ប្រាក់ និង

(ខ) មិនបញ្ចូលតម្លៃក្នុងបញ្ជីនៃការទទួលស្គាល់ជាបំណុល លើកលែងតែ តម្លៃអាចទទួលបានមកវិញ នៃអង្គភាពស្វែងរកសាច់ប្រាក់មិនអាច ត្រូវបានកំណត់ដោយមិនគិតនៃបំណុលទេ។ព្រោះថាតម្លៃសមស្របដ កថ្លៃដើម្បីលក់ និងតម្លៃកំពុងប្រើប្រាស់នៃអង្គភាពរកសាច់ប្រាក់ត្រូវ បានកំណត់មិនរាប់បញ្ចូលលំហូរសាច់ប្រាក់ ដែលពាក់ព័ន្ធនឹងទ្រព្យ សកម្មដែលមិនមែនជាផ្នែកនៃអង្គភាពរកសាច់ប្រាក់និងបំណុលដែល ត្រូវបានទទួលស្គាល់ (សូមមើលកថាខណ្ឌទី ២៨ និង ៤៣)។

៧៧ នៅពេលទ្រព្យសកម្ម ត្រូវបានដាក់ជាក្រុម សម្រាប់ការវាយតម្លៃពីភាពអាច ទទួលបានមកវិញ ចាំបាច់រួមបញ្ចូលក្នុងអង្គភាពរកសាច់ប្រាក់នូវទ្រព្យសកម្ម ដែលទទួលបាន ឬត្រូវបានប្រើ ក្នុងការទទួលបានលំហូរសាច់ប្រាក់ចូល។ ម្យ៉ាងទៀត អង្គភាពរកសាច់ប្រាក់អាចចេញជាតម្លៃអាចទទួលបានមកវិញ ពេញលេញ នៅពេលការពិតការខាតពីការធ្លាក់ចុះតម្លៃដែលបានកើតឡើង។

ក្នុងករណីខ្លះ ទោះបីទ្រព្យសកម្មខ្លះចូលរួមចំណែក ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត នៃអង្គភាពរកសាច់ប្រាក់ ពួកគេមិនអាចបែងចែកទៅអង្គភាពរកសាច់ប្រាក់ផ្អែកលើមូលដ្ឋានសមស្រប និងនិរន្តភាព។ នេះអាចជាករណីសម្រាប់មូលនិធិពាណិជ្ជកម្ម ឬទ្រព្យសារជីវកម្ម ដូចជាទ្រព្យសកម្មការិយាល័យកណ្តាល។ កថាខណ្ឌទី ៨០-១០៣ ពន្យល់ពីការដោះស្រាយជាមួយទ្រព្យសកម្មទាំងនេះក្នុងការសាកល្បងការធ្លាក់ចុះនៃតម្លៃនៃអង្គភាពរកសាច់ប្រាក់។

៧៨ ចាំបាច់ពិចារណាការទទួលស្គាល់បំណុល ក្នុងការកំណត់តម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់។ករណីនេះអាចកើតឡើងប្រសិនបើការលក់អង្គភាពរកសាច់ប្រាក់តម្រូវឱ្យអ្នកទិញសន្មត់ជាបំណុល។ ក្នុងករណីនេះតម្លៃសមស្របដកថ្លៃដើម្បីលក់ (ឬការប៉ាន់ស្មានលំហូរសាច់ប្រាក់ពីការលក់ចុងក្រោយ) នៃអង្គភាពរកសាច់ប្រាក់ គឺជាការប៉ាន់ស្មានថ្លៃលក់សម្រាប់ទ្រព្យសកម្មនៃអង្គភាពរកសាច់ប្រាក់ និងបំណុលទាំងអស់ដកចេញចំណាយលក់។ ដើម្បីអនុវត្តការប្រៀបធៀបរវាងតម្លៃក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់ និងតម្លៃអាចទទួលបានមកវិញ តម្លៃក្នុងបញ្ជីនៃបំណុលត្រូវបានដកចេញក្នុងការកំណត់ទាំងតម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្ម និងតម្លៃក្នុងបញ្ជី។

| ឧទាហរណ៍ |
| --- |
| ក្រុមហ៊ុនប្រតិបត្តិការក្នុងរុករករ៉ែក្នុងប្រទេសមួយ ដែលច្បាប់តម្រូវឱ្យម្ចាស់កម្មសិទ្ធស្តារឡើងវិញនូវទីតាំងដែល បានធ្វើប្រតិបត្តិការរុករករ៉ែ។ ចំណាយដើម្បីស្តារឡើង |

វិញនូវទីតាំងរួមមានការជំនួសនៃការបន្ទុកលើស ដែលត្រូវដកហូតមុនពេលចាប់ផ្តើមប្រតិបត្តិការរុករករ៉ែ។ សំវិធានធនសម្រាប់ចំណាយការជំនួសបន្ទុកលើសត្រូវបានទទួលស្គាល់ឆាប់បំផុតបន្ទុកលើស ដែលត្រូវដកចេញ។ តម្លៃទទួលបានត្រូវបានទទួលស្គាល់ ជាផ្នែកនៃចំណាយនៃការរុករករ៉ែ ហើយត្រូវបានចាប់ផ្តើមរំលស់លើអាយុកាលប្រើប្រាស់។ តម្លៃក្នុងបញ្ជីនៃសំវិធានធនសម្រាប់ស្តារឡើងវិញ នូវទីតាំង CU ៥០០[c] ដែលស្មើទៅនឹងតម្លៃបច្ចុប្បន្ននៃចំណាយស្តារឡើងវិញនូវទីតាំង។ក្រុមហ៊ុនប្រតិបត្តិការក្នុងរុករករ៉ែក្នុងប្រទេសមួយ ដែលច្បាប់តម្រូវឱ្យម្ចាស់កម្មសិទ្ធស្តារឡើងវិញនូវទីតាំងដែល បានធ្វើប្រតិបត្តិការរុករករ៉ែ។ ចំណាយដើម្បីស្តារឡើងវិញនូវទីតាំងរួមមានការជំនួសនៃការបន្ទុកលើសដែលត្រូវដកហូតមុនពេលចាប់ផ្តើមប្រតិបត្តិការរុករករ៉ែ។ សំវិធានធនសម្រាប់ចំណាយការជំនួសបន្ទុកលើសត្រូវបានទទួលស្គាល់ឆាប់បំផុតបន្ទុកលើសដែលត្រូវដកចេញ។ តម្លៃទទួលបានត្រូវបានទទួលស្គាល់ជាផ្នែកនៃចំណាយនៃការរុករករ៉ែ ហើយត្រូវបានចាប់ផ្តើមរំលស់លើអាយុកាលប្រើប្រាស់។ តម្លៃក្នុងបញ្ជីនៃសំវិធានធនសម្រាប់ស្តារឡើងវិញនូវទីតាំងសីយូ ៥០០[d]ដែលស្មើទៅនឹងតម្លៃបច្ចុប្បន្ននៃចំណាយស្តារឡើងវិញនូវទីតាំង។

---

[c] នៅក្នុងស្តង់ដារនេះ តម្លៃជាសាច់ប្រាក់ត្រូវបានកំណត់ក្នុង (ឯកតារូបិយប័ណ្ណ) (សីយូ)។

[d] នៅក្នុងស្តង់ដារនេះ តម្លៃជាសាច់ប្រាក់ត្រូវបានកំណត់ក្នុង (ឯកតារូបិយប័ណ្ណ) (សីយូ)។

អង្គភាពធ្វើតេស្តការធ្លាក់ចុះនៃតម្លៃរ៉ែ។ អង្គភាពរកសាច់ប្រាក់សម្រាប់រ៉ែគឺជារ៉ែទាំងមូល។ អង្គភាពទទួលបានសំណើក្នុងការទិញរ៉ែនូវតម្លៃប្រហែល សីយូ ៨០០។ ថ្ងៃនេះឆ្លុះបញ្ចាំងការពិតថា អ្នកទិញនឹងសន្មត់កាតព្វកិច្ចស្តារឡើងវិញនូវទីតាំងបន្ទុកលើស។ ចំណាយលក់សម្រាប់រ៉ែមិនធំដុំ។ តម្លៃកំពុងប្រើប្រាស់នៃរ៉ែគឺប្រហាក់ប្រហែល សីយូ ១.២០០ មិនរាប់បញ្ចូលចំណាយសម្រាប់ស្តារឡើងវិញនូវទីតាំង។ តម្លៃក្នុងបញ្ជីនៃរ៉ែគឺ សីយូ ១.០០០។

តម្លៃសមស្របរបស់អង្គភាពរកសាច់ប្រាក់ដកថ្លៃដើម្បីលក់ គឺ សីយូ ៨០០។ តម្លៃនេះគិតពីចំណាយសម្រាប់ ស្តារឡើងវិញនូវទីតាំងដែលបានត្រៀមរួចជាស្រេច។ ជាលទ្ធផល តម្លៃកំពុងប្រើប្រាស់សម្រាប់អង្គភាពរកសាច់ប្រាក់ ត្រូវបានកំណត់បន្ទាប់ពីគិតការចំណាយស្តារឡើងវិញនូវទីតាំង និងត្រូវបានប៉ាន់ស្មានទៅជាសីយូ ៧០០ (សីយូ ១.២០០ ដក សីយូ ៥០០)។ តម្លៃក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់គឺ សីយូ ៥០០ ដែលតម្លៃក្នុងបញ្ជីនៃរ៉ែ (សីយូ១.០០០) ដកចេញតម្លៃក្នុងបញ្ជី នៃសំវិធានធនសម្រាប់ការចំណាយស្តារឡើងវិញនូវទីតាំង (សីយូ ៥០០)។ ដូចនេះ តម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់លើសពីតម្លៃក្នុងបញ្ជី។

ក្រុមហ៊ុនប្រតិបត្តិការក្នុងរុករករ៉ែក្នុងប្រទេសមួយ ដែលច្បាប់តម្រូវឱ្យម្ចាស់កម្មសិទ្ធស្តារឡើងវិញនូវទីតាំងដែល បានធ្វើប្រតិបត្តិការរុករករ៉ែ។ ចំណាយដើម្បីស្តារឡើងវិញនូវទីតាំងរួមមានការជំនួសនៃការបន្ទុកលើសដែលត្រូវដកហូតមុនពេលចាប់ផ្តើមប្រតិបត្តិការរុករករ៉ែ។ សំវិធានធនសម្រាប់ចំណាយការជំនួសបន្ទុកលើសត្រូវបានទទួលស្គាល់ឆាប់បំផុតបន្ទុកលើសដែលត្រូវដកចេញ។ តម្លៃទទួលបានត្រូវបានទទួលស្គាល់ជាផ្នែកនៃចំណាយនៃការរុករករ៉ែ ហើយត្រូវបានចាប់ផ្តើមរំលស់លើអាយុកាលប្រើប្រាស់។ តម្លៃក្នុងបញ្ជីនៃសំវិធានធនសម្រាប់ស្តារឡើង

វិញនូវទីតាំងសីយូ ៥០០[e]ដែលស្មើទៅនឹងតម្លៃបច្ចុប្បន្ននៃចំណាយស្តារឡើងវិញនូវទីតាំង។

៧៩. សម្រាប់មូលផលអនុវត្ត តម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ពេលខ្លះត្រូវបានកំណត់បន្ទាប់ពីគិតនៃទ្រព្យសកម្មដែលមិនមែនជាផ្នែក នៃអង្គភាពរកសាច់ប្រាក់ (ឧទាហរណ៍ គណនីត្រូវទទួល ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ) ឬបំណុលដែលត្រូវបានទទួលស្គាល់ (ឧទាហរណ៍ គណនីត្រូវបង់ សោធននិវត្ត និងសំវិធានធនផ្សេងទៀត)។ ក្នុងករណីនេះ តម្លៃក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់ត្រូវ បានកើនឡើងដោយតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មទាំងនោះ និងការថយចុះដោយតម្លៃក្នុងបញ្ជីនៃបំណុលទាំងនោះ។

**មូលនិធិពាណិជ្ជកម្ម**

*ការបែងចែកមូលនិធិពាណិជ្ជកម្មទៅអង្គភាពរកប្រាក់ចំណេញ*

៨០ **សម្រាប់គោលបំណងនៃការធ្វើតេស្តការធ្លាក់ចុះតម្លៃមូលនិធិពាណិជ្ជកម្មបានទទួលក្នុងការបញ្ចូលអាជីវកម្មពីថ្ងៃទិញ ត្រូវបានបែងចែកទៅអង្គភាពរកសាច់ប្រាក់នីមួយៗ ឬក្រុមនៃអង្គភាពរកសាច់ប្រាក់ របស់អ្នកទិញដែលត្រូវបានរំពឹងថាទទួលបានអត្ថប្រយោជន៍ពីផលនៃការបញ្ចូលគ្នាមិនពាក់ព័ន្ធទ្រព្យសកម្ម ឬបំណុល ផ្សេងទៀត នៃអ្នកលក់ត្រូវកំណត់បានចែកទៅអង្គភាព ឬ**

---

[e] នៅក្នុងស្តង់ដារនេះ តម្លៃជាសាច់ប្រាក់ត្រូវបានកំណត់ក្នុង (ឯកតារូបិយប័ណ្ណ) (សីយូ)។

**ក្រុមនៃអង្គភាព។ អង្គភាពនីមួយៗ ឬក្រុមនៃអង្គភាពដែលមូលនិធិពាណិជ្ជកម្មដែលត្រូវបានបែងចែក÷**

**(ក) បង្ហាញពីកម្រិត ទាបក្នុងអង្គភាពដែលមូលនិធិពាណិជ្ជកម្មត្រូវបានតាម ដានសម្រាប់គោលបំណងគ្រប់គ្រងផ្ទៃក្នុង និង**

**(ខ) មិនធំជាងប្រតិបត្តិការតាមផ្នែកដូចបានកំណត់ដោយកថាខណ្ឌ ទី ៥ នៃ ស.រ.ហ.អ.ក ៨** ប្រតិបត្តិការតាមផ្នែក **មុនពេលសរុប។**

៨១ មូលនិធិពាណិជ្ជកម្ម បានទទួលស្គាល់ក្នុងការបញ្ចូលអាជីវកម្ម គឺជាទ្រព្យសកម្មដោយបង្ហាញពីអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលកើតចេញពីទ្រព្យសកម្មផ្សេងទៀតទទួលបានពីការបញ្ចូលអាជីវកម្មដែលមិនកំណត់ជាបុគ្គល និងទទួលស្គាល់ដាច់ដោយឡែក។ មូលនិធិពាណិជ្ជកម្មមិនទទួលបានសាច់ប្រាក់ផ្អែកលើនៃទ្រព្យសកម្ម ឬក្រុមនៃទ្រព្យសកម្មផ្សេងៗ និងជាទូទៅចូលរួមក្នុងលំហូរសាច់ប្រាក់នៃអង្គភាពរកសាច់ប្រាក់ជាច្រើន។ មូលនិធិពាណិជ្ជ-កម្មពេលខ្លះមិនអាចបែងចែកលើមូលដ្ឋានមិនស្មើភាព ទៅអង្គភាពរកសាច់ប្រាក់នីមួយៗ គឺទៅក្រុមនៃអង្គភាពរកសាច់ប្រាក់។ ជាលទ្ធផល កម្រិតទាបបំផុតក្នុងអង្គភាពដែលមូលនិធិពាណិជ្ជកម្មត្រូវបានតាមដាន សម្រាប់គោលបំណងគ្រប់គ្រងផ្ទៃក្នុង ពេលខ្លះមានអង្គភាពរកសាច់ប្រាក់ច្រើន ដែលមូលនិធិពាណិជ្ជកម្មពាក់ព័ន្ធ ប៉ុន្តែមិនអាចបែងចែកបាន។ យោងក្នុងកថាខណ្ឌទី ៨៣-៩៩ និងឧបសម្ព័ន្ធ គ ទៅអង្គភាពរកសាច់ប្រាក់ ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែកត្រូវអានជាការយោង ក៏ដូចជាក្រុមនៃអង្គភាពរកសាច់ប្រាក់ ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក។

៨២ ការអនុវត្តលក្ខខណ្ឌក្នុងកថាខណ្ឌទី ៨០ ជាលទ្ធផលក្នុងមូលនិធិពាណិជ្ជកម្ម ត្រូវធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃនៅកំរិតមួយដែលឆ្លុះបញ្ចាំងមធ្យោបាយ ដែលអង្គភាពមួយគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន និងមូលនិធិពាណិជ្ជកម្ម ដែលពាក់ព័ន្ធធម្មតា។ ដូចនេះ មិនចាំបាច់ការអភិវឌ្ឍន៍ប្រព័ន្ធរាយការណ៍ បន្ថែម។

៨៣ អង្គភាពរកសាច់ប្រាក់ ដែលមូលធិនិពាណិជ្ជកម្មត្រូវបានបែងចែកស្ថិតនៅ សម្រាប់គោលបំណងការធ្វើតេស្តការធ្លាក់ចុះតម្លៃអាចមិនថៃដន្យជាមួយ កម្រិតមួយដែលមូលធិនិពាណិជ្ជកម្មត្រូវបានបែងចែកស្របតាម ស.គ.អ.ក ២១ *ការប៉ះពាល់ នៃការផ្លាស់ប្ដូរអត្រាប្ដូរប្រាក់* សម្រាប់គោលបំណងវាស់វែង ចំណេញ និងខាតរូបិយប័ណ្ណបរទេស។ ឧទាហរណ៍ ប្រសិនបើអង្គភាពមួយ ត្រូវបានតម្រូវដោយ ស.គ.អ.ក ២១ ដើម្បីបែងចែកមូលនិធិពាណិជ្ជកម្ម ទៅកម្រិតទាប សម្រាប់គោលបំណងវាស់វែង ការចំណេញនៃរូបិយប័ណ្ណ បរទេសនិងខាតរូបិយប័ណ្ណ វាមិនតម្រូវឱ្យមានធ្វើតេស្តមូលនិធិពាណិជ្ជកម្ម សម្រាប់ការធ្លាក់ចុះតម្លៃនៅកម្រិតដូចគ្នា លើកលែងតែការតាមដានមូលនិធិ ពាណិជ្ជកម្មនៅកម្រិតមួយសម្រាប់គោលបំណងគ្រប់គ្រងផ្ទៃក្នុង។

៨៤ **ប្រសិនបើការបែងចែកមូលធិនិពាណិជ្ជកម្មលើកដំបូងទទួលបានពីការបញ្ចូល អាជីវកម្មមិនអាចត្រូវបានបញ្ចប់មុនពេលចុងគ្រាប្រចាំឆ្នាំដែលត្រូវបានប៉ះ ពាល់ដោយការបញ្ចូលអាជីវកម្ម ការបែងចែកលើកដំបូងត្រូវបានបញ្ចប់មុន ពេលចុងគ្រាប្រចាំឆ្នាំទី១ ចាប់ផ្តើមបន្ទាប់ពីថ្ងៃទិញ។**

៨៥ ស្របតាម ស.រ.ហ.អ.ក ៣ ការបញ្ចូលអាជីវកម្ម ប្រសិនបើការទទួលស្គាល់គណនេយ្យដំបូងសម្រាប់ការបញ្ចូលអាជីវកម្មអាចត្រូវបានកំណត់នៅចុងគ្រាដែលប៉ះពាល់ដោយការបញ្ចូលគ្នា អ្នកទិញ÷

(ក) គណនីសម្រាប់ការបញ្ចូលគ្នាដោយប្រើប្រាស់តម្លៃសំវិធានធន និង

(ខ) ទទួលស្គាល់ការកែតម្រូវណាមួយ ទៅតម្លៃសំវិធានធនជាលទ្ធផលនៃការបញ្ចប់គណនេយ្យដំបូងនៅក្នុងគ្រាវាស់វែង ដែលមិនលើសពីដប់ពីរខែពីថ្ងៃទិញ។

នៅក្នុងស្ថានភាពនេះមិនមានលទ្ធភាពបញ្ចប់ការបែងចែកដំបូងនៃការទទួលស្គាល់មូលនិធិពាណិជ្ជកម្ម ក្នុងការបញ្ចូលគ្នាមុនពេលបញ្ចប់គ្រាប្រចាំឆ្នាំដែលប៉ះពាល់ពីការបញ្ចូលគ្នា។ ករណីនេះ អង្គភាពលាតត្រដាងព័ត៌មានដូចបានតម្រូវដោយកថាខណ្ឌទី ១៣៣។

**៨៦ ប្រសិនបើមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែកទៅអង្គភាពរកសាច់ប្រាក់ និងអង្គភាពលក់ប្រតិបត្តិការណាមួយនៅក្នុងអង្គភាពនោះ មូលនិធិពាណិជ្ជកម្មពាក់ព័ន្ធជាមួយប្រតិបត្តិការលក់ត្រូវ÷**

**(ក) បញ្ចូលក្នុងតម្លៃក្នុងបញ្ជីនៃប្រតិបត្តិការនៅពេលកំណត់ចំណេញ ឬខាតពីការលក់ និង**

**(ខ) វាស់វែងផ្អែកលើមូលដ្ឋាននៃតម្លៃពាក់ព័ន្ធនៃប្រតិបត្តិការលក់ និងផ្នែកនៃការរក្សាទុកអង្គភាពរកសាច់ប្រាក់ លើកលែងតែអង្គភាព អាចបង្ហាញថាវិធីសាស្ត្រប្រសើរជាងក្នុងការឆ្លុះបញ្ចាំងមូលនិធិពាណិជ្ជកម្មពាក់ព័ន្ធជាមួយប្រតិបត្តិការលក់។**

| ឧទាហរណ៍ |
| --- |
| អង្គភាពមួយលក់សីយូ ១០០ ប្រតិបត្តិការមួយដែលជាផ្នែកមួយនៃអង្គភាពរកសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក។ មូលនិធិពាណិជ្ជកម្ម បានបែងចែកទៅកាន់អង្គភាពមិនអាចត្រូវបានកំណត់ឬពាក់ព័ន្ធជាមួយក្រុមទ្រព្យសកម្មនៅកម្រិតទាបជាងអង្គភាព លើកលែងតែស្មើភាព។ តម្លៃអាចទទួលបានមកវិញនៃចំណែកនៃអង្គភាពរកសាច់ប្រាក់បានរក្សាគឺសីយូ ៣០០។ព្រោះថាមូលនិធិពាណិជ្ជកម្មបានបែងចែកទៅកាន់អង្គភាពរកសាច់ប្រាក់មិនអាចកំណត់ស្មើភាព ឬពាក់ព័ន្ធក្រុមនៃទ្រព្យសកម្មនៅកម្រិតទាប មួយជាងអង្គភាព មូលនិធិពាណិជ្ជកម្មពាក់ព័ន្ធជាមួយប្រតិបត្តិការលក់ត្រូវបានវាស់វែងលើមូលដ្ឋាននៃតម្លៃពាក់ព័ន្ធនៃប្រតិបត្តិការលក់និងចំណែកនៃអង្គភាពបានរក្សាទុក។ដូចនេះ ២៥ ភាគរយនៃមូលនិធិពាណិជ្ជកម្មបានបែងចែកទៅអង្គភាពរកសាច់ប្រាក់ត្រូវបានបញ្ចូលក្នុងតម្លៃក្នុងបញ្ជីនៃប្រតិបត្តិការដែលលក់នោះ។ |

**៨៧ ប្រសិនបើអង្គភាពមួយរុះរើរចនាសម្ព័ន្ធរាយការណ៍ក្នុងមធ្យោបាយមួយដែលផ្លាស់ប្តូរសមាសធាតុមួយឬច្រើននៃអង្គភាពរកសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក មូលនិធិពាណិជ្ជកម្មត្រូវបានបែងចែកសារជាថ្មីទៅអង្គភាពដែលរងឥទ្ធិពល។ ការបែងចែកសារជាថ្មីនេះត្រូវបានអនុវត្តដោយប្រើវិធីតម្លៃពាក់ព័ន្ធប្រហាក់ប្រហែលគ្នានៅពេលអង្គភាពមួយលក់ប្រតិបត្តិការណាមួយក្នុងអង្គភាពរកសាច់ប្រាក់ លើកលែងតែអង្គភាពអាចបង្ហាញថាវិធីសាស្ត្រប្រសើរជាងក្នុងការឆ្លុះបញ្ចាំងមូលនិធិពាណិជ្ជកម្មពាក់ព័ន្ធជាមួយការរុះរើអង្គភាព។**

| ឧទាហរណ៍ |
| --- |
| មូលនិធិពាណិជ្ជកម្មដែលពីមុនបានបែងចែកទៅអង្គភាពរកសាច់ប្រាក់ ក។ មូលនិធិពាណិជ្ជកម្មបានបែងចែកទៅ ក មិនអាចត្រូវបានកំណត់ ឬពាក់ព័ន្ធជាមួយក្រុមទ្រព្យសកម្មមួយនៅកម្រិតទាបជាង ក លើកលែងតែមានស្មើភាព។ ក ត្រូវបានចែក និងបញ្ចូលទៅក្នុងអង្គភាពស្វែងរកសាច់ប្រាក់បី គឺ ខ គ និងឃ។ ព្រោះថាមូលនិធិពាណិជ្ជកម្មបានបែងចែកទៅ ក មិនអាចកំណត់ស្មើភាព ឬពាក់ព័ន្ធជាមួយក្រុមនៅកម្រិតទាបជាង ក វាត្រូវបានបែងចែកសារជាថ្មីទៅអង្គភាព ខ គ និងឃ លើមូលដ្ឋាន នៃតម្លៃពាក់ព័ន្ធនៃចំណែកបី នៃ ក មុនពេលចំណែកត្រូវបានប្រមូលផ្តុំជាមួយ ខ គ និង ឃ។ |

*ការធ្វើតេស្តអង្គភាពរកសាច់ប្រាក់*

*ជាមួយមូលនិធិពាណិជ្ជកម្មសម្រាប់ការធ្លាក់ចុះតម្លៃ*

**៨៨ ដូចបានបរិយាយក្នុងកថាខណ្ឌ ទី ៨១ នៅពេលមូលនិធិពាណិជ្ជកម្មពាក់ព័ន្ធនឹងអង្គភាពរកសាច់ប្រាក់ ប៉ុន្តែមិនត្រូវបានបែងចែកទៅអង្គភាពនោះ អង្គភាពត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃ នៅពេលមានសញ្ញាថាអង្គភាពត្រូវបានធ្លាក់ចុះតម្លៃ ដោយប្រៀបធៀបតម្លៃក្នុងបញ្ជីនៃអង្គភាពជាមួយនឹងតម្លៃអាចទទួលបានមកវិញ លើកលែងមូលនិធិពាណិជ្ជកម្មណាមួយ។ ការខាតពីធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ស្របតាមកថាខណ្ឌទី ១០៤។**

៨៩ ប្រសិនបើអង្គភាពរកសាច់ប្រាក់ដូចបានបរិយាយក្នុងកថាខណ្ឌទី៨៨ បញ្ចូលក្នុងតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មអរូបីយមួយដែលមានអាយុកាលប្រើប្រាស់មិនកំណត់បាន ឬមិនទាន់រួចរាល់សម្រាប់ប្រើប្រាស់ ហើយទ្រព្យសកម្មនោះអាច

ត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃជាផ្នែកមួយនៃអង្គភាពរកសាច់ប្រាក់ កថាខណ្ឌ ទី ១០ តម្រូវឱ្យអង្គភាពត្រូវបានធ្វើតេស្ត សម្រាប់ការធ្លាក់ចុះតម្លៃប្រចាំឆ្នាំ។

៩០ អង្គភាពរកសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែកត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃប្រចាំឆ្នាំ ហើយនៅពេលមានសញ្ញាថាអង្គភាពអាចត្រូវបានធ្លាក់ចុះតម្លៃ ដោយប្រៀបធៀបរវាងតម្លៃក្នុងបញ្ជីនៃអង្គភាពរួមបញ្ចូលមូលនិធិពាណិជ្ជកម្ម ជាមួយតម្លៃអាចទទួលបានមកវិញ។ ប្រសិនបើតម្លៃអាចទទួលបានមកវិញនៃអង្គភាពលើសពីតម្លៃក្នុងបញ្ជីនៃអង្គភាព អង្គភាព និងមូលនិធិពាណិជ្ជកម្មបែងចែកទៅអង្គភាពនោះត្រូវបានចាត់ថាមិនធ្លាក់ចុះតម្លៃ។ ប្រសិនបើតម្លៃក្នុងបញ្ជីនៃអង្គភាពលើសពីតម្លៃដែលអាចទទួលបានមកវិញនៃអង្គភាព អង្គភាពត្រូវទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃស្របតាមកថាខណ្ឌទី ១០៤។

៩១-៩៥ (បានលុបចោល)

*ពេលវេលានៃការធ្វើតេស្តការធ្លាក់ចុះតម្លៃ*

៩៦ ការធ្វើតេស្តការធ្លាក់ចុះតម្លៃប្រចាំឆ្នាំសម្រាប់អង្គភាពរកសាច់ប្រាក់ទៅមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែកអាចត្រូវបានអនុវត្តនៅពេលណាមួយកំឡុងគ្រាផ្តល់ការធ្វើតេស្តត្រូវបានអនុវត្តនៅពេលដូចគ្នាជារៀងរាល់ឆ្នាំ។ភាពខុសគ្នានៃអង្គភាពរកសាច់ប្រាក់អាចត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃនៅពេលខុសគ្នា។ ប៉ុន្តែ ប្រសិនបើមូលនិធិពាណិជ្ជកម្មខ្លះ ឬមូលនិធិពាណិជ្ជកម្ម ទាំងអស់បានបែងចែកទៅជាអង្គភាពរកសាច់ប្រាក់ត្រូវបានទទួលក្នុងការរួមបញ្ចូល

អាជីវកម្មក្នុងកំឡុងគ្រាបច្ចុប្បន្ន អង្គភាពនោះត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃមុនចុងគ្រាបច្ចុប្បន្ន។

៩៧ ប្រសិនបើទ្រព្យសកម្មបង្កើតអង្គភាពរកសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក ត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃ នៅពេលដូចគ្នាជាអង្គភាពមានមូលនិធិពាណិជ្ជកម្ម ពួកគេត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃមុនពេលអង្គភាពមានមូលនិធិពាណិជ្ជកម្ម។ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើអង្គភាពរកសាច់ប្រាក់បង្កើតក្រុមនៃអង្គភាពរកសាច់ប្រាក់ ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែកធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃនៅពេលដូចគ្នាជាក្រុមនៃអង្គមានមូលនិធិពាណិជ្ជកម្ម អង្គភាពនីមួយៗត្រូវបានធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃមុនពេលក្រុមនៃអង្គភាពមានមូលនិធិពាណិជ្ជកម្ម។

៩៨ នៅពេលការធ្វើតេស្តនៃការធ្លាក់ចុះតម្លៃអង្គភាពរកសាច់ប្រាក់ ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក មានសញ្ញានៃការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្មមួយក្នុងអង្គភាពមានមូលនិធិពាណិជ្ជកម្ម។ ក្នុងស្ថានភាពនេះ អង្គភាពធ្វើតេស្តទ្រព្យសកម្មសម្រាប់ការធ្លាក់ចុះតម្លៃជាមុន ហើយទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មនោះមុនពេលធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃនៃអង្គភាពរកសាច់ប្រាក់មានមូលនិធិពាណិជ្ជកម្ម។ ប្រហាក់ប្រហែលគ្នានេះដែរ មានសញ្ញានៃការធ្លាក់ចុះតម្លៃនៃអង្គភាពរកសាច់ប្រាក់នៅក្នុងក្រុមនៃអង្គភាពមានមូលនិធិពាណិជ្ជកម្ម។ ក្នុងស្ថានភាពនេះ អង្គភាពធ្វើតេស្តអង្គភាពរកសាច់ប្រាក់ សម្រាប់ការធ្លាក់ចុះតម្លៃជាមុន ហើយទទួល

ស្គាល់ការខាតពីការធ្លាក់ចុះតម្លៃសម្រាប់អង្គភាព មុនពេលធ្វើតេស្តសម្រាប់ការធ្លាក់ចុះតម្លៃក្រុមនៃអង្គភាពដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក។

៩៩ **ការគណនាលម្អិតថ្មីៗបំផុតក្នុងគ្រាមុននៃតម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក អាចត្រូវបានប្រើប្រាស់ក្នុងការធ្វើតេស្តការធ្លាក់ចុះតម្លៃនៃអង្គភាពក្នុងគ្រាបច្ចុប្បន្ន ដោយគោរពបាននូវលក្ខខណ្ឌ ដូចខាងក្រោម÷**

**(ក) ទ្រព្យសកម្ម និងបំណុលបង្កើតឡើងអង្គភាពដែលមិនបានផ្លាស់ប្ដូរសំខាន់ចាប់តាំងពីការគណនាតម្លៃទទួលបានមកវិញថ្មីៗបំផុត**

**(ខ) ការគណនាតម្លៃអាចទទួលបានមកវិញថ្មីបំផុតលទ្ធផលបានមកពីតម្លៃដែលលើសតម្លៃក្នុងបញ្ជីនៃអង្គភាពដោយគំលាតខ្លាំងបំផុត និង**

**(គ) ផ្អែកលើការវិភាគព្រឹត្តិការណ៍ដែលបានកើតឡើងនិងស្ថានភាព ដែលបានផ្លាស់ប្ដូរចាប់តាំងពីគណនាតម្លៃអាចទទួលបានមកវិញថ្មីបំផុត ទំនងការកំណត់តម្លៃអាចទទួលបានមកវិញអាចតិចជាងតម្លៃក្នុងបញ្ជីនៃអង្គភាពនៅឆ្ងាយ។**

### ទ្រព្យសកម្មសារជីវកម្ម

១០០ ទ្រព្យសកម្មសារជីវកម្មរួមបញ្ចូលក្រុម ឬទ្រព្យសកម្មតាមផ្នែក ដូចជា អាគាររបស់ទីស្នាក់ការកណ្ដាល ឬផ្នែកនៃអង្គភាព អីឌីភីឧបករណ៍ ឬមណ្ឌលស្រាវជ្រាវ។ រចនាសម្ព័ន្ធអង្គភាពកំណត់ពីទ្រព្យសកម្មមួយអាចអនុវត្តបានតាមនិយមន័យនៃស្តង់នេះសម្រាប់ទ្រព្យសកម្មសាជីវកម្មសម្រាប់អង្គភាពរកសាច់ប្រាក់ជាក់លាក់ណាមួយ។ លក្ខណៈសំគាល់នៃទ្រព្យសកម្មសារជីវកម្ម គឺពួក

គេមិនទទួលបានលំហូរសាច់ប្រាក់ចូលដោយមិនផ្អែកលើទ្រព្យសកម្ម ឬក្រុមនៃទ្រព្យសកម្មផ្សេងៗទៀត ហើយតម្លៃក្នុងបញ្ជីមិនអាចចូលរួមដោយផ្ទាល់ទៅអង្គភាពរកសាច់ប្រាក់។

១០១ ព្រោះទ្រព្យសកម្មសារជីវកម្ម មិនអាចទទួលបានលំហូរសាច់ប្រាក់ចូលដាច់ដោយឡែក តម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មសារជីវកម្មនីមួយៗមិនអាចត្រូវបានកំណត់ លើកលែងតែអ្នកគ្រប់គ្រងសម្រេចចិត្តលក់ទ្រព្យសកម្ម។ ជាលទ្ធផល ប្រសិនបើមានសញ្ញាបង្ហាញថាទ្រព្យសកម្មសារជីវកម្មមួយអាចត្រូវបានធ្លាក់ចុះតម្លៃ តម្លៃអាចទទួលបានមកវិញត្រូវបានកំណត់សម្រាប់អង្គភាពរកសាច់ប្រាក់ ឬក្រុមនៃអង្គភាពរកសាច់ប្រាក់ ដែលទ្រព្យសកម្មសារជីវកម្មស្ថិតនៅ ហើយត្រូវបានធ្វើការប្រៀបធៀបជាមួយតម្លៃក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់ ឬក្រុមនៃអង្គភាពរកសាច់ប្រាក់។ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ស្របតាមកថាខណ្ឌ ទី ១០៤។

**១០២ នៅក្នុងការធ្វើតេស្តធ្លាក់ចុះតម្លៃនៃអង្គភាពរកសាច់ប្រាក់ អង្គភាពមួយត្រូវកំណត់ទ្រព្យសកម្មសារជីវកម្មទាំងអស់ដែលពាក់ព័ន្ធទៅអង្គភាពរកសាច់ប្រាក់។ ប្រសិនបើផ្នែកមួយនៃតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្មសារជីវកម្ម÷**

(ក) **អាចត្រូវបានបែងចែកលើមូលដ្ឋានសមស្រប និងនិរន្តភាពទៅអង្គភាព អង្គភាពត្រូវប្រៀបធៀបតម្លៃក្នុងបញ្ជីនៃអង្គភាព បញ្ចូលចំណែកនៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មសារជីវកម្មបានបែងចែកទៅអង្គភាពជាមួយនឹតម្លៃអាចទទួលបានមកវិញ។ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ស្របតាមកថាខណ្ឌទី ១០៤។**

(ខ) មិនអាចត្រូវបានបែងចែកលើមូលដ្ឋានសមស្រប និងនិរន្តភាពទៅអង្គភាព អង្គភាពត្រូវ÷

(១) ប្រៀបធៀបតម្លៃក្នុងបញ្ជីនៃអង្គភាព មិនបញ្ចូលទ្រព្យសកម្មសារជីវកម្ម ជាមួយតម្លៃអាចទទួលបានមកវិញនិងទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃស្របតាមកថាខណ្ឌទី ១០៤

(២) កំណត់ក្រុមនៃអង្គភាពរកសាច់ប្រាក់តូចជាងគេបំផុត ដែលបញ្ចូលអង្គភាពរកសាច់ប្រាក់ និងផ្នែកនៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មសារជីវកម្មអាចត្រូវបានបែងចែកលើមូលដ្ឋានសមស្រប និងនិរន្តភាព និង

(៣) ប្រៀបធៀបតម្លៃក្នុងបញ្ជីក្រុមនៃអង្គភាពរកសាច់ប្រាក់ បញ្ចូលផ្នែកនៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មសារជីវកម្មបែងចែកទៅក្រុមនៃអង្គភាពរកសាច់ប្រាក់ជាមួយតម្លៃអាចទទួលបានមកវិញនៃក្រុមនៃអង្គភាព។ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ស្របតាមកថាខណ្ឌទី ១០៤។

១០៣ ឧទាហរណ៍បង្ហាញ ទី ៨ បង្ហាញការអនុវត្តនៃលក្ខខណ្ឌទៅលើទ្រព្យសកម្មសារជីវកម្ម។

**ការខាតពីការធ្លាក់ចុះតម្លៃសម្រាប់អង្គភាពរកសាច់ប្រាក់**

១០៤ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់អង្គភាពរកសាច់ប្រាក់ (ក្រុមនៃអង្គភាពរកសាច់ប្រាក់តូចបំផុតដែលមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មសារជីវកម្មត្រូវបានបែងចែក) ប្រសិនបើ តម្លៃអាចទទួលបានមកវិញ

នៃអង្គភាព (ក្រុមនៃអង្គភាព) តិចជាងតម្លៃក្នុងបញ្ជីនៃអង្គភាព (ក្រុមនៃអង្គភាព)។ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានបែងចែកដើម្បីកាត់បន្ថយតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មនៃអង្គភាព (ក្រុមនៃអង្គភាព) ក្នុងលំដាប់ដូចខាងក្រោម÷

(ក) ដំបូងកាត់បន្ថយតម្លៃក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្មបានបែកចែងទៅអង្គភាពរកសាច់ប្រាក់ (ក្រុមនៃអង្គភាព) និង

(ខ) បន្ទាប់មកទៅអង្គភាពទ្រព្យសកម្មផ្សេងទៀតនៃអង្គភាព (ក្រុមនៃអង្គភាព) សមាមាត្រលើ មូលដ្ឋាននៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មនីមួយៗ ក្នុងអង្គភាព (ក្រុមនៃអង្គភាព)។

ការកាត់បន្ថយតម្លៃក្នុងបញ្ជីត្រូវបានចាត់ទុកជាការខាតពីការធ្លាក់ចុះតម្លៃលើទ្រព្យសកម្មមួយៗ និងបានទទួលស្គាល់ស្របតាមកថាខណ្ឌទី ៦០។

១០៥ ការបែងចែកការខាតពីការធ្លាក់ចុះតម្លៃស្របតាមកថាខណ្ឌទី ១០៤ អង្គភាពមួយមិនត្រូវកាត់បន្ថយតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មក្រោមតម្លៃខ្ពស់ជាងនៃ÷

(ក) តម្លៃសមស្របដកថ្លៃដើម្បីលក់ (ប្រសិនបើអាចកំណត់បាន)

(ខ) តម្លៃកំពុងប្រើប្រាស់ (ប្រសិនបើអាចកំណត់បាន) និង

(គ) សូន្យ

តម្លៃនៃការខាតពីការធ្លាក់ចុះតម្លៃដែលត្រូវបានបែងចែកទៅទ្រព្យសកម្មសមាមាត្រទៅទ្រព្យសកម្មផ្សេងទៀតនៃអង្គភាព (ក្រុមនៃអង្គភាព)។

១០៦ ប្រសិនបើ មិនអាចប៉ាន់ស្មានតម្លៃអាចទទួលបានមកវិញ នៃទ្រព្យសកម្មនីមួយៗនៃអង្គភាពរកសាច់ប្រាក់ ស្តង់ដានេះតម្រូវឱ្យការបែងចែកស្មើភាពនៃការខូចពីការធ្លាក់ចុះតម្លៃ រវាងទ្រព្យសកម្មនៃអង្គភាពមិនមែនមូលនិធិ

ពាណិជ្ជកម្ម ព្រោះថាទ្រព្យសកម្មទាំងអស់នៃអង្គភាពរកសាច់ប្រាក់ប្រើជាមួយគ្នា។

១០៧ ប្រសិនបើតម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មនីមួយៗ មិនអាចកំណត់បាន (សូមមើលកថាខណ្ឌទី ៦៧)÷

(ក) ការខាតពីការធ្លាក់ចុះតម្លៃ ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្ម ប្រសិនបើតម្លៃក្នុងបញ្ជីលើស តម្លៃខ្ពស់ជាងនៃតម្លៃសមស្របដកថ្លៃដើម្បីលក់និងលទ្ធផលនៃនិតិវិធីបែងចែកដូចបានបរិយាយក្នុងកថាខណ្ឌទី ១០៤ និង ១០៥ និង

(ខ) គ្មានការខាតពីការធ្លាក់ចុះតម្លៃ ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មប្រសិនបើពាក់ព័ន្ធនឹងអង្គភាពរកសាច់ប្រាក់ មិនត្រូវបានធ្លាក់ចុះតម្លៃ។ ការអនុវត្តនេះបើទោះជាតម្លៃសមស្របដកថ្លៃ ដើម្បីលក់របស់ទ្រព្យសកម្មដើមតិចជាងតម្លៃក្នុងបញ្ជីក៏ដោយ។

| ឧទាហរណ៍ |
|---|
| ម៉ាស៊ីនមួយត្រូវទទួលរងការខូចខាត ប៉ុន្តែនៅអាចដំណើរការបាន ទោះបីជាលក្ខខណ្ឌមិនល្អដូចមុនពេលរងការខូចខាត។ តម្លៃសមស្របដកថ្លៃ ដើម្បីលក់របស់ទ្រព្យសកម្មតិចជាងតម្លៃក្នុងបញ្ជី។ ម៉ាស៊ីនមិនអាចទទួលបានលំហូរសាច់ប្រាក់ចូលដោយឯករាជ្យ។ ការកំណត់ក្រុមនៃទ្រព្យសកម្មតូចបំផុតដែលរួមបញ្ចូលទាំងម៉ាស៊ីន និងលំហូរសាច់ប្រាក់ចូលទទួលបាន ដែលមានឯករាជ្យភាពច្រើននៃលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មផ្សេងទៀត គឺជាខ្សែផលិតកម្ម ដែលម៉ាស៊ីននោះស្ថិតនៅ។ តម្លៃអាចទទួលបានមកវិញនៃខ្សែផលិតកម្មបង្ហាញពីខ្សែផលិតកម្មទាំងមូលមិនត្រូវបានធ្លាក់ចុះតម្លៃ។ |

ការសន្មតទី១÷ គម្រោងថវិកា/ការព្យាករណ៍បានអនុម័តដោយអ្នកគ្រប់គ្រងឆ្លុះបញ្ចាំងពីការមិនបានតាំងចិត្តនៃអ្នកគ្រប់គ្រងដើម្បីជំនួសម៉ាស៊ីន។ តម្លៃអាចទទួលបានមកវិញនៃម៉ាស៊ីនតែឯងមិនអាចត្រូវបានព្យាករណ៍ព្រោះតម្លៃកំពុងប្រើប្រាស់របស់ម៉ាស៊ីននោះ÷

(ក) អាចខុសគ្នាពីតម្លៃសមស្របដកថ្លៃដើម្បីលក់ និង

(ខ)អាចត្រូវបានកំណត់សម្រាប់អង្គភាពរកសាច់ប្រាក់ដែលម៉ាស៊ីនស្ថិតនៅ (ខ្សែផលិតកម្ម)។

ខ្សែផលិតកម្មមិនត្រូវបានធ្លាក់ចុះតម្លៃ។ ដូចនេះ គ្មានការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្ម។ ប៉ុន្តែ អង្គភាពអាចវាយតម្លៃឡើងវិញនូវការរំលស់ប្រចាំគ្រា ឬវិធីសាស្រ្តរំលស់សម្រាប់ម៉ាស៊ីន។ ប្រហែលការរំលស់ប្រចាំគ្រាខ្លី ឬវិធីសាស្រ្តរំលស់លឿនតម្រូវឱ្យឆ្លុះបញ្ចាំងពីការរំពឹងអាយុកាលប្រើប្រាស់នៃម៉ាស៊ីន ឬទម្លាប់នៃអត្ថប្រយោជន៍សេដ្ឋកិច្ចត្រូវបានរំពឹងថាបានប្រើប្រាស់ដោយអង្គភាព។

ការសន្មតទី ២÷ គម្រោងថវិកា/ការព្យាករណ៍ បានអនុម័តដោយអ្នកគ្រប់គ្រងឆ្លុះបញ្ចាំងពីការតាំងចិត្តនៃអ្នកគ្រប់គ្រងដើម្បីជំនួសម៉ាស៊ីន និងលក់ក្នុងពេលអនាគតដ៏ខ្លី។ លំហូរសាច់ប្រាក់បានមកពីការបន្តការប្រើប្រាស់ម៉ាស៊ីនរហូតពេលដែលត្រូវលក់ ត្រូវបានប៉ាន់ស្មានថាមិនធំដុំ។

តម្លៃកំពុងប្រើប្រាស់របស់ម៉ាស៊ីន អាចត្រូវបានប៉ាន់ស្មានប្រហាក់ប្រហែលទៅនឹង

តម្លៃសមស្របដកថ្លៃដើម្បីលក់។ ដូចនេះ តម្លៃអាចទទួលបានមកវិញនៃម៉ាស៊ីន អាចត្រូវបានកំណត់ ហើយមិនគិតលើអង្គភាពរកសាច់ប្រាក់ដែលម៉ាស៊ីនស្ថិតនៅ (ឧទាហរណ៍ ខ្សែផលិតកម្ម)។ ព្រោះតម្លៃសមស្របដកថ្លៃ ដើម្បីលក់របស់ម៉ាស៊ីន តិចជាងតម្លៃក្នុងបញ្ជី ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់។

**១០៨ បន្ទាប់ពីលក្ខខណ្ឌក្នុងកថាខណ្ឌទី ១០៤ និង ១០៥ ត្រូវបានអនុវត្ត បំណុល ត្រូវបានទទួលស្គាល់សម្រាប់តម្លៃនៅសល់នៃការខាតពីការធ្លាក់ចុះតម្លៃ សម្រាប់អង្គភាពរកសាច់ប្រាក់ ប្រសិនបើមិនដូច្នេះ តម្រូវដោយ ស.រ.ហ.អ.ក ផ្សេងទៀត។**

## ការប្រែប្រួលត្រឡប់ការខាតពីការធ្លាក់ចុះតម្លៃ

១០៩ កថាខណ្ឌទី ១១០ -១១៦ កំណត់ពីលក្ខខណ្ឌសម្រាប់ការទទួលការប្រែត្រឡប់ការខាត ពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់នៃទ្រព្យសកម្មមួយ ឬ អង្គភាពរកសាច់ប្រាក់ក្នុងគ្រាមុន។លក្ខខណ្ឌទាំងនេះប្រើពាក្យ (ទ្រព្យសកម្ម) ប៉ុន្តែអនុវត្តដូចគ្នា ទៅនឹងទ្រព្យសកម្មនីមួយៗ ឬអង្គភាពរកសាច់ប្រាក់។ លក្ខខណ្ឌបន្ថែមសម្រាប់ទ្រព្យសកម្មនីមួយៗ ត្រូវបានកំណត់ក្នុងកថាខណ្ឌទី ១១៧-១២១ សម្រាប់អង្គភាពរកសាច់ប្រាក់ក្នុងកថាខណ្ឌទី ១២២ និង ១២៣ និងសម្រាប់មូលនិធិពាណិជ្ជកម្មក្នុងកថាខណ្ឌទី ១២៤ និង ១២៥។

**១១០ អង្គភាពមួយត្រូវវាយតម្លៃនៅចុងគ្រារាយការណ៍នីមួយៗ ពីសញ្ញាណាមួយ ដែលបង្ហាញថាការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ក្នុងគ្រាមុន**

សម្រាប់ទ្រព្យសកម្មមួយមិនមែនមូលនិធិពាណិជ្ជកម្ម អាចមិនមាន ឬត្រូវបានថយចុះ។ ប្រសិនបើមានសញ្ញាណាមួយ អង្គភាពត្រូវប៉ាន់ស្មាន តម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មនោះ។

១១១ ក្នុងការវាយតម្លៃពីសញ្ញាណាមួយបង្ហាញថា ការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ក្នុងគ្រាមុនសម្រាប់ទ្រព្យសកម្មមួយ មិនមែនមូលនិធិពាណិជ្ជកម្ម អាចមិនមាន ឬត្រូវបានថយចុះ អង្គភាពមួយត្រូវពិចារណា សញ្ញាអប្បបរមាដូចខាងក្រោម÷

ប្រភពព័ត៌មានខាងក្រៅ

(ក) តម្លៃទីផ្សារនៃទ្រព្យសកម្មបានកើនឡើងខ្លាំងក្នុងគ្រា។

(ខ) ការផ្លាស់ប្តូរខ្លាំងក្នុងគ្រាដែលមានផលប៉ះពាល់ល្អលើអង្គភាព ឬនឹងកើតឡើងនាពេលអនាគតដ៏ខ្លី ក្នុងបច្ចេកវិទ្យា ទីផ្សារ ឬច្បាប់ ដែលអង្គភាពធ្វើប្រតិបត្តិការ ឬក្នុងទីផ្សារដែលទ្រព្យសកម្មមានគោលបំណងពិសេស។

(គ) អត្រាការប្រាក់ទីផ្សារ ឬអត្រាទីផ្សារនៃចំណូលលើការវិនិយោគផ្សេងទៀត បានថយចុះក្នុងកំឡុងគ្រា ហើយការថយចុះទាំងនោះ ទំនងប៉ះពាល់ ដល់អត្រាអប្បហារបានប្រើក្នុងការគណនាតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្ម និងការកើនឡើងជាសារវន្តនៃតម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្ម។

ប្រភពព័ត៌មានខាងក្នុង

(ឃ) **ការផ្លាស់ប្តូរខ្លាំងក្នុងគ្រាដែលមានផលប៉ះពាល់ល្អលើអង្គភាព ឬរំពឹងថានឹងកើតឡើងនាពេលអនាគតដ៏ខ្លីខាងមុខ ក្នុងទំហំ ឬវិសាលភាពមួយដែលទ្រព្យសកម្មត្រូវបានប្រើឬរំពឹងថាត្រូវប្រើ។ ការផ្លាស់ប្តូរនេះរួមមានការចំណាយកើតឡើងក្នុងកំឡុងគ្រា ដើម្បីធ្វើឱ្យប្រសើរឡើង ឬបង្កើនស្នាដៃរបស់ទ្រព្យសកម្ម ឬការរុះរើប្រតិបត្តិការដែលទ្រព្យសកម្មស្ថិតនៅ។**

(ង) **មានភស្តុតាងពីការរាយការណ៍ខាងក្នុងដែលបង្ហាញថាលទ្ធផលសេដ្ឋកិច្ចនៃទ្រព្យសកម្មថាល្អ ឬនឹងប្រសើរជាងការរំពឹងទុក។**

១១២ សញ្ញាបង្ហាញថាការធ្លាក់ចុះជាសក្តានុពលក្នុងការខាតពីការធ្លាក់ចុះតម្លៃក្នុងកថាខណ្ឌទី១១១ ជាសញ្ញាបង្ហាញនៃការខាតពីការធ្លាក់ចុះជាសក្តានុពលក្នុងកថាខណ្ឌទី ១២។

១១៣ ប្រសិនបើមានសញ្ញាបង្ហាញថាការខាតពីការធ្លាក់ចុះនៃតម្លៃបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មមិនមែនមូលនិធិពាណិជ្ជកម្ម អាចមិនមាន ឬត្រូវបានថយចុះ នេះអាចជាការបង្ហាញអាយុកាល ប្រើប្រាស់នៅសល់វិធីសាស្ត្ររំលស់ ឬតម្លៃកាកសំណល់អាចត្រូវបានពិនិត្យ និងការកែសម្រួលស្របតាម ស.រ.ហ.អ.ក អាចអនុវត្តបានចំពោះទ្រព្យសកម្ម ទោះបីជាគ្មានការខាតពីការធ្លាក់ចុះតម្លៃត្រូវបានប្រែត្រឡប់សម្រាប់ទ្រព្យសកម្ម។

**១១៤ ការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ក្នុងគ្រាមុនសម្រាប់ទ្រព្យសកម្មមិនមែនមូលនិធិពាណិជ្ជកម្មត្រូវបានប្រែត្រឡប់ ប្រសិន មានបើ ការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានបានប្រើក្នុងការកំណត់តម្លៃអាចទទួលបានមកវិញរបស់ទ្រព្យសកម្មចាប់តាំងពីការខាតពីការធ្លាក់ចុះតម្លៃចុងក្រោយត្រូវបានទទួល**

**ស្គាល់។ ក្នុងករណីនេះ តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មត្រូវ លើកលែងតែដូចបាន បរិយាយក្នុងកថាខណ្ឌទី ១១៧ ត្រូវបានកើនឡើង លើសតម្លៃអាចទទួលបាន មកវិញ។ ការកើនឡើងត្រូវបានប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃ។**

១១៥. ការប្រែត្រឡប់ការខាតពីការធ្លាក់ចុះតម្លៃ ឆ្លុះបញ្ចាំងការកើនឡើងក្នុងការប៉ាន់ស្មានសេវាកម្មសក្តានុពល នៃទ្រព្យសកម្មមួយ ទាំងបានមកពីការប្រើប្រាស់ ឬលក់ ចាប់តាំងពីថ្ងៃដែលអង្គភាពមួយបានទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃចុងក្រោយសម្រាប់ទ្រព្យសកម្មនោះ។ កថាខណ្ឌទី ១៣០ តម្រូវឱ្យអង្គភាពមួយកំណត់ការផ្លាស់ប្តូរក្នុងការប៉ាន់ស្មាន ដែលបណ្តាលឱ្យកើនឡើងក្នុងការប៉ាន់ស្មានសេវាកម្មសក្តានុពល។ ឧទាហរណ៍ការផ្លាស់ប្តូរក្នុងការប៉ាន់ស្មាន រួមបញ្ចូល÷

(ក) ការផ្លាស់ប្តូរក្នុងមូលដ្ឋាន សម្រាប់តម្លៃ អាចទទួលបានមកវិញ (ឧទាហរណ៍ តម្លៃអាចទទួលបានមកវិញ គឺផ្អែកលើតម្លៃសមស្រប ដកថ្លៃដើម្បីលក់ ឬតម្លៃកំពុងប្រើប្រាស់)

(ខ) ប្រសិនបើ តម្លៃអាចទទួលបានមកវិញផ្អែកលើតម្លៃកំពុងប្រើប្រាស់ ការផ្លាស់ប្តូរក្នុងតម្លៃ ឬពេលវេលា នៃប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត ឬក្នុងអត្រាអប្បហារ ឬ

(គ) ប្រសិនបើ តម្លៃអាចទទួលបានមកវិញផ្អែកលើតម្លៃសមស្របដកថ្លៃដើម្បីលក់ការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានសមាសធាតុនៃតម្លៃសមស្រប ដកថ្លៃដើម្បីលក់ ។

១១៦ តម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្ម អាចខ្ពស់ជាងតម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្មជាធម្មតាព្រោះថាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ចូលអនាគតកើន

ឡើងប្រហាក់ប្រហែល។ ប៉ុន្តែ សេវាកម្មសក្តានុពលរបស់ទ្រព្យសកម្ម មិនបានកើនឡើង។ ដូចនេះ ការខាតពីការធ្លាក់ចុះតម្លៃមិនត្រូវបានប្រែត្រឡប់ព្រោះតែការកន្លងទៅនៃពេលវេលា (ពេលខ្លះបានហៅថា (ភាពមិនបត់បែន) នៃការអប្បហារ) ទោះបីតម្លៃអាច ទទួលបានមកវិញនៃទ្រព្យសកម្មខ្ពស់ជាងតម្លៃក្នុងបញ្ជី។

**ការប្រែត្រឡប់ការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មនីមួយៗ**

**១១៧ ការកើនឡើងតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មមួយមិនមែនមូលនិធិពាណិជ្ជកម្មចូលរួមទៅការប្រែត្រឡប់ការខាតពីការធ្លាក់ចុះតម្លៃមិនត្រូវលើសពីតម្លៃក្នុងបញ្ជីដែលត្រូវបានកំណត់ (ការលស់សុទ្ធ ឬការលស់) មិនមានការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មក្នុងឆ្នាំមុន។**

១១៨ ការកើនឡើងក្នុងតម្លៃក្នុងបញ្ជី នៃទ្រព្យសកម្មមិនមែនមូលនិធិពាណិជ្ជកម្មខាងលើសពីតម្លៃក្នុងបញ្ជីដែលត្រូវបានកំណត់ (ការរំលស់សុទ្ធឬការរំលស់) ដែលមិនមានការទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មក្នុងឆ្នាំមុនគឺជាការវាយតម្លៃឡើងវិញ។ ក្នុងគណនេយ្យសម្រាប់ការវាតម្លៃឡើងវិញ អង្គភាពត្រូវអនុវត្តតាម ស.រ.ហ.អ.កសម្រាប់ទ្រព្យសកម្ម។

**១១៩ ការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មមិនមែនមូលនិធិពាណិជ្ជកម្មត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងចំណេញ ឬខាតលើកលែងតែទ្រព្យកម្មត្រូវបានអនុវត្តនៅតម្លៃវាយតម្លៃឡើងវិញស្របតាម ស.រ.ហ.អ.ក ផ្សេងទៀត (ឧទាហរណ៍ គំរូវាយតម្លៃឡើងវិញក្នុង ស.គ.អ.ក ១៦)។ ការប្រែត្រឡប់នៃខាតពីការធ្លាក់ចុះតម្លៃនៃតម្លៃទ្រព្យសកម្មបានវាយ**

តម្លៃឡើងវិញត្រូវបានចាត់ទុកជាការកើនឡើងវិញស្របតាម ស.រ.ហ.អ.ក ផ្សេងទៀត។

១២០ ការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃ លើទ្រព្យសកម្មបានវាយតម្លៃឡើងវិញ ត្រូវទទួលស្គាល់ក្នុងចំណេញលម្អិត និងការកើនឡើងការវាយតម្លៃលើសសម្រាប់ទ្រព្យសកម្មនោះ។ ប៉ុន្តែក្នុងន័យថាការខាតពី ការធ្លាក់ចុះតម្លៃទ្រព្យសកម្មដូចបានទទួលស្គាល់លើកមុនក្នុងចំណេញ ឬខាត ការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃគឺត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬ ខាត។

**១២១ បន្ទាប់ពីប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ ការគិតរំលស់ សម្រាប់ទ្រព្យសកម្មត្រូវបានកែតម្រូវក្នុងគ្រាអនាគតទៅ បែងចែកតម្លៃក្នុងបញ្ជីកែត្រូវរបស់ទ្រព្យសកម្មដកតម្លៃកាកសំណល់ (ប្រសិនបើមាន) ផ្អែកលើមូលដ្ឋានជាប្រព័ន្ធទៅលើអាយុកាលប្រើប្រាស់នៅសល់។**

## ការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់អង្គភាពរកសាច់ប្រាក់

១២២ ការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់អង្គភាពរកសាច់ប្រាក់ ត្រូវតែបានបែងចែកទៅទ្រព្យ សកម្មនៃអង្គភាព លើកលែងតែមូលនិធិពាណិជ្ជកម្ម សមាមាត្រជាមួយតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មទាំងនោះ។ ការកើនឡើងតម្លៃក្នុងបញ្ជី ត្រូវបានចាត់ទុកថាជាការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មនីមួយៗ ហើយបានទទួលស្គាល់ស្របតាមកថាខណ្ឌទី ១១៩។

១២៣ ការបែងចែកការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់អង្គភាពរកសាច់ប្រាក់ស្របតាមកថាខណ្ឌទី ១២២ តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មមួយមិនត្រូវបានកើនឡើងលើសតម្លៃទាបជាងនៃ÷

(ក) តម្លៃអាចទទួលបានមកវិញ (ប្រសិនបើអាចកំណត់បាន) និង

(ខ) តម្លៃក្នុងបញ្ជីដែលត្រូវបានកំណត់ (ការរំលស់សុទ្ធ ឬការរំលស់) មិនមានការខាតពីការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ សម្រាប់ទ្រព្យសកម្មក្នុងគ្រាមុន។

តម្លៃនៃការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃដែលបានបែងចែកទៅកាន់ទ្រព្យសកម្មត្រូវបានបែងចែកសមាមាត្រទៅទ្រព្យសកម្មនៃអង្គភាព លើកលែងតែមូលនិធិពាណិជ្ជកម្ម។

### ការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់មូលនិធិពាណិជ្ជកម្ម

១២៤ ការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់សម្រាប់មូលនិធិពាណិជ្ជកម្មមិនត្រូវបានប្រែត្រឡប់ក្នុងគ្រាបន្ទាប់ទេ។

១២៥ ស.គ.អ.ក ៣៨ ទ្រព្យសកម្មអរូបីយហាមឃាត់ការទទួលស្គាល់មូលនិធិពាណិជ្ជកម្មដែលបង្កើតឡើងផ្ទៃក្នុង។ ការកើនឡើងក្នុងតម្លៃអាចទទួលបានមកវិញនៃមូលនិធិពាណិជ្ជកម្មក្នុងគ្រាបន្ទាប់ការទទួលស្គាល់នៃការខាតពីការធ្លាក់ចុះតម្លៃសម្រាប់មូលនិធិពាណិជ្ជកម្ម ទំនងជាកើនឡើងក្នុងមូលនិធិពាណិជ្ជ កម្មដែលបង្កើតឡើងផ្ទៃក្នុង ជាជាងការប្រែត្រឡប់នៃការខាតពីធ្លាក់ចុះតម្លៃបានទទួលស្គាល់សម្រាប់មូលនិធិពាណិជ្ជកម្មដែលទទួបាន។

១២៦ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានសម្រាប់ថ្នាក់នៃទ្រព្យសកម្ម ដូចខាងក្រោម÷

(ក) តម្លៃនៃការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ក្នុងចំណេញ ឬខាតក្នុងកំឡុងគ្រា និងធាតុនៃរបាយការណ៍ចំណេញលម្អិតដែលការខាតពីការធ្លាក់ចុះតម្លៃត្រូវបានបញ្ចូល។

(ខ) តម្លៃនៃការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ក្នុងចំណេញ ឬខាត ក្នុងកំឡុងគ្រា និងធាតុនៃរបាយការណ៍ចំណេញលម្អិតដែលការខាតពីការធ្លាក់ចុះតម្លៃត្រូវបានប្រែត្រឡប់។

(គ) តម្លៃនៃការខាតពីការធ្លាក់ចុះតម្លៃលើទ្រព្យសកម្មបានវាយតម្លៃឡើងវិញបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញលម្អិតក្នុងគ្រា។

(ឃ) តម្លៃនៃការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃលើទ្រព្យសកម្មបានវាយតម្លៃឡើងវិញបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញលម្អិតក្នុងកំឡុងគ្រា។

១២៧ ថ្នាក់នៃទ្រព្យសកម្មគឺការដាក់ជាក្រុមនៃទ្រព្យសកម្មនៃលក្ខណៈស្រដៀងគ្នា និងប្រើប្រាស់ក្នុងប្រតិបត្តិការរបស់អង្គភាព។

១២៨ព័ត៌មានតម្រូវក្នុងកថាខណ្ឌទី ១២៧ អាចត្រូវបានបង្ហាញជាមួយព័ត៌មានដែលត្រូវលាតត្រដាងសម្រាប់ថ្នាក់ទ្រព្យសកម្ម។ ឧទាហរណ៍ ព័ត៌មាននេះអាចត្រូវបានបញ្ចូលក្នុងការសម្របសម្រួលនៃតម្លៃក្នុងបញ្ជីនៃទ្រព្យ រោងចក្រ និងឧបករណ៍ នៅដើម និងចុងគ្រា ដូចមានតម្រូវក្នុង ស.គ.អ.ក ១៦។

១២៩ អង្គភាពមួយដែលរាយការណ៍ព័ត៌មានតាមផ្នែកស្របតាម ស.រ.ហ.អ.ក ៨ ត្រូវបង្ហាញនូវការរាយការណ៍តាមផ្នែកដូចខាងក្រោម÷

(ក) តម្លៃនៃការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ក្នុងចំណេញ ឬខាត និងក្នុងចំណេញលម្អិតក្នុងកំឡុងគ្រា។

(ខ) តម្លៃនៃការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ក្នុងចំណេញ ឬខាត និងក្នុងចំណេញលម្អិតក្នុងកំឡុងគ្រា។

១៣០ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោមសម្រាប់ការខាតពីការធ្លាក់ចុះតម្លៃជាសារវន្តបានទទួលស្គាល់ ឬប្រែត្រឡប់កំឡុងគ្រា សម្រាប់ទ្រព្យសកម្មនីមួយៗ ដោយរួមបញ្ចូលទាំងមូលនិធិពាណិជ្ជកម្ម ឬអង្គភាពរកសាច់ប្រាក់÷

(ក) ព្រឹត្តិការណ៍ និងស្ថានភាពដែលនាំដល់ការទទួលស្គាល់ ឬប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃ។

(ខ) តម្លៃនៃការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ ឬប្រែត្រឡប់។

(គ) សម្រាប់ទ្រព្យសកម្មនីមួយៗ÷

(១) លក្ខណៈរបស់ទ្រព្យសកម្ម និង

(២) ប្រសិនបើអង្គភាពរាយការណ៍ព័ត៌មានតាមផ្នែកស្របតាម ស.រ.ហ.អ.ក ៨ ការរាយការណ៍តាមផ្នែកដែលទ្រព្យសកម្មស្ថិតនៅ។

(ឃ) សម្រាប់អង្គភាពរកសាច់ប្រាក់÷

(១) ការបរិយាយនៃអង្គភាពរកសាច់ប្រាក់ (ដូចជាខ្សែផលិតផល រោងចក្រ ប្រតិបត្តិការអាជីវកម្ម តំបន់តាមភូមិសាស្ត្រ ឬការអាចរាយការណ៍តាមផ្នែក ដូចមានកំណត់ក្នុង ស.រ.ហ.អ.ក ៨)

(២) តម្លៃនៃការខាតពីការធ្លាក់ចុះតម្លៃបានទទួលស្គាល់ ឬប្រែត្រឡប់ដោយថ្នាក់នៃទ្រព្យសកម្ម និងប្រសិនអង្គភាពរាយការណ៍ព័ត៌មានតាមផ្នែក ស្របតាម ស.រ.ហ.អ.ក ៨ ការអាចរាយការណ៍តាមផ្នែក និង

(៣) ប្រសិនបើការសរុបនៃទ្រព្យសកម្មសម្រាប់កំណត់សំគាល់អង្គភាពរកសាច់ប្រាក់បានផ្លាស់ប្តូរចាប់តាំងពីការប៉ាន់ស្មានតម្លៃអាចទទួលបានមកវិញរបស់អង្គភាពរកសាច់ប្រាក់ (ប្រសិនបើមាន) ការបរិយាយនៃការសរុបទ្រព្យសកម្មបច្ចុប្បន្ន និងអតីតកាល និងមូលហេតុសម្រាប់ការផ្លាស់ប្តូរមធ្យោបាយក្នុងការកំណត់អង្គភាពរកសាច់ប្រាក់ត្រូវបាន។

(ង) ពីតម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្ម (អង្គភាពរកសាច់ប្រាក់) គឺជាតម្លៃសមស្របដកថ្លៃដើម្បីលក់ ឬតម្លៃកំពុងប្រើប្រាស់។

(ច) ប្រសិនបើតម្លៃអាចទទួលបានមកវិញគឺជាតម្លៃសមស្របដកថ្លៃ ដើម្បីលក់ មូលដ្ឋានបានប្រើក្នុងការកំណត់តម្លៃសមស្របដកថ្លៃដើម្បីលក់ (ដូចជាតម្លៃសមស្របបានត្រូវបានកំណត់ដោយយោងលើទីផ្សារសកម្ម)។

(ឆ) ប្រសិនបើតម្លៃអាចទទួលបានមកវិញគឺជាតម្លៃកំពុងប្រើប្រាស់ អត្រាអប្បហារបានប្រើក្នុងការប៉ាន់ស្មានតម្លៃកំពុងប្រើប្រាស់បច្ចុប្បន្ន និងពីមុន (ប្រសិនបើមាន)។

១៣១ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម សម្រាប់ការខាតពីការធ្លាក់ចុះតម្លៃសរុប និងការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃសរុបបានទទួលស្គាល់ក្នុងកំឡុងគ្រាសម្រាប់ព័ត៌មានមិនត្រូវបានលាតត្រដាងស្របតាមកថាខណ្ឌទី ១៣០÷

(ក) ថ្នាក់សំខាន់ៗនៃទ្រព្យសកម្មទាំងអស់បានប៉ះពាល់ដោយការខាតពីការធ្លាក់ចុះតម្លៃ និងថ្នាក់សំខាន់ៗនៃទ្រព្យសកម្មបាន ប៉ះពាល់ដោយការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃ។

(ខ) ព្រឹត្តិការណ៍ និងស្ថានភាពសំខាន់ៗ ដែលនាំទៅដល់ការទទួលស្គាល់នៃការខូច ពីការធ្លាក់ចុះតម្លៃ និងការប្រែត្រឡប់នៃការខាតពីការធ្លាក់ចុះតម្លៃ។

១៣២ អង្គភាពមួយត្រូវបានជំរុញឱ្យលាតត្រដាងការសន្មតបានប្រើក្នុងការកំណត់តម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្ម (អង្គភាពរកសាច់ប្រាក់)ក្នុងកំឡុងគ្រា។ ប៉ុន្តែ កថាខណ្ឌទី ១៣៤ តម្រូវឱ្យអង្គភាពមួយលាតត្រដាងព័ត៌មានពីការប៉ាន់ស្មានបាន ប្រើក្នុងការវាស់វែងតម្លៃអាចទទួលបានមកវិញ នៃអង្គភាព រកសាច់ប្រាក់នៅពេលដែលមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់ត្រូវបានបញ្ចូលក្នុងតម្លៃ ក្នុងបញ្ជីនៃអង្គភាពនោះ។

១៣៣ ប្រសិនបើ ស្របតាមកថាខណ្ឌទី៨៤ ចំណែកណាមួយនៃមូលនិធិពាណិជ្ជកម្មទទួលបានក្នុងការបញ្ចូលអាជីវកម្មក្នុងកំឡុងគ្រាមិនត្រូវបានបែងចែកទៅអង្គភាពរកសាច់ប្រាក់ (ក្រុមនៃអង្គភាព) នៅក្នុងគ្រារាយការណ៍ តម្លៃនៃមូលនិធិដែលមិនអាចបែងចែកត្រូវបានលាតត្រដាងព័ត៌មានជាមួយគ្នានឹងមូលហេតុដែលតម្លៃនៅតែមិនអាចបែងចែកបាន។

**ការប៉ាន់ស្មានបានប្រើក្នុងការវាស់វែងតម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់មានមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់**

១៣៤ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានដូចបានតម្រូវដោយ ចំនុច ក-ង សម្រាប់អង្គភាពរកសាច់ប្រាក់(ក្រុមនៃអង្គភាព) សម្រាប់តម្លៃក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយដែលមានអាយុកាលប្រើប្រាស់មិនកំណត់បានបែងចែកទៅអង្គភាព (ក្រុមនៃអង្គភាព) គឺសំខាន់ក្នុងការប្រៀបធៀបជាមួយតម្លៃក្នុងបញ្ជីសរុបរបស់អង្គភាពនៃមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់÷

(ក) តម្លៃក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្មបានបែងចែកទៅអង្គភាព (ក្រុមនៃអង្គភាព)។

(ខ) តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់បានបែងចែកទៅកាន់អង្គភាព (ក្រុមនៃអង្គភាព)។

(គ) មូលដ្ឋានដែលតម្លៃអាចទទួលបានមកវិញអង្គភាព (ក្រុមនៃអង្គភាព) ត្រូវបានកំណត់ (ឧទាហរណ៍តម្លៃកំពុងប្រើប្រាស់ ឬតម្លៃសមស្របដកថ្លៃដើម្បីលក់)។

(ឃ) ប្រសិនបើតម្លៃអាចទទួលបានមកវិញរបស់អង្គភាព (របស់ក្រុមនៃអង្គភាព) គឺផ្អែកលើតម្លៃកំពុងប្រើប្រាស់÷

(១) ការបរិយាយនៃការសន្មតសំខាន់នីមួយៗដែលអ្នកគ្រប់គ្រងប្រើជាមូលដ្ឋានក្នុងការព្យាករណ៍លំហូរសាច់ប្រាក់សម្រាប់គ្រាដែលបានគ្របដណ្តប់ដោយគម្រោងថវិកា និងការព្យាករណ៍ថ្មីៗ។ ការសន្មតសំខាន់ៗគឺជាអ្វីដែលតម្លៃអាចទទួលបានមកវិញរបស់អង្គភាពដែលមានរំញោចបំផុត។

(២) ការបរិយាយនៃវិធីសាស្ត្រដែលអ្នកគ្រប់គ្រងប្រើក្នុងការកំណត់តម្លៃដែលប្រើក្នុងការសន្មតសំខាន់នីមួយៗ ពីតម្លៃទាំងនោះឆ្លុះបញ្ចាំងបទពិសោធន៍អតីតកាល ឬប្រសិនបើសមស្រប ដែលមាននិរន្តភាពជាមួយប្រភពព័ត៌មានខាងក្រៅ ហើយ ប្រសិនបើមិនសមស្របរបៀប និងមូលហេតុដែលមូលហេតុខុសគ្នាពីបទពិសោធន៍អតីតកាល ឬប្រភពព័ត៌មានខាងក្រៅ។

(៣) គ្រាដែលអ្នកគ្រប់គ្រងបានព្យាករណ៍លំហូរសាច់ប្រាក់ផ្អែកលើគម្រោងថវិកា/ការព្យាករណ៍បានអនុម័តដោយអ្នកគ្រប់គ្រង និងគ្រាលើសពីប្រាំឆ្នាំ គឺត្រូវបានប្រើសម្រាប់អង្គភាពរកសាច់ប្រាក់ (ក្រុមនៃអង្គភាព) ការពន្យល់ពីមូលហេតុដែលគ្រាវែងត្រូវបានកែសម្រួល។

(៤) អត្រាកំណើនបានប្រើដើម្បីសរុបលំហូរសាច់ប្រាក់ព្យាករណ៍លើសគ្រាដែលបានគ្របទៅដោយគម្រោងថវិកា/ ការព្យាករណ៍ថ្មីបំផុត និងការកែតម្រូវសម្រាប់ការប្រើអត្រាកំណើនដែលលើសអត្រាកំណើនរយៈពេលវែងមធ្យមសម្រាប់ផលិតផលវិស័យ ឬប្រទេសមួយ ឬប្រទេសច្រើនដែលអង្គភាពប្រតិបត្តិការ ឬសម្រាប់ទីផ្សារដែលអង្គភាព (ក្រុមនៃអង្គភាព) ត្រូវបានប្រើ។

(៥) អត្រាអប្បហារបានប្រើទៅលើលំហូរសាច់ប្រាក់ព្យាករណ៍។

(ង) ប្រសិនបើតម្លៃអាចទទួលបានមកវិញនៃអង្គភាព (របស់ក្រុមនៃអង្គភាព) ផ្អែកលើមូលដ្ឋានលើតម្លៃសមស្របដកថ្លៃដើម្បីលក់វិធីសាស្ត្របានប្រើដើម្បីកំណត់តម្លៃសមស្របដកថ្លៃដើម្បីលក់។ ប្រសិនបើតម្លៃសមស្របដកថ្លៃដើម្បីលក់មិនអាចត្រូវបានកំណត់ដោយប្រើប្រាស់ថ្លៃទីផ្សារដែលអាចអង្កេតបានសម្រាប់អង្គភាព (ក្រុមនៃអង្គភាព) ត្រូវលាតត្រដាងព័ត៌មានខាងក្រោម÷

(១) ការបរិយាយនៃការសន្មតសំខាន់នីមួយៗដែលដែលអ្នកគ្រប់គ្រងប្រើជាមូលដ្ឋានក្នុងការកំណត់តម្លៃសមស្របដកថ្លៃដើម្បីលក់។ ការសន្មតសំខាន់ៗគឺអ្វីដែលតម្លៃអាចទទួលបានមកវិញរបស់អង្គភាព (របស់ក្រុមនៃអង្គភាព) ដែលមានវិញ្ញោចបំផុត។

(២) ការបរិយាយនៃវិធីសាស្ត្រដែលអ្នកគ្រប់គ្រងប្រើក្នុងការកំណត់តម្លៃ (ឬតម្លៃ) ប្រើទៅលើការសន្មតពីតម្លៃទាំងនោះឆ្លុះបញ្ចាំងបទពិសោធន៍អតីតកាលឬប្រសិនបើសមស្របត្រូវមាននិរន្តភាព

ជាមួយប្រភពព័ត៌មានខាងក្រៅ និងប្រសិនបើមិនសមស្រប របៀប និងមូលហេតុដែលខុសគ្នាពីបទពិសោធន៍អតីតកាល ឬប្រភពព័ត៌មានខាងក្រៅ។

ប្រសិនបើតម្លៃសមស្របដកថ្លៃដើម្បីលក់ត្រូវបានកំណត់ដោយប្រើអត្រាអប្បហារលំហូរសាច់ប្រាក់ព្យាករណ៍ ត្រូវលាតត្រដាងព័ត៌មានខាងក្រោម÷

(៣) គ្រាដែលអ្នកគ្រប់គ្រងបានព្យាករណ៍លំហូរសាច់ប្រាក់។

(៤) អត្រាកំណើនបានប្រើដើម្បីសរុបលំហូរសាច់ប្រាក់ព្យាករណ៍។

(៥) អត្រាអប្បហារបានប្រើលើលំហូរសាច់ប្រាក់ការព្យាករណ៍។

(ច) ប្រសិនបើផ្លាស់ប្តូរសមហេតុផលក្នុងការសន្មតសំខាន់ៗដែលអ្នកគ្រប់គ្រងបានប្រើក្នុងការកំណត់តម្លៃអាចទទួលបានមកវិញរបស់អង្គភាព (របស់ក្រុមនៃអង្គភាព)អាចបណ្តាលឱ្យតម្លៃក្នុងបញ្ជីរបស់អង្គភាព (របស់ក្រុមនៃអង្គភាព) លើសពីតម្លៃអាចទទួលបានមកវិញ÷

(១) តម្លៃនៃតម្លៃអាចទទួលបានមកវិញរបស់អង្គភាព (របស់ក្រុមនៃអង្គភាព)លើសពីតម្លៃក្នុងបញ្ជី។

(២) តម្លៃដែលបានប្រើលើការសន្មតសំខាន់។

(៣) តម្លៃដែលត្រូវបានប្រើលើការសន្មតសំខាន់ៗត្រូវផ្លាស់ប្តូរបន្ទាប់ពីការកើតឡើងនូវផលប៉ះពាល់ណាមួយដែលផ្លាស់ប្តូរលើអថេរផ្សេងៗបានប្រើក្នុងការវាស់វែងតម្លៃអាចទទួលបានមកវិញបាន ក្នុងគោលបំណងសម្រាប់តម្លៃអាចទទួលបានមកវិញត្រូវស្មើគ្នាទៅនឹងតម្លៃក្នុងបញ្ជីរបស់អង្គភាព (របស់ក្រុមនៃអង្គភាព)។

១៣៥ ប្រសិនបើតម្លៃក្នុងបញ្ជីខ្លះ ឬទាំងអស់នៃមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់ត្រូវបានបែងចែកទៅគ្រប់ទាំងអស់នៃអង្គភាពរកសាច់ប្រាក់ (ក្រុមនៃអង្គភាព) ហើយតម្លៃដែលបានបែងចែកទៅគ្រប់អង្គភាព (ក្រុមនៃអង្គភាព)គឺមិនសំខាន់ក្នុងការប្រៀបធៀបជាមួយតម្លៃក្នុងបញ្ជីសរុបរបស់អង្គភាព នៃមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់ ការពិតត្រូវលាតត្រដាងជាមួយគ្នានឹងតម្លៃក្នុងបញ្ជីសរុបនៃមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់បានបែងចែកទៅអង្គភាពទាំងនោះ (ក្រុមនៃអង្គភាព)។ បន្ថែមពីនេះ ប្រសិនបើតម្លៃអាចទទួលបានមកវិញនៃអង្គភាពណាមួយ (ក្រុមនៃអង្គភាព) ត្រូវបានផ្អែកលើការសន្មតដូចគ្នា ហើយតម្លៃក្នុងបញ្ជីសរុបនៃមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់បានបែងចែកទៅ អង្គភាព គឺសំខាន់ក្នុងការប្រៀបធៀបជាមួយតម្លៃក្នុងបញ្ជីសរុបនៃមូលនិធិពាណិជ្ជកម្ម ឬទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានការពិតជាមួយគ្នា÷

(ក) តម្លៃក្នុងបញ្ជីសរុបនៃមូលនិធិពាណិជ្ជកម្មបានបែងចែកទៅអង្គភាពទាំងនោះ (ក្រុមនៃអង្គភាព)។

(ខ) តម្លៃក្នុងបញ្ជីសរុបនៃទ្រព្យសកម្មអរូបីយជាមួយអាយុកាលប្រើប្រាស់មិនកំណត់បានបែងចែកទៅអង្គភាពទាំងនោះ (ក្រុមនៃអង្គភាព)។

(គ) ការបរិយាយនៃការសន្មតសំខាន់ៗ។

(ឃ) ការបរិយាយនៃវិធីសាស្ត្រដែលអ្នកគ្រប់គ្រងប្រើដោយក្នុងការកំណត់តម្លៃប្រើទៅលើការសន្មតសំខាន់ៗ ពីតម្លៃទាំងនោះឆ្លុះបញ្ចាំងបទពិសោធន៍អតីតកាល ឬប្រសិនសមស្រប គឺមាននិរន្តភាពជាមួយប្រភពព័ត៌មានខាងក្រៅ ឬប្រសិនមិនសមស្រប របៀប និងមូលហេតុដែលខុសគ្នាពីបទពិសោធន៍អតីតកាល ឬប្រភពព័ត៌មានខាងក្រៅ។

(ង) ប្រសិនផ្លាស់ប្តូរហេតុផល ក្នុងការសន្មតសំខាន់ដែលបណ្តាលឱ្យតម្លៃក្នុងបញ្ជីសរុបរបស់អង្គភាព (របស់ក្រុមនៃអង្គភាព) លើសពីតម្លៃអាចទទួលបានមកវិញសរុប÷

(១) តម្លៃដែលតម្លៃអាចទទួលបានមកវិញសរុបរបស់អង្គភាព (របស់ក្រុមនៃអង្គភាព) លើសពីតម្លៃក្នុងបញ្ជីសរុប។

(២) តម្លៃបានប្រើទៅលើការសន្មតសំខាន់ៗ។

(៣) តម្លៃដែលបានប្រើទៅលើការសន្មតសំខាន់ៗត្រូវផ្លាស់ប្តូរបន្ទាប់ពីការកើតឡើងដែលប៉ះពាល់ការផ្លាស់ប្តូរលើអថេរណាមួយបានប្រើក្នុងការវាស់វែងតម្លៃអាចទទួលបានមកវិញ ក្នុងគោលបំណងសម្រាប់តម្លៃអាចទទួលបានមកវិញសរុបរបស់អង្គភាព (របស់ក្រុមនៃអង្គភាព)ត្រូវស្មើគ្នានឹងតម្លៃក្នុងបញ្ជីនៃអង្គភាព។

១៣៦ ការគណនាលម្អិតថ្មីបំផុតដែលបានធ្វើក្នុងគ្រាមុននៃតម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់(ក្រុមនៃអង្គភាព) អាចស្របតាម កថាខណ្ឌទី ២៤ ឬ ៩៩ ត្រូវបន្ត និងបានប្រើក្នុងការធ្វើតេស្តការធ្លាក់ចុះតម្លៃសម្រាប់អង្គភាព (ក្រុមនៃអង្គភាព) ក្នុងគ្រាបច្ចុប្បន្ន ដែលបានអនុវត្តទៅតាម

លក្ខខណ្ឌ។ នៅក្នុងករណីនេះ ព័ត៌មានសម្រាប់អង្គភាព (ក្រុមនៃអង្គភាព) ដែលត្រូវលាតត្រដាងព័ត៌មានតម្រូវក្នុងកថាខណ្ឌទី ១៣៤ និង ១៣៥ ពាក់ព័ន្ធនឹងការបន្តការគណនាតម្លៃអាចទទួលបានមកវិញ។

១៣៧ បង្ហាញឧទាហរណ៍ ទី ៩ បង្ហាញការលាតត្រដាងព័ត៌មានតម្រូវដោយកថាខណ្ឌទី ១៣៤ និង ១៣៥។

## សំវិធានធនអន្តរកាល និងថ្ងៃចូលជាធរមាន

១៣៨ លុបចោល

១៣៩ អង្គភាពមួយត្រូវអនុវត្តស្តង់ដានេះ÷

(ក) ទៅលើមូលនិធិពាណិជ្ជកម្ម និងទ្រព្យសកម្មអរូបីយទទួលបានក្នុងការរួមបញ្ចូលអាជីវកម្មសម្រាប់ថ្ងៃកិច្ចសន្យាគឺនៅថ្ងៃ ឬបន្ទាប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៤ និង

(ខ) ទៅលើទ្រព្យសកម្មទាំងអស់អនុវត្តអនាគត ចាប់ផ្តើមប្រចាំឆ្នាំ ទី១ ចាប់ផ្តើមនៅ ឬបន្ទាប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៤។

១៤០ អង្គភាពដែលតម្រូវក្នុងកថាខណ្ឌទី ១៣៩ ត្រូវបានជំរុញឱ្យអនុវត្តលក្ខខណ្ឌក្នុងស្តង់ដានេះ មុនពេលថ្ងៃចូលជាធរមាន បានបញ្ជាក់ក្នុងកថាខណ្ឌទី ១៣៩។ ប៉ុន្តែ ប្រសិនបើអង្គភាពមួយអនុវត្តស្តង់ដានេះមុនពេលថ្ងៃចូលជាធរមាន ក៏ត្រូវអនុវត្ត ស.រ.ហ.អ.ក ៣ និង ស.គ.អ.ក ៣៨ (ដែលបានកែប្រែក្នុងឆ្នាំ ២០០៤)នៅគ្រាដូចគ្នា។

១៤០ក ស.គ.អ.ក១ ការបង្ហាញព័ត៌មានហិរញ្ញវត្ថុ (ដែលបានកែប្រែក្នុងឆ្នាំ២០០៧) បានធ្វើវិសោធនកម្មពាក្យបច្ចេកទេសប្រើ ស.រ.ហ.អ.ក ទាំងមូល។

បន្ថែមពីនេះ បានធ្វើវិសោធនកម្មក្នុងកថាខណ្ឌទី ៦១ ១២០ ១២៦ និង ១២៩។ អង្គភាពមួយត្រូវអនុវត្តការធ្វើវិសោធនកម្មទាំងនោះសម្រាប់គ្រាប្រចាំឆ្នាំចាប់ផ្តើមនៅ ឬបន្ទាប់ពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាពមួយអនុវត្ត ស.គ.អ.ក ១ (បានកែប្រែក្នុងឆ្នាំ ២០០៧) សម្រាប់គ្រាមុន ការធ្វើវិសោធនកម្មត្រូវអនុវត្តសម្រាប់គ្រាមុន។

១៤០ខស.រ.ហ.អ.ក ៣ (ដែលបានកែប្រែក្នុងឆ្នាំ២០០៨) បានធ្វើវិសោធនកម្មកថាខណ្ឌទី ៦៥ ៨១ ៨៥ និង ១៣៩ បានលុបចោលកថាខណ្ឌទី ៩១-៩៥ និង ១៣៨ ហើយបានបន្ថែមឧបសម្ព័ន្ធ គ។ អង្គភាពមួយត្រូវអនុវត្តការធ្វើវិសោធនកម្មទាំងនោះសម្រាប់គ្រាប្រចាំឆ្នាំចាប់ផ្តើមនៅ ឬបន្ទាប់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាពមួយអនុវត្ត ស.រ.ហ.អ.ក ៣ (បានកែប្រែក្នុង ឆ្នាំ២០០៨)សម្រាប់ការរាយការណ៍គ្រាមុនការធ្វើវិសោធ-នកម្មត្រូវតែបានអនុវត្តសម្រាប់គ្រាមុន។

១៤០គកថាខណ្ឌទី ១៣៤ (ង) ត្រូវបានធ្វើវិសោធនកកម្មដោយបង្កើនទៅ ស.រ.ហ.គ.ក បានបោះផ្សាយក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពមួយត្រូវអនុវត្តការធ្វើវិសោធនកម្មសម្រាប់គ្រាប្រចាំឆ្នាំចាប់ផ្តើមនៅ ឬបន្ទាប់ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុនក៏ត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយអនុវត្តធ្វើវិសោធនកម្មសម្រាប់គ្រាមុនវា ត្រូវបានលាតត្រដាងព័ត៌មានពិត។

១៤០ឃចំណាយនៃការវិនិយោគក្នុងបុត្រសម្ព័ន្ធ អង្គភាពគ្រប់គ្រងរួមគ្នា ឬញាតិសម្ព័ន្ធ (ធ្វើវិសោធនកម្មទៅលើ ស.រ.ហ.អ.ក ១ ការអនុវត្តដំបូងនៃការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងស.គ.អ.ក ២៧) បាន

បោះផ្សាយក្នុងខែឧសភា ឆ្នាំ២០០៨ បានបន្ថែមក្នុងកថាខណ្ឌទី ១២ (ជ)។ អង្គភាពមួយត្រូវអនុវត្ត ការធ្វើវិសោធនកម្មបន្ទាប់សម្រាប់គ្រាប្រចាំឆ្នាំចាប់ផ្តើម ឬបន្ទាប់ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុនក៏ត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយអនុវត្តការធ្វើវិសោធនកម្មដែលពាក់ព័ន្ធក្នុងកថាខណ្ឌទី ៤ និង ៣៨ ក នៃស.គ.អ.ក ២៧ សម្រាប់គ្រាមុន វាត្រូវបានអនុវត្តការធ្វើវិសោធនកម្មក្នុងកថាខណ្ឌទី ១២ (ជ) នៅពេលដូចគ្នា។

១៤០ងការបង្កើនទៅជា ស.រ.ហ.អ.ក បានបោះផ្សាយក្នុង ខែមេសា ឆ្នាំ២០០៩ បានធ្វើវិសោធនកម្មកថាខណ្ឌទី ៨០ (ខ)។ អង្គភាពមួយអនុវត្តការធ្វើវិសោធនកម្មទៅអនាគតសម្រាប់គ្រាប្រចាំឆ្នាំចាប់ផ្តើមនៅ ឬបន្ទាប់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១០។ ការអនុវត្តមុនក៏ត្រូវបានអនុញ្ញាត។ ប្រសិនបើអង្គភាពមួយអនុវត្តការធ្វើវិសោធនកម្មសម្រាប់គ្រាមុនត្រូវលាតត្រដាងព័ត៌មានពិត។

១៤០ច លុបចោល

១៤០ជ ស.រ.ហ.អ.ក ៩ បានបោះផ្សាយក្នុង ខែតុលា ឆ្នាំ២០១០ បានធ្វើវិសោធនកម្មកថាខណ្ឌទី ២ (ង) និងកថាខណ្ឌ ៥ និងលុបចោលកថាខណ្ឌទី ១៤០(ច)។ អង្គភាពមួយត្រូវអនុវត្តការធ្វើវិសោធនកម្មទាំងនោះនៅពេលអនុវត្ត ស.រ.ហ.អ.ក ៩ បានបោះផ្សាយក្នុងខែតុលា ឆ្នាំ២០១០។

## ការដកចេញនៃ ស.គ.អ.ក ៣៦ (បានបោះផ្សាយ ក្នុងឆ្នាំ ១៩៩៨)

១៤១ស្តង់ដានេះ ជំនួស ស.គ.អ.ក ៣៦ ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្ម (បានបោះ ផ្សាយក្នុងឆ្នាំ ១៩៩៨)។

## ឧបសម្ព័ន្ធ ក
## ការប្រើប្រាស់បច្ចេកទេសតម្លៃបច្ចុប្បន្នដើម្បីវាស់វែងតម្លៃកំពុងប្រើប្រាស់

ឧបសម្ព័ន្ធនេះរួមបញ្ចូលផ្នែកនៃស្តង់ដា។ វាផ្តល់គោលការណ៍ប្រើបច្ចេក-ទេស តម្លៃបច្ចុប្បន្នក្នុងការវាស់វែងតម្លៃកំពុងប្រើប្រាស់។ ទោះបីការប្រើប្រាស់ក្នុងពាក្យ (ទ្រព្យសកម្ម) អនុវត្តស្មើគ្នាទៅក្រុមនៃទ្រព្យសកម្មក្នុងការបង្កើតអង្គភាពរកសាច់ប្រាក់។

## សមាសធាតុនៃការវាស់វែងតម្លៃបច្ចុប្បន្ន

ក១ ធាតុខាងក្រោមផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចភាពខុសគ្នានៃទ្រព្យសកម្ម÷

(ក) ការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត ឬករណីស្មុគស្មាញខ្លាំង សេរីនៃលំហូរសាច់ប្រាក់អនាគត ដែលអង្គភាពរំពឹងទទួលបាន ពីទ្រព្យសកម្ម

(ខ) ការរំពឹងទុកពីអថេរក្នុងតម្លៃ ឬពេលវេលានៃលំហូរសាច់ប្រាក់

(គ) តម្លៃពេលវេលានៃលុយ តំណាងឱ្យអត្រាការប្រាក់ទីផ្សារបច្ចុប្បន្នគ្មានហានិភ័យ

(ឃ) ថ្លៃដែលបានពីការមិនប្រាកដប្រជាក្នុងទ្រព្យសកម្ម និង

(ង) កត្តាផ្សេងៗ មិនអាចកំណត់បាន (ដូចជាភាពមិនអាចប្តូរជាសាច់ប្រាក់) ដែលអ្នកចូលរួមទីផ្សារដែលអាចឆ្លុះបញ្ចាំងក្នុងថ្លៃលំហូរសាច់ប្រាក់អនាគតដែលអង្គភាពរំពឹងទទួលបានពីទ្រព្យសកម្ម។

ក២ ឧបសម្ព័ន្ធនេះផ្ដុយពីវិធីសាស្ត្រពីរក្នុងការគណនាតម្លៃបច្ចុប្បន្ន ទាំងត្រូវបានប្រើប៉ាន់ស្មានតម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្ម អាស្រ័យទៅលើស្ថានភាព។ ក្រោមវីធីសាស្ត្រចាស់ ការកែតម្រូវសម្រាប់កត្តា (ខ)-(ង) បានបរិយាយក្នុងកថាខណ្ឌ ក១ ត្រូវបានជាប់ក្នុងអត្រាអប្បហារ។ ក្រោមវីធីសាស្ត្រ (លំហូរសាច់ប្រាក់រំពឹងទុក) កត្តា (ខ) (ឃ) និង (ង) បណ្ដាលឱ្យមានការកែតម្រូវក្នុងការទទួលបានលំហូរសាច់ប្រាក់រំពឹងទុកកែតម្រូវជាមួយហានិ-ភ័យ។ ការប្រើវិធីសាស្ត្រណាមួយ អង្គភាពមួយជ្រើសយកក្នុងការឆ្លុះបញ្ចាំងការរំពឹងទុកពី អថេរក្នុងតម្លៃ ឬពេលវេលា នៃលំហូរសាច់ប្រាក់អនាគតលទ្ធផលត្រូវតែឆ្លុះបញ្ចាំង ពីការរំពឹងទុកតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគត ឧទាហរណ៍ ទំងន់មធ្យមនៃគ្រប់លទ្ធផលទាំងអស់។

## គោលការណ៍ទូទៅ

ក៣ បច្ចេកទេសប្រើប្រាស់ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់អនាគត និងអត្រាការប្រាក់ នឹងត្រូវផ្លាស់ប្ដូរពីស្ថានភាពមួយទៅស្ថានភាពមួយអាស្រ័យទៅលើស្ថានភាពជុំវិញទ្រព្យសកម្ម។ ប៉ុន្តែ គោលការណ៍ទូទៅ ខាងក្រោមអនុវត្តបច្ចេកទេសក្នុងការវាស់វែងទ្រព្យសកម្ម÷

ក អត្រាការប្រាក់ប្រើក្នុងការអប្បហារលំហូរសាច់ប្រាក់គួរឆ្លុះបញ្ចាំងការសន្មតដែលមាននិរន្តភាពជាមួយអីពាក់ព័ន្ធក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់។ ម្យ៉ាងវិញទៀត ការប៉ះពាល់ការសន្មតខ្លះដែលនឹងត្រូវរាប់ស្ទួន ឬមិនគិត។ ឧទាហរណ៍ អត្រាអប្បហារ ១២ ភាគរយ អាចត្រូវបានអនុវត្តទៅលើកាតព្វកិច្ចលំហូរសាច់ប្រាក់នៃបំណុល ដែល

អាចទទួល។ អត្រានោះឆ្លុះបញ្ចាំងការរំពឹងទុកពីការខូចខាតអនាគតពីបំណុលជាមួយចារីកលក្ខណៈជាក់លាក់។ អត្រា ១២ភាគរយ មិនគួរត្រូវបានធ្វើអប្បហារលំហូរសាច់ប្រាក់អនាគតរំពឹងទុក ព្រោះថាលំហូរសាច់ប្រាក់ទាំងនោះបានឆ្លុះបញ្ចាំងពីការសន្មតពីការខូចខាតអនាគតរួចហើយ។

(ខ) ការប៉ាន់ស្មានលំហូរសាច់ប្រាក់ និងអត្រាអប្បហារគួរត្រូវដកចេញទាំងភាពលំអៀង និងកត្តាដែលមិនពាក់ព័ន្ធទៅនឹងទ្រព្យសកម្ម។ ឧទាហរណ៍ ការគិតទុកជាមុន ការប៉ាន់ស្មានលំហូរសាច់ប្រាក់សុទ្ធដើម្បីបង្កើនលទ្ធភាពចំនេញអនាគតនៃទ្រព្យសកម្មមួយ ដោយយកការវាស់វែងលំអៀង។

(គ) ការប៉ាន់ស្មានលំហូរសាច់ប្រាក់ ឬអត្រាអប្បហារ គួរឆ្លុះបញ្ចាំងពីលទ្ធផលដែលអាចកើតមានជាជាងអ្វីដែលទំនងនឹងកើតមានតែមួយតម្លៃអប្បបរមា ឬអតិប្បរមា។

## វិធីសាស្ត្រចាស់ និងវិធីសាស្ត្រការរំពឹងលំហូរសាច់ប្រាក់នៅតម្លៃបច្ចុប្បន្ន

### វិធីសាស្ត្រចាស់

ក៤ ការអនុវត្តគណនេយ្យនៃតម្លៃបច្ចុប្បន្នពីមុនត្រូវបានប្រើប៉ាន់ស្មានលំហូរសាច់ប្រាក់ និងអត្រាអប្បហារតែមួយ បានបរិយាយជាញឹកញាប់ជា (អត្រាប្រហាក់ប្រហែលជាមួយហានិភ័យ)។ ការប៉ះពាល់ វិធីសាស្ត្របុរាណសន្មតថាការផ្លាស់ប្តូរអត្រាអប្បហារអាចបង្កើតការរំពឹងទុកទាំងអស់ពីលំហូរសាច់

ប្រាក់អនាគត និងបុព្វលាភហានិភ័យសមស្រប។ ដូចនេះ វិធីសាស្ត្រចាស់យកចិត្តទុកដាក់លើការជ្រើសរើសអត្រាអប្បហារ។

ក៥ នៅក្នុងស្ថានភាពខ្លះ ដែលទ្រព្យសកម្មអាចប្រៀបធៀបបានត្រូវបានអង្កេតក្នុងទីផ្សារ វិធីសាស្ត្រចាស់គឺងាយស្រួលក្នុងការអនុវត្ត។ សម្រាប់ទ្រព្យសកម្មជាមួយកិច្ចសន្យាលំហូរសាច់ប្រាក់ គឺមាននិរន្តភាពជាមួយឥរិយាបទក្នុងទីផ្សារ ដែលអ្នកចូលរួមបរិយាយទ្រព្យសកម្ម ដូចក្នុង (១២ភាគរយ នៃបំណុល)។

ក៦ ប៉ុន្តែ វីធីសាស្ត្រចាស់អាចមិនសមស្របក្នុងការវាស់វែងបញ្ហាដែលស្មុគស្មាញដូចជាការវាស់វែងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសម្រាប់ដែលមិនមានធាតុឬធាតុសម្រាប់ប្រៀបធៀបបាន។ ការស្រាវជ្រាវដ៏សមស្របសម្រាប់ (អត្រាប្រហាក់ប្រហែល ជាមួយហានិភ័យ) តម្រូវឱ្យមានការវិភាគយ៉ាងហោចណាស់ពីរធាតុ (ទ្រព្យសកម្មមួយដែលមានក្នុងទីផ្សារ និងអត្រាការប្រាក់អាចអង្កេតបាន និងទ្រព្យសកម្មដែលត្រូវវាស់វែង)។ អត្រាអប្បហារសមស្របសម្រាប់ការវាស់វែង លំហូរសាច់ប្រាក់ ត្រូវតែយោងពីអត្រាការប្រាក់អាចអង្កេតបាននៃទ្រព្យសកម្មនោះ។ ដើម្បីយកមកយោងបាន លក្ខណៈនៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មផ្សេងទៀតត្រូវតែស្រដៀងគ្នាទៅនឹងទ្រព្យសកម្មដែលត្រូវបានវាស់វែង។ ដូចនេះ អ្នកវាស់វែងត្រូវអនុវត្ត ដូចខាងក្រោម÷

(ក) កំណត់កញ្ចប់នៃលំហូរសាច់ប្រាក់ដែលនឹងត្រូវធ្វើអប្បហារ

(ខ) កំណត់ទ្រព្យសកម្មផ្សេងមួយទៀត នៅក្នុងទីផ្សារដែលមានលក្ខណៈលំហូរសាច់ប្រាក់ប្រហាក់ប្រហែលគ្នា

(គ) ប្រៀបធៀបកញ្ចប់លំហូរសាច់ប្រាក់ពីឯកតាពីរដើម្បីប្រាកដថាវាមានលក្ខណៈប្រហាក់ប្រហែលគ្នា (ឧទាហរណ៍ ទាំងកញ្ចប់កិច្ចសន្យាលំហូរសាច់ប្រាក់ ឬមួយកិច្ចសន្យាមួយនិងការប៉ាន់ស្មានលំហូរសាច់ប្រាក់ផ្សេងទៀត)

(ឃ) វាយតម្លៃពីធាតុដែលមានក្នុងធាតុមួយដែលមិនបង្ហាញក្នុងធាតុមួយផ្សេទៀត (ឧទាហរណ៍ ភាពមិនអាចប្តូរជាសាច់ប្រាក់ជាងធាតុដទៃទៀត) និង

(ង) វាយតម្លៃពីលំហូរសាច់ប្រាក់ទាំងពីរអាចមានលក្ខណៈ (ឧទាហរណ៍ ផ្លាស់ប្តូរ) ប្រហាក់ប្រហែលគ្នាក្នុងការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច។

## វិធីសាស្ត្រលំហូរសាច់ប្រាក់រំពឹងទុក

ក៧ វិធីសាស្ត្រលំហូរសាច់ប្រាក់រំពឹងទុក ក្នុងស្ថានភាពខ្លះ គឺជាឧបករណ៍វាស់វែងដ៏មានប្រសិទ្ធភាពជាងវិធីសាស្ត្រចាស់។ ក្នុងការអភិវឌ្ឍន៍ការវាស់វែងវិធីសាស្ត្រលំហូរសាច់ប្រាក់រំពឹងទុកប្រើគ្រប់ការរំពឹងទុកគ្រប់លទ្ធភាពទាំងអស់នៃលំហូរសាច់ប្រាក់ជំនួសលំហូរសាច់ប្រាក់តែមួយ។ ឧទាហរណ៍ លំហូរសាច់ប្រាក់អាចជា សីយូ ១០០ សីយូ ២០០ ឬសីយូ៣០០ ជាមួយនឹងភវនីយភាព ១០ ភាគរយ ៦០ភាគរយ និង ៣០ ភាគរយ រៀងគ្នា។ លំហូរសាច់ប្រាក់រំពឹងទុកគឺសីយូ ២២០។ វិធីសាស្ត្រលំហូរសាច់ប្រាក់រំពឹងទុកខុសគ្នាពីវិធីសាស្ត្រចាស់ដោយផ្តោតទៅលើការវិភាគផ្ទាល់នៃលំហូរសាច់ប្រាក់និងរបាយការណ៍ជាក់លាក់នៃការសន្មតប្រើក្នុងការវាស់វែង។

ក៨ វិធីសាស្ត្រលំហូរសាច់ប្រាក់រំពឹងទុក ក៏អនុញ្ញាតឱ្យប្រើ បច្ចេកទេសតម្លៃបច្ចុប្បន្ននៅពេលវេលានៃលំហូរសាច់ប្រាក់មិនប្រាកដប្រជា។ ឧទាហរណ៍ លំហូរសាច់ប្រាក់សីយូ១.០០០អាចត្រូវបានទទួលបានក្នុងឆ្នាំ ទីមួយ ឆ្នាំទីពីរ ឬឆ្នាំទីបី ជាមួយភវនីយភាព ១០ ភាគរយ ៦០ ភាគរយ និង ៣០ ភាគរយ រៀងគ្នា។ ឧទាហរណ៍ ខាងក្រោមបង្ហាញពីការគណនាតម្លៃបច្ចុប្បន្នរំពឹងទុកក្នុងស្ថានភាពនោះ។

| | | |
|---|---|---|
| តម្លៃបច្ចុប្បន្ននៃ សីយូ ១.០០០ ក្នុងឆ្នាំ ទីមួយ នៅអត្រា ៥% | សីយូ៩៥២.៣៨ | |
| ភវនីយភាព | ១០.០០% | សីយូ ៩៥.២៤ |
| តម្លៃបច្ចុប្បន្ននៃសីយូ១.០០០ ក្នុងឆ្នាំ ទីពីរ នៅអត្រា ៥.២៥% | សីយូ៩០២.៧៣ | |
| ភវនីយភាព | ៦០.០០% | សីយូ៥៤១.៦៤ |
| តម្លៃបច្ចុប្បន្ននៃសីយូ១.០០០ ក្នុងឆ្នាំ ទីបី នៅអត្រា ៥.៥០% | សីយូ៨៥១.៦១ | |
| ភវនីយភាព | ៣០.០០% | សីយូ២៥៥.៤៨ |
| តម្លៃបច្ចុប្បន្នរំពឹងទុក | | សីយូ ៨៩២.៣៦ |

ក៩ តម្លៃបច្ចុប្បន្នរំពឹងទុកនៃសីយូ ៨៩២.៣៦ ខុសគ្នាពីវិធីសាស្ត្រចាស់នៃការប៉ាន់ស្មាននៃសីយូ ៩០២.៧៣ (ភវនីយភាព ៦០ ភាគរយ)។ ការគណនាតម្លៃបច្ចុប្បន្នចាស់អនុវត្តក្នុង ឧទាហរណ៍នេះ តម្រូវឱ្យមានការសម្រេចចិត្ត ពីលទ្ធភាពពេលវេលាលំហូរសាច់ប្រាក់ប្រើ មិនឆ្លុះបញ្ចាំង

ភនីយភាពនៃពេលវេលា។ ព្រោះថាអត្រាអប្បហារ ក្នុងការគណនាតម្លៃបច្ចុប្បន្នចាស់មិនឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជានៃពេលវេលា។

ក១០ ការប្រើប្រាស់ភនីយភាពគឺធាតុដ៏សំខាន់នៃវិធីសាស្ត្រលំហូរសាច់ប្រាក់រំពឹងទុក។ មានសំនួរខ្លះចោទសួរពីការបែងចែកភវនីយភាព ទៅការប៉ាន់ស្មានដែលមានលក្ខណៈវិនិច្ឆ័យមានលក្ខណៈច្បាស់ជាងការពិតដែលកើតមាន។ ប៉ុន្តែ វិធីសាស្ត្រចាស់ បានអនុវត្តបានត្រឹមត្រូវ (ដូចមានបរិយាយក្នុងកថាខណ្ឌ ក៦) តម្រូវការប៉ាន់ស្មានដូចគ្នា និងការវិនិច្ឆ័យដោយគ្មានការផ្តល់ការគណនាតម្លាភាពនៃវិធីសាស្ត្រតម្លៃបច្ចុប្បន្នរំពឹងទុក។

ក១១ ការអភិវឌ្ឍន៍ក្នុងការអនុវត្តបច្ចុប្បន្នបានបង្កើតធាតុនៃតម្លៃបច្ចុប្បន្នរំពឹងទុកមិនផ្លូវការ។ បន្ថែមពីនេះ គណនេយ្យករជាញឹកញាប់តែងតែប្រឈមមុខតម្រូវការក្នុងការវាស់វែងទ្រព្យសកម្មដោយកំហិតព័ត៌មានអំពីភនីយភាពនៃលំហូរសាច់ប្រាក់។ ឧទាហរណ៍ គណនេយ្យករមួយអាចត្រូវបានប្រឈមនឹងស្ថានភាពដូចខាងក្រោម÷

(ក) តម្លៃប៉ាន់ស្មានធ្លាក់ចុះនៅពេលណាមួយក្នុងចន្លោះពី សីយូ ៥០ និង សីយូ ២៥០ ប៉ុន្តែមិនមានតម្លៃក្នុងចន្លោះណាមួយទំនងជាងមួយណានោះទេ។ ផ្អែកលើការកំហិតព័ត៌មាន ការប៉ាន់ស្មានលំហូរសាច់ប្រាក់រំពឹងទុក គឺសីយូ ១៥០ (៥០ បូក ២៥០/២)។

(ខ) តម្លៃប៉ាន់ស្មានធ្លាក់ចុះនៅពេលណាមួយចន្លោះពី សីយូ ៥០ និង សីយូ ២៥០ ហើយតម្លៃប្រហាក់ប្រហែល គឺសីយូ ១០០។ ប៉ុន្តែភនីយភាពភ្ជាប់ទៅតម្លៃនីមួយៗមិនដឹង។ ផ្អែកលើការកំហិតព័ត៌មាន

ការប៉ាន់ស្មានលំហូរសាច់ប្រាក់រំពឹងទុក គឺសីយូ ១៣៣.៣៣ (៥០ បូក១០០ បូក ២៥០/៣)។

(គ) តម្លៃប៉ាន់ស្មានគឺ សីយូ ៥០ (ភនីយភាព ១០ភាគរយ) សីយូ ២៥០ (ភនីយភាព៣០ភាគរយ) ឬសីយូ១០០ (ភនីយភាព៦០ភាគរយ)។ ផ្អែកលើការកំហិតព័ត៌មាន ការប៉ាន់ស្មានលំហូរសាច់ប្រាក់រំពឹងទុក គឺសីយូ ១៤០ (៥០ គុណ ០.១០) បូក (២៥០គុណ ០.៣០) បូក (១០០ គុណ ០.៦០)។

ក្នុងករណីនីមួយៗ ការប៉ាន់ស្មានលំហូរសាច់ប្រាក់រំពឹងទុក ទំនងអាចផ្ដល់នូវតម្លៃប៉ាន់ស្មាននៃតម្លៃកំពុងប្រើប្រាស់ល្អជាងអប្បបរមា ដែលអាច ឬតម្លៃអតិបរមា។

ក១២ ការអនុវត្តវិធីសាស្ត្រលំហូរសាច់ប្រាក់រំពឹងទុកគឺជាកម្មវត្ថុការកំហិតចំណាយអត្ថប្រយោជន៍។ ក្នុងករណីខ្លះ អង្គភាពមួយអាចទទួលបានទិន្នន័យជាក់លាក់ និងអាចអភិវឌ្ឍន៍ទិដ្ឋភាពលំហូរសាច់ប្រាក់ច្រើន។ ក្នុងករណីខ្លះទៀត អង្គភាពមួយមិនអាចអភិវឌ្ឍន៍ច្រើនជាងរបាយការណ៍ទូទៅពីអថេរនៃការផ្លាស់ប្ដូរលំហូរសាច់ប្រាក់ ដោយគ្មានការកើនឡើងនូវចំណាយបន្ថែមទេ។ អង្គភាពត្រូវសមតុល្យរវាងចំណាយដែលទទួលបានព័ត៌មានបន្ថែមទៅនឹងព័ត៌មានបន្ថែមដែលអាចជឿទុកចិត្តបានទៅនឹងការវាស់វែង។

ក១៣ ខ្លះជឿជាក់ថាបច្ចេកទេសលំហូរសាច់ប្រាក់រំពឹងទុកមិនសមស្របសម្រាប់ការវាស់វែងធាតុមួយ ឬធាតុមួយជាមួយនឹងកំហិតចំនួនលទ្ធផលដែលមាន។ ឧទាហរណ៍មួយនៃទ្រព្យសកម្មជាមួយលទ្ធផលពីរគឺៈ ភនីយភាព ៩០ ភាគរយ ដែលលំហូរសាច់ប្រាក់អាចជា សីយូ ១០ និងភនីយភាព ១០ ភាគរយដែលលំហូរសាច់ប្រាក់អាចជា សីយូ ១.០០០។ គេអង្កេតឃើញថា

លំហូរសាច់ប្រាក់រំពឹងទុកក្នុងឧទាហរណ៍នោះគឺ សីយូ ១០៩ និងរិះគន់ថាលទ្ធផលមិនតំណាងឱ្យទាំងតម្លៃដែលចុងក្រោយអាចត្រូវបានចំណាយ។

ក១៤ ការអះអាងដូចបានបង្ហាញឆ្លុះបញ្ចាំងការអនុវត្តមិនត្រូវគ្នាជាមួយកម្មវត្ថុវាស់វែង។ ប្រសិនបើកម្មវត្ថុមួយត្រូវបានបូកបន្តចំណាយត្រូវបានកើតឡើងលំហូរសាច់ប្រាក់រំពឹងទុកអាចមិនត្រូវផលិតតំណាងឱ្យការប៉ាន់ស្មានសមស្របចំណាយរំពឹងទុកទេ។ ប៉ុន្តែ ស្តង់ដារនេះពាក់ព័ន្ធជាមួយការវាស់វែងតម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មមួយ។ តម្លៃអាចទទួលបានមកវិញនៃទ្រព្យសកម្មក្នុងឧទាហរណ៍នេះមិនមែនជាសីយូ ១០ ទោះបីជាអាចជាលំហូរសាច់ប្រាក់ក៏ដោយ។ នេះព្រោះការវាស់វែងនៃសីយូ ១០ មិនបានបង្កើតភាពមិនប្រាកដប្រជានៃការវាស់វែងនៃលំហូរសាច់ប្រាក់នៃទ្រព្យសកម្ម។ ជំនួសឱ្យភាពមិនប្រាកដប្រជាលំហូរសាច់ប្រាក់ គឺជាភាពប្រាកដប្រជាលំហូរសាច់ប្រាក់។ គ្មានអង្គភាពណាអាចលក់ទ្រព្យសកម្មមួយជាមួយលក្ខណៈសម្រាប់សីយូ១០ទេ។

## អត្រាអប្បហារ

ក១៥ វិធីសាស្ត្រណាមួយ ដែលអង្គភាពមួយអនុវត្តសម្រាប់ការវាស់វែងតម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្មមួយ អត្រាអប្បហារប្រើដើម្បីអប្បហារលំហូរសាច់ប្រាក់មិនគួរឆ្លុះបញ្ចាំងពីហានិភ័យសម្រាប់ការប៉ាន់ស្មាន លំហូរសាច់ប្រាក់ដែលបានកែតម្រូវទេ។ មិនដូច្នោះទេ ការប៉ះពាល់ការសន្មតនឹងត្រូវរាប់ស្ទួន។

ក១៦ នៅពេល អត្រាជាក់លាក់ នៃទ្រព្យសកម្មមួយគ្មាន ដោយផ្ទាល់ពីទីផ្សារ អង្គភាពមួយប្រើអត្រាជំនួស ដើម្បីប៉ាន់ស្មានអត្រាអប្បហារ។ គោលបំណង នៃការប៉ាន់ស្មានគឺការវាយតម្លៃទីផ្សារ÷

(ក) តម្លៃពេលវេលានៃលុយ សម្រាប់គ្រារហូតដល់ចុងអាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម និង

(ខ) កត្តា (ខ) (ឃ) និង (ង) បានបរិយាយក្នុងកថាខណ្ឌទី ក១ កត្តាទាំងនោះដែលមិនបណ្តាលឱ្យមានការកែតម្រូវក្នុងការទទួលបានការប៉ាន់ស្មានលំហូរសាច់ប្រាក់។

ក១៧ ជាចំនុចចាប់ផ្តើមក្នុងការធ្វើការប៉ាន់ស្មាន អង្គភាពអាចពិចារណានូវអត្រាដូចខាងក្រោម÷

(ក) ចំណាយថ្លៃដើមមូលធនជាមធ្យមរបស់អង្គភាពបានកំណត់ ដោយប្រើបច្ចេកទេសដូចជា គំរូកំណត់ថ្លៃដើមមូលធន

(ខ) ការបង្កើនអត្រាខ្ចីប្រាក់បន្ថែមរបស់អង្គភាព និង

(គ) អត្រាខ្ចីប្រាក់ដទៃទៀត។

ក១៨ ប៉ុន្តែ អត្រាត្រូវតែកែតម្រូវដូចខាងក្រោម÷

(ក) ឆ្លុះបញ្ចាំងពីមធ្យោបាយ ដែលទីផ្សារអាចវាយតម្លៃពីហានិភ័យជាក់លាក់ពាក់ព័ន្ធជាមួយការប៉ាន់ស្មានលំហូរសាច់ប្រាក់របស់ទ្រព្យសកម្ម និង

(ខ) ដកចេញនូវហានិភ័យដែលមិនពាក់ព័ន្ធទៅនឹងការប៉ាន់ស្មានលំហូរសាច់ប្រាក់របស់ទ្រព្យសកម្ម ឬសម្រាប់ការប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលត្រូវបានកែតម្រូវរបស់ទ្រព្យសកម្ម។

ការពិចារណាផ្ដល់បានផ្ដល់ទៅហានិភ័យដូចជាហានិភ័យប្រទេស ហានិភ័យរូបិយប័ណ្ណ និងហានិភ័យថ្លៃ។

ក១៩ អត្រាអប្បហារគឺមិនពឹងផ្អែកនៃរចនាសម្ព័ន្ធទុនរបស់អង្គភាព និងរបៀបដែលអង្គភាពធ្វើហិរញ្ញប្រទានទិញទ្រព្យសកម្ម ព្រោះថាការរំពឹងទុកលំហូរសាច់ប្រាក់អនាគតកើតឡើង ពីទ្រព្យសកម្មមួយមិនផ្អែកលើរបៀបដែលអង្គភាពធ្វើហិរញ្ញប្បទានទិញទ្រព្យសកម្ម។

ក២០ កថាខណ្ឌទី ៥៥ តម្រូវឱ្យប្រើអត្រាអប្បហារមុនពេលបង់ពន្ធ។ ដូចនេះនៅពេលប្រើមូលដ្ឋានក្នុងការប៉ាន់ស្មានអត្រាអប្បហារគឺក្រោយពេលបង់ពន្ធនោះជាមូលដ្ឋានត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងអត្រាមុនពេលបង់ពន្ធ។

ក២១ អង្គភាពមួយប្រើជាផ្លូវការនូវអត្រាអប្បហារសម្រាប់ការប៉ាន់ស្មាននៃតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្ម។ប៉ុន្តែ អង្គភាពមួយប្រើអត្រាអប្បហារដាច់ដោយឡែកសម្រាប់គ្រាអនាគតខុសគ្នាដែលតម្លៃកំពុងប្រើប្រាស់មានរំញោចទៅនឹងហានិភ័យសម្រាប់គ្រាខុសគ្នាឬរចនាសម្ព័ន្ធនៃអត្រាការប្រាក់។

## ឧបសម្ព័ន្ធ ខ

ធ្វើវិសោធនកម្ម មិនអនុវត្តចំពោះលក្ខខណ្ឌ

## ឧបសម្ព័ន្ធ គ

## ការធ្វើតេស្តការធ្លាក់ចុះតម្លៃអង្គភាពរកសាច់ប្រាក់ជាមួយមូលនិធិពាណិជ្ជកម្ម និងភាគកម្មអប្បភាគ

ឧបសម្ព័ន្ធនេះគឺជាការផ្អែកនៃស្តង់ដា។

គ១ ស្របតាម ស.រ.ហ.អ.ក ៣ (បានកែសម្រួលក្នុងឆ្នាំ ២០០៨) អ្នកទិញវាស់វែង និងទទួលស្គាល់មូលនិធិពាណិជ្ជកម្មនៅថ្ងៃទិញជាការលើសនៃ (ក) លើ (ខ) ដូចខាងក្រោម÷

(ក) ការសរុបនៃ÷

(១) ការវាស់វែងការផ្ទេរស្របតាម ស.រ.ហ.អ.ក ៣ ដែលតម្រូវថ្ងៃទិញនូវតម្លៃសមស្រប

(២) តម្លៃនៃភាគកម្មអប្បភាគផលចំណេញដែលមិនអាចត្រួតត្រាក្នុងអ្នកលក់វាស់វែងស្របតាម ស.រ.ហ.អ.ក ៣ និង

(៣) ក្នុងការរួមបញ្ចូលអាជីវកម្មទទួលបានក្នុងដំណាក់កាល ថ្ងៃទិញតម្លៃសមស្របនៃអ្នកទិញមុនដែលចាត់ទុកភាគកម្មនៃមូលធនផ្ទាល់ចំនេញមូលធនរបស់អ្នកលក់។

(ខ) តម្លៃសុទ្ធនៅថ្ងៃទិញនៃទ្រព្យសកម្មទទួលបាននិងបំណុលបានវាស់វែងស្របតាម ស.រ.ហ.អ.ក ៣។

## ការបែងចែកមូលនិធិពាណិជ្ជកម្ម

គ២ កថាខណ្ឌទី ៨០ នៃស្តង់ដានេះតម្រូវឱ្យមូលនិធិពាណិជ្ជកម្មក្នុងការបញ្ចូលអាជីវកម្ម ត្រូវបានបែងចែកទៅកាន់អង្គភាពរកសាច់ប្រាក់របស់ អ្នកទិញនីមួយៗ ឬក្រុមនៃអង្គភាពរកសាច់ប្រាក់រំពឹងថាទទួលបានអត្ថប្រយោជន៍ពីផលនៃការបញ្ចូលគ្នា មិនពាក់ព័ន្ធពីទ្រព្យសកម្ម ឬបំណុលផ្សេងៗ នៃអ្នកលក់បានបែងចែកទៅអង្គភាពទាំងនោះ ឬក្រុមនៃអង្គភាព។ លទ្ធភាពដែល

ផល ដែលចេញពីការបញ្ចូលអាជីវកម្ម នឹងត្រូវបានបែងចែកទៅអង្គភាពរកសាច់ប្រាក់ដែលភាគកម្មអប្បភាគមិនមានផលប្រយោជន៍។

## ការធ្វើតេស្តការធ្លាក់ចុះតម្លៃ

គ៣ ការធ្វើតេស្តការធ្លាក់ចុះតម្លៃពាក់ព័ន្ធនឹងការប្រៀបធៀបតម្លៃអាចទទួលបានមកវិញ នៃអង្គភាពរកសាច់ប្រាក់ជាមួយតម្លៃ ក្នុងបញ្ជីនៃអង្គភាពរកសាច់ប្រាក់។

គ៤ ប្រសិនបើ អង្គភាពមួយវាស់វែងភាគកម្មអប្បភាគ ជាផ្នែកមួយនៃផលប្រយោជន៍ ក្នុងការកំណត់ទ្រព្យសកម្មសុទ្ធនៃបុត្រសម្ព័ន្ធនៅថ្ងៃទិញ មិនមែននៅតម្លៃសមស្រប មូលនិធិពាណិជ្ជកម្មបែងចែកទៅភាគកម្មអប្បភាគ គឺត្រូវបានបញ្ចូលក្នុងតម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ពាក់ព័ន្ធនឹងអង្គភាពរកសាច់ប្រាក់ ប៉ុន្តែមិនត្រូវបានទទួលស្គាល់ក្នុងការរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុនមេ។ ជាលទ្ធផល អង្គភាពមួយត្រូវធ្វើការបន្ថែមតម្លៃក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្មបានបែងចែកទៅអង្គភាពរួមបញ្ចូលមូលនិធិពាណិជ្ជកម្មអាចបែងចែកទៅភាគកម្មអប្បភាគ។ ការកែតម្រូវតម្លៃក្នុងបញ្ជីបន្ទាប់មកត្រូវបានប្រៀបធៀបជាមួយតម្លៃអាចទទួលបានមកវិញ នៃអង្គភាពដើម្បីកំណត់ពីតម្លៃដែលអាចធ្លាក់ចុះរបស់អង្គភាពរកសាច់ប្រាក់។

## ការបែងចែកការខាតពីការធ្លាក់ចុះតម្លៃ

គ៥ កថាខណ្ឌទី ១០៤ តម្រូវឱ្យកំណត់ការធ្លាក់ចុះតម្លៃត្រូវបែងចែកជាមុន ដើម្បីកាត់បន្ថយតម្លៃក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្មបានបែងចែកទៅកាន់អង្គភាព

និងបន្ទាប់មកទៅកាន់ទ្រព្យសកម្មនៃអង្គភាពតាមមូលដ្ឋានសមាមាត្រ នៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មក្នុងអង្គភាព។

គ៦ ប្រសិនបើបុត្រសម្ព័ន្ធមួយ ឬផ្នែកមួយនៃបុត្រសម្ព័ន្ធ ជាមួយភាគកម្មអប្បភាគ គឺជាអង្គភាពរកសាច់ប្រាក់ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបានបែងចែករវាងក្រុមហ៊ុនមេ និងភាគកម្មអប្បភាគផ្អែកលើមូលដ្ឋានបែងចែកចំណេញ ឬខាត។

គ៧ ប្រសិនបើបុត្រសម្ព័ន្ធមួយ ឬផ្នែកមួយនៃបុត្រសម្ព័ន្ធ ជាមួយភាគកម្មអប្បភាគ គឺជាផ្នែកដ៏ធំនៃអង្គភាពរកសាច់ប្រាក់ ការខាតពីការធ្លាក់ចុះតម្លៃនៃមូលនិធិពាណិជ្ជកម្ម ត្រូវបានបែងចែកទៅផ្នែកមួយនៃ អង្គភាពរកសាច់ប្រាក់ ដែលមានភាគកម្មអប្បភាគ និងផ្នែកដែលមិនមាន។ ការខាតពីការធ្លាក់ចុះតម្លៃគួរត្រូវបានបែងចែកទៅផ្នែកមួយនៃអង្គភាពរកសាច់ប្រាក់ផ្អែកលើមូលដ្ឋាន÷

(ក) ការធ្លាក់ចុះតម្លៃពាក់ព័ន្ធនឹងមូលនិធិពាណិជ្ជកម្មក្នុងអង្គភាពរកសាច់ប្រាក់ពាក់ព័ន្ធតម្លៃ ក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្មនៃផ្នែកមុនពេលធ្លាក់ចុះតម្លៃ និង

(ខ) ការធ្លាក់ចុះតម្លៃពាក់ព័ន្ធ នឹងការកំណត់ទ្រព្យសកម្មក្នុងអង្គភាពរកសាច់ប្រាក់ពាក់ព័ន្ធតម្លៃក្នុងបញ្ជី នៃតម្លៃទ្រព្យសកម្មសុទ្ធនៃផ្នែកមុនពេលធ្លាក់ចុះតម្លៃ។ ការធ្លាក់ចុះតម្លៃណាមួយត្រូវបានបែងចែកទៅទ្រព្យសកម្មនៃផ្នែក នៃអង្គភាពផ្អែកលើមូលដ្ឋានសមាមាត្រនៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្ម នីមួយៗក្នុងផ្នែក។

ក្នុងផ្នែកទាំងនោះដែលភាគកម្មអប្បភាគ ការខាតពីការធ្លាក់ចុះតម្លៃត្រូវបាន បែងចែករវាងក្រុមហ៊ុនមេ និងភាគកម្មអប្បភាគ ផ្អែកលើមូលដ្ឋានចំណេញ ឬខាតត្រូវ។

គ៨ ប្រសិនបើការខាតពីការធ្លាក់ចុះតម្លៃបែងចែកទៅភាគកម្មអប្បភាគពាក់ព័ន្ធនឹងមូលនិធិពាណិជ្ជកម្ម ដែលមិនត្រូវបានទទួលស្គាល់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុនមេ (សូមមើលកថាខណ្ឌទី គ៤) ដែលការធ្លាក់ចុះតម្លៃមិន ត្រូវបានទទួលស្គាល់ ជាការខូចខាតការធ្លាក់ចុះនៃតម្លៃមូលនិធិពាណិជ្ជកម្ម។ ក្នុងករណីនេះ មានតែការខាតពីការធ្លាក់ចុះតម្លៃពាក់ព័ន្ធនឹងមូលនិធិពាណិជ្ជកម្ម ដែលត្រូវបានបែងចែកទៅក្រុមហ៊ុនមេត្រូវបានទទួលស្គាល់ជាការខាតពីការធ្លាក់ចុះតម្លៃមូលនិធិពាណិជ្ជកម្ម។

គ៩ ការបង្ហាញក្នុងឧទាហរណ៍ទី ៧ បង្ហាញពីការធ្វើតេស្តការធ្លាក់ចុះតម្លៃនៃមូលនិធិពាណិជ្ជកម្មនៃផ្នែកមិនកាន់កាប់ដោយ អង្គភាពរកសាច់ប្រាក់។

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា

អាស័យដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh



ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ